ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Sep-2012, 15:46
CMS/CFO: Krystal THOMPSON

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី១០៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាវស្ស៊ី

កញ្ញា សុង ឆវ័ន្ត

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms.Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក នង សុផង់ (TCW-480) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក នន សុផន់** (TCW-480)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ផ្តើមពី៖............................................................ទំព័រ ៣

សួរដោយលោក គង់ សំអុន ផ្តើមពី៖....................................................................ទំព័រ ២៧

សួរដោយលោក អាកឡូរ វែកគែន ផ្តើមពី៖.........................................................ទំព័រ ៣២

សួរដោយលោក សុន អរុណ ផ្តើមពី៖.................................................................ទំព័រ ៤៨

សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី ផ្តើមពី៖ ......................................................ទំព័រ ៦១

E1/122.1

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ កិច្ចដំណើរការសវនាការនឹងបន្តការតាំងសំណួរដេញដោលចំពោះសាក្សី នង សុផង់ ដែលនឹងសួរដោយក្រុមមេធាវីការពារក្ដីដែលចាប់ផ្ដើមពីក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដំបូងគេ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញ ឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៥:២១]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែលោកមេធាវីជាតិការពារក្ដីឲ្យលោក អៀង សារី។ លោកមេធាវី អាង ឧត្ដម អវត្តមាន ដោយមានធុរៈផ្ទាល់ខ្លួន និងជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ។ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ សម្រាប់រយៈពេលពេញ១ថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដោយឡែកសាក្សីបម្រុងដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មសាក្សី នង សុផង់ គឺសាក្សីដែលរហស្សនាម TCW-307។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកកាលពីពេលព្រឹកមិញនេះ។

សូមអរគុណ។

[០៩:០៦:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈធ្វើសវនាការពេញមួយថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត ឈា គន្ធាវី គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ បានកត់សម្គាល់ឃើញថាលោក អៀង សារី មានអាការៈហត់ខ្លាំង ពេលធ្វើចលនាបន្តិចបន្តួច, វិលមុខ នៅពេលដើបឈរ, នោមញឹកញាប់ និងឈឺចង្កេះមិនអាចអង្គុយយូរបាន។ និងបានផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

នៅពេលនេះ លោក អៀង សារី បានស្នើសុំលះបង់សិទ្ធិមានវត្តមាន នៅក្នុងបន្ទប់សវនាការដោយផ្ទាល់ដោយគាត់មានសុខភាព -- មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់។ តែរូបកាយនិងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅពីក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយអាចសម្រួលទំនាក់ទំនងរវាងគាត់ ជាមួយនឹងមេធាវីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំ របស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:០៨:២៨]

លោក នង សុផង់ តាមព័ត៌មានដែលយើងទទួលបាន គឺនៅព្រឹកនេះក៏លោកមានបញ្ហាសុខភាព

ដូចពីម្សិលមិញដែរ ដោយអាការៈខាងសម្ពាធឈាមឡើងខ្ពស់។ ប៉ុន្តែលោកបានប្តេជ្ញាចិត្តថា បន្តផ្តល់សក្ខីកម្ម។ ដូច្នេះនៅក្នុងអំឡុងពេលនៃដំណើរការសវនាការដេញដោលនេះ ប្រសិនបើលោកមានអាការៈប្រមើមើល៍ថា លោកមិនអាចទៅរួចទេ ឬក៏មានបញ្ហាដែលធ្ងន់ លោកអាចស្នើសុំមកយើងដើម្បីសម្រាកឬក៏អាចសម្រាកបណ្តោះអាសន្ន ឬក៏សម្រាកក្នុងពេលណាមួយសមស្រប ដើម្បីឱ្យសុខភាពរបស់លោកហ្នឹងអាចប្រសើរឡើងវិញ។ សូមលោកកុំខ្លាចរអែងអី។

[០៩:០៩:២៣]

**លោក នង សុផង់៖**

បាទ អរគុណលោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះមុនសហមេធាវីពីរក្រុមទៀត។

បាទ សូមអធ្យាស្រ័យ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

បាទ សូមលោកក្រុមមេធាវី ខៀវ សំផន អង់សិន រង់ចាំការសាកសួររបស់លោកចៅក្រមចប់។ សូមអញ្ជើញ!

[០៩:១០:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោក នង សុផង់។ ខ្ញុំជាចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវចោទសួរលោក។ ខ្ញុំសូមអរគុណ ចំពោះការខិតខំប្រឹងប្រែងរបស់លោកក្នុងការផ្តល់សក្ខីកម្ម។ ខ្ញុំសូមបញ្ជាក់ថា សក្ខីកម្មរបស់លោកមានសារៈសំខាន់ខ្លាំងណាស់ អាស្រ័យហេតុនេះហើយ បានជាខ្ញុំចង់ឱ្យលោកបំភ្លឺនូវចំណុចមួយចំនួន។

ជាបឋម ខ្ញុំសូមពិនិត្យមើលឡើងវិញទៅលើទូរលេខមួយចំនួន។ ទូរលេខដំបូង គឺទូរលេខដែលមានលេខ E3/244។ ខ្ញុំមានឯកសារជាក្រដាស ដែលផ្តល់ជូនសាក្សី សូមមន្ត្រីតុលាការជួយផ្តល់

ឯកសារនេះជូនសាក្សី។ ខ្ញុំសូមបញ្ជាក់ថា បញ្ជីឯកសារដែលខ្ញុំនឹងប្រើប្រាស់នេះ ខ្ញុំបានផ្ដល់ជូនភាគីរួចអស់ហើយសម្រាប់ជាព័ត៌មាន ហើយនិងសម្រាប់ជាការគួរសម ហើយបញ្ជីនេះមានបញ្ជាក់អំពីលេខ ERN របស់ឯកសារទាំងអស់។ ដូច្នេះ ខ្ញុំមិនចាំបាច់ផ្ដល់លេខ ERN ទាំងអស់នោះទេ នៃឯកសារ ពីព្រោះថា វាជួយសម្រួលឲ្យមានដំណើរការទៅលឿន។

ឯកសារ E3/244 គឺជាទូរលេខ១៦ គោរពជូនបងប៉ ជាទីស្នេហា និងរឭក ចុះថ្ងៃទី២៣ ខែ១ ឆ្នាំ៧៨ ចុះហត្ថលេខដោយ ឆុន។ នៅទំព័រទី២ ខាងក្រោមយើងឃើញមានព័ត៌មានមួយចំនួន ជាពិសេស គឺបុគ្គលដែលត្រូវចម្លងជូន។ ខ្ញុំមានសំណួរដំបូង ដោយសារតែមានបញ្ហាពាក់ព័ន្ធទៅនឹងការបកប្រែជាភាសាបារាំង។ នៅក្នុងឯកសារនេះមានបញ្ជាក់ថា "ចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ, ឯកសារ"។ ជាភាសាបារាំង អ៊ំនេះគឺដាក់ជាពហុវចនៈ ក្នុងឯកសារនេះក៏ដូចជា ឯកសារផ្សេងទៀត។ ចុះចំពោះឯកសារខ្មែរវិញលោកសាក្សី តើឯកសារនេះគេបញ្ជាក់ថា អ៊ំហ្នឹងជាពហុវចនៈ ឬក៏ឯកវចនៈ? ហើយខ្ញុំមានសំណួរដូចគ្នា ពាក់ព័ន្ធទៅនឹងពាក្យថា "មន្ទីរ" នៅក្នុងភាសាបារាំងនេះក៏មន្ទីរនេះដាក់ជាពហុវចនៈដែរ។ តើជាភាសាខ្មែរ មន្ទីរហ្នឹងពហុវចនៈ ឬក៏ជាឯកវចនៈ ឬក៏មន្ទី៨៧០ ឬក៏មន្ទីរណាផ្សេងទៀត? សូមលោកជួយបញ្ជាក់ត្រង់ចំណុចនេះឲ្យបានច្បាស់បន្តិច។

[០៩:១៣:២៨]

**លោក នង សុផង់៖**

**ឆ៖** បាទ អរគុណបាទ ដែលពាក្យថា ចម្លងជូនអ៊ំ មិនមែនជាសំដៅពហុវចនៈទេ គឺឯកវចនៈ។ សំដៅលើ បងប៉ុល បាទ ដែលជាបងទី១ហ្នឹង នេះចំពោះអ៊ំ។ ឯមន្ទីរ ក៏មិនមែនពហុវចនៈដែរ គឺសំដៅមន្ទីរមួយរបស់៨៧០ហ្នឹងតែម្ដងបាទ មិនមែនមន្ទីរទូទៅនានាទាំងអស់ ដែលនៅក្នុងភ្នំពេញទាំងអស់ទេបាទ។

**ស៖** ចំពោះមន្ទីរ៨៧០ តើលោកដឹងច្បាស់ទេថាតើមន្ទីរនេះ មានទីតាំងនៅឯណាដែរ? តើនៅ ក-១ ឬក៏នៅកន្លែងណាផ្សេងទៀត? សូមលោកជួយបញ្ជាក់ទីតាំងនៃមន្ទីរ៨៧០ ឲ្យបានច្បាស់។ តើលោកដឹងទេ តើលោកមានព័ត៌មានអី ដែលបញ្ជាក់ឲ្យយើងអាចដឹងបានថា មន្ទីរ៨៧០ នេះមានទីតាំងនៅឯណាទេ?

[០៩:១៥:០០]

**ឆ៖** បាទ ខ្ញុំខ្លួនឯងក៏មិនច្បាស់ដែរបាទ មិនដឹងដែរបាទ។ ព្រោះខ្ញុំដឹងតែថាបកសារហើយ ជូន

ទៅ ក-១ ឯអ្នកណាទទួលណាអីគឺខ្ញុំ -- មន្ទីរត្រង់ណា អីត្រង់ណា គឺអត់ដឹងទេបាទ។

**ស៖** នៅពេលដែលយើងឃើញបញ្ជីឈ្មោះបុគ្គលដែលត្រូវចម្លងជូន យើងឃើញ អ៊ំ គឺមានន័យ អ៊ំ គឺមានន័យថា អ៊ំប៉ុល ពត ហើយមន្ទីរនោះមានន័យថាជាមន្ទីរផ្សេងគ្នា។ ប៉ុល ពត មិនមែនជាមន្ទីរទេ។ អ៊ីចឹងតើលោកយល់ឯកភាពតាមអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំយល់ថា ចំពោះអ៊ំហ្នឹង គឺគេឲ្យលោក ប៉ុល ពត មួយសន្លឹក ហើយគេរក្សាទុកនៅកន្លែងមន្ទីរហ្នឹងមួយសន្លឹក។ គឺផ្សេងពី ប៉ុល ពត។

**ស៖** ទូរលេខនេះត្រូវបានចុះហត្ថលេខាដោយឈ្មោះ ឆុន។ លោកបានបញ្ជាក់ថា លោកមិនដឹងអ្នកណាទេ ឆុន ហ្នឹង តើថ្ងៃហ្នឹងលោកអាចបញ្ជាក់បានទេ ថាតើអ្នកណាគេឈ្មោះ ឆុន ហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនស្គាល់ច្បាស់ថា ឆុន ហ្នឹងជានរណាទេ។ តែដូចជាសារមុនៗដែរ ធម្មតាអ្នកដែលមានសិទ្ធិធ្វើរបាយការណ៍ឡើងមកខាងលើនេះ គឺនេះគឺជាទូរលេខរបស់ខាងបូព៌ា។ អ៊ីចឹងគឺយើងឃើញថា ទូរលេខមុនៗក៏ឃើញ ឆុន ទូរលេខនេះក៏ឃើញ ឆុន។ អ៊ីចឹងគឺ ឆុន ហ្នឹង គឺជាថ្នាក់ដឹកនាំនៅភូមិភាគបូព៌ា។

[០៩:១៧:៤៨]

**ស៖** ដូច្នេះតើយើងអាចនិយាយបានថាជា សោ ភឹម ទេ? បើសិនជាលោកមិនច្បាស់ ខ្ញុំមិនចង់ឲ្យបញ្ជាក់ច្បាស់ទេ គ្រាន់ថាតើជាលទ្ធភាពទេ អាចទេ អាចជា សោ ភឹម ទេ?

**ឆ៖** បាទ វាមាន វាអាចមានលទ្ធភាពដែរ។ ពីព្រោះដូចលោកដឹងហើយ ឧបមាថា បងខៀវ ដូច បងខៀវ នេះគឺគេមិនដាក់ សុន សេន ទេ ជួនកាលគេដាក់តែ ខៀវ។ នេះគឺបានន័យថា សុន សេន ហើយ មិនមែន ខៀវ សំផន ទេ។ ហើយដូច ឆុន ហ្នឹងអ៊ីចឹងដែរ។ ជួនណាគេមិនដាក់ សោ ភឹម ចំទេ គឺគេដាក់ ឆុន ហ្នឹង គឺ ឆុន ហ្នឹងបានន័យថា ឈ្មោះដែលគាត់ប្រើទូទៅក្នុងកាលសម័យនោះ គឺគាត់ដាក់ ឆុន អ៊ីចឹងតែម្តង។ អាចអ៊ីចឹងដែរបាទ។

**ស៖** បាទ សូមអរគុណ។ ទូរលេខនេះគឺមកពីភូមិភាគបូព៌ា ហើយដែលផ្តល់ព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងសភាពការណ៍នៅព្រំដែន និងជម្លោះជាមួយវៀតណាម។ ខ្ញុំសូមអានកថាខណ្ឌទី៣ ដែលនៅទំព័រទី២ នៃឯកសារនេះ។ កថាខណ្ឌ៣ សរសេរថា “សភាពការណ៍ប្រជាជនបានរៀបរយ ប្រជាជនដែលនៅព្រំដែនឲ្យថយមកស្នាក់នៅខាងក្រោយអស់ហើយ។ ហើយបានប្រជុំរៀនសូត្រអប់រំជាប់ ម្យ៉ាងសម្រិតសម្រាំងសមាសភាពខ្សែយួន ខ្មាំងយួន មិនឲ្យនៅច្របូកច្របល់នឹងប្រជាជនល្អទេ។ តាមដាន

អប់រំដោយឡែក"។ លោកសាក្សី តើលោកធ្លាប់ទទួលឯកសារប្រភេទនេះទេ ឬក៏ខ្លឹមសារនៃឯកសារនេះធ្វើឱ្យលោកមានការភ្ញាក់ផ្អើល? មានន័យថា លោកមិនធ្លាប់ឃើញឯកសារ -- ខ្លឹមសារបែបនេះទេ?

**ឆ៖** បាទ ខ្លឹមសារនិយាយពីរឿងសម្រិតសម្រាំង ខ្ញុំក៏ធ្លាប់បានទទួលពីភូមិភាគនានា ដូចជាឯកសារហ្នឹងដែរ ក៏ប៉ុន្តែអ្វីដែលខ្ញុំមិនដឹង គឺថាមិនដឹងជាគេសម្រិតសម្រាំងយ៉ាងណា សភាពជាក់ស្តែងយ៉ាងណាពិតប្រាកដនោះទេ បាទ។

[០៩:២១:០១]

**សៈ** ខ្ញុំសូមបញ្ជាក់ថា ទូរលេខនេះ គឺលេខ E3/244។ ERN ជាភាសាខ្មែរ 00001052 ដល់ 1053, ជាភាសាបារាំង 00634386 ទៅដល់ 87, ជាភាសាអង់គ្លេស 00182755 ទៅដល់56។ ឥឡូវនេះ ខ្ញុំសូមចូលទៅទូរលេខមួយទៀត គឺទូរលេខ១៥ ឯកសារ E3/243។ ខ្ញុំមានឯកសារក្រដាសដែលត្រូវផ្តល់ជូនសាក្សី។ សូមមន្ត្រីតុលាការជួយ។ ERN នៃឯកសារនេះ មានដូចតទៅ ជាភាសាខ្មែរ 00020938 ទៅដល់ 40, ជាភាសាបារាំង 00548911 ទៅដល់ 13, អង់គ្លេស 00532795 ទៅដល់ 96។ នេះគឺជា -- បាទជាភាសាបារាំង ហើយជាភាសាអង់គ្លេស ដូចជាមានភាពខុសគ្នា។ អង់គ្លេស ថា "គោរពជូន បងប៉" បារាំងថា "គោរពជូន បងប៉ ជាទីស្នេហានិងរឭក"។ តើលោកអាចអានបញ្ជាក់ឱ្យបានច្បាស់ទេ ថានៅក្នុងឯកសារនេះ ជាភាសាខ្មែរ គេដាក់គោរពជូនណាដែរ?

**ឆ៖** បាទ គោរពជូនបងប៉ នោះ គឺធម្មតា គេមានសរសេរកាត់ ប៉ុល អ៎! គេមិនដាក់ ប៉ុល ផ្ទាល់ទេ ជួនកាលគេគ្រាន់តែដាក់ ប៉ ហ្នឹង គេអាចយល់ហើយ។ ថា ប៉ នេះ គឺ ប៉ុល ហ្នឹងហើយបាទ។ គឺបងទី១ ហ្នឹងហើយ។

**សៈ** តើប៉ុល ពត មានឈ្មោះហៅក្រៅច្រើនទេ? មាន ប៉ ផង, ប៉ុល ផង ឬក៏យើងមានរបៀបអ្វីផ្សេងទៀតទេ ដើម្បីហៅឈ្មោះ ប៉ុល ពត នោះ?

**ឆ៖** បាទ ក្នុងសម័យហ្នឹង គឺ ប៉ នេះ គឺប្រើចំពោះតែខាងភូមិភាគបូព៌ាទេ គាត់ហៅកាត់អ៊ីចឹង។ ប៉ុន្តែកន្លែងផ្សេងៗទៀត ភាគច្រើនគេ ឯកសារផ្សេងៗទៀត ជួនកាល គឺគេដាក់ ប៉ុល ចំអ៊ីចឹងតែម្តង បងប៉ុល ចំតែម្តង ឬមួយខ្លះទៀត គេមិនប៉ាននិយាយចំថា ប៉ុល ឬ ប៉ ទេ គ្រាន់តែដាក់ "បងជាទីស្នេហានិងរឭក" គឺសំដៅថា បងទី១ ហើយបាទ។ អត់មានបងណា ធំជាងបងទី១ ទៀតទេ បាទ។

[០៩:២៤:៣៤]

**សៈ** ទូរលេខនេះ ត្រូវបានផ្ញើដោយឈ្មោះដដែល គឺឈ្មោះ ឆុន ដែលជាសារមកពីភូមិភាគបូព៌ា

ដែលរាយការណ៍អំពីសភាពការណ៍នៅតាមព្រំដែន។ ហើយនៅក្នុងកថាខណ្ឌ៣ សរសេរថា “យើងបានរៀបចំប្រជាជន និងបានដកជម្លៀសចេញពីមុខអស់ហើយ។ ជួរមុខកងទ័ពនៅការពារ ចំពោះការរៀបរយប្រជាជនដែលអាខ្មាំងយួនវាកៀរទៅគ្រប់គ្រងបណ្តោះអាសន្ន និងមួយចំនួនតូចជឿតាមយួនត្រូវយើងប្រមូលបានមកវិញមួយភាគធំ។ បច្ចុប្បន្នយើងរៀបចំយកមកក្រោយអស់ ដើម្បីអប់រំ និងបែងចែកសម្រិតសម្រាំង”។ តើទូរលេខនេះគឺជាទូរលេខដែលលោកបកប្រែឬក៏មានខាងផ្នែកផ្សេងទៀតដែលបកប្រែទូរលេខនេះ? លោកមានចាំពីទូរលេខនេះទេ?

**ឆ៖** បាទ ទិសបូព៌ាហ្នឹងគឺដែលមានសភាពការណ៍ជាប់ជាមួយនឹងវៀតណាម មិនមែនជាទិសដែលខ្ញុំទទួលបកប្រែទេបាទ។ គឺគេបកប្រែនៅខាងក្នុង កន្លែងលោក ប៉ុន។

**ស៖** បើតាមលោកដឹង តើលោកអាចបញ្ជាក់បានទេ ពាក្យថា “អប់រំ”, “បែងចែក”, “សម្រិតសម្រាំង” នេះ តើមានន័យថាម៉េចដែរ? នៅក្នុងភាសាបារាំងគឺនៅក្នុងកថាខណ្ឌទី៣ ដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺមានពាក្យ “អប់រំ”, “បែងចែក” និង “សម្រិតសម្រាំង” តើលោកអាចពន្យល់បានទេចំពោះពាក្យទាំងបីនេះ?

[០៩:២៧:១២]

**ឆ៖** បាទ ខ្ញុំ ពាក្យហ្នឹងគឺខ្ញុំមិនអាចពន្យល់ដោយស្មានៗបានទេ ក្រែងលោវាខុស ពីព្រោះខ្ញុំមិនបានអនុវត្តបាទ។ គឺខ្ញុំសូមរក្សាសិទ្ធិមិននិយាយ ពីព្រោះពាក្យហ្នឹងគឺ ខ្ញុំបានជម្រាបអង្គសវនាការដដែលៗថាខ្ញុំមិនៗដឹងទេ ការជាក់ស្តែងយ៉ាងម៉េចបាទ។ អ៊ីចឹង ខ្ញុំធ្វើការពន្យល់ទៅវាមិនត្រូវបាទ។

**ស៖** សូមអរគុណលោក សុផង់។ ខ្ញុំមានសំណួរបញ្ជាក់ចុងក្រោយពាក់ព័ន្ធទៅនឹងឯកសារនេះៗត្រូវបានចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, មន្ទីរ, ឯកសារ ដូច្នេះក្នុងនេះគឺ នួន គឺ នួន ជា ចុះឈ្មោះ វ៉ាន់ តើ អៀង សារី មែនទេ វ៉ាន់ ហ្នឹង?

**ឆ៖** បាទ គឺលោក អៀង សារី បាទ។

**ស៖** តើលោក អៀង សារី មានឈ្មោះហៅក្រៅផ្សេងទៀតទេ មានន័យយើងមានរបៀបហៅឈ្មោះ -- ហៅបង អៀង សារី ហ្នឹងផ្សេងក្រៅពី វ៉ាន់ ទេ?

**ឆ៖** មិនមានទេបាទ។

[០៩:២៨:៤១]

**ស៖** បង វន គឺ វន វ៉េត ហើយបន្ទាប់មកគឺមន្ទីរ, ឯកសារ។ ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារ

ទី៣ គឺទូរលេខ៦៩ ហើយខ្ញុំមានក្រដាសសូមផ្តល់ជូនសាក្សី។ ទូរលេខនេះ គឺមានលេខ E3/1122, ERN ជាភាសាខ្មែរ 00020932, បារាំង 00511626, អង់គ្លេស 00436992។ ទូរលេខនេះត្រូវបានផ្ញើដោយឈ្មោះ វី ជូនបងជាទីគោរព ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៨។ តើលោកអាចបញ្ជាក់អំពីអ្នកផ្ញើ និងអ្នកទទួលទូរលេខនេះទេ? អំនេះគឺយើងដឹងហើយថា ប៉ុល ពត ចុះ វី អ្នកផ្ញើហ្នឹងតើជាអ្នកណាដែរ?

**ផ៖** បាទ វី ហ្នឹងគឺជាលេខាភូមិភាគព្រៀសានបាទ។

**ស៖** ទូរលេខនេះមានបញ្ជាក់ថា "ចំពោះវិធានការទូទៅកំពុងប្រមូលផលស្រូវដឹកចូលមកខាងក្នុង ខាង១០៤, ខាង១០១, ខាង១០៧ និងដូរប្រជាជនមួយចំនួនទៅម-៥, ម-៦ និងកោះភ្នៅ អូរស្វាយ។ ពួកសៀមប៉ាងខាងលិចទន្លេក្នុងពេលរៀបចំដីស្រែបានដកបន្តិចម្តងៗ រហូតគ្រប់ចំនួនដីមកនៅខាងកើត ព្រោះខាង១០៧ វានៅជិតព្រំដែនលាវ និងចោទរកទឹក។ ម-៥, ម-៦ ខាងលាវ វានៅជិតព្រំដែនដូចកោះភ្នៅ អូរស្វាយ"។ តើលោកអាចបញ្ជាក់ពីទីកន្លែងនៅក្នុងឃ្លានេះបានទេ? តើនៅកន្លែងណាខ្លះដូចជា ១០៤, ១០១, ១០៧ហ្នឹង តើជាតំបន់មែនទេ? ហើយចុះ ម-៥, ម-៦ នេះ ជាស្អីដែរ?

[០៩:៣២:០៥]

**ផ៖** បាទ ចំពោះ១០៤, ១០១, ១០៧ គឺជាតំបន់អ៊ីចឹងមែន។ ឯរឿង "ម" ខ្ញុំមិនដឹងទេបាទ។ ម គឺជាទូទៅក្នុងសម័យហ្នឹងគឺសំដៅលើមន្ទីរបាទ។ អ៊ីចឹងមិនមែនជាតំបន់ទេ។

**ស៖** នៅក្នុងទូរលេខនេះគេនិយាយអំពីការដូរប្រជាជនមួយចំនួនទៅកន្លែងផ្សេង តើលោកមាននឹកឃើញអ្វីទេ? លោកមានចងចាំសារណាដែលមានលក្ខណៈប្រហាក់ប្រហែលហ្នឹងទេ ដែលនិយាយអំពីការផ្ទេរប្រជាជនពីតំបន់ព្រៀសាននោះ?

**ផ៖** បាទ ខ្ញុំមិនដែលបានជួបប្រទះដែរ បាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ, ឯកសារ។ ឥឡូវនេះ ខ្ញុំចូលទៅទូរលេខមួយទៀត--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកចៅក្រមបញ្ជាក់អំពីលេខនៃឯកសារនេះម្តងទៀត អ្នកបកប្រែបកអត់ទាន់។

[០៩:៣៤:១៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ឯកសារនេះគឺលេខ E3/898 ERN ជាភាសាខ្មែរ 00020903, ជាភាសាបារាំង 00335194, ជាភាសាអង់គ្លេស 00183626។ ទូរលេខនេះ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ផ្ញើជូនមន្ទីរ ៨៧០ ជាទីគោរពស្នេហា ហើយផ្ញើដោយឈ្មោះ សែ។ តើលោកអាចបញ្ជាក់បានទេ អំពីឈ្មោះ សែ ដែលជាអ្នកផ្ញើ ហើយនិងអ្នកទទួលនេះ? តើអ្នកទទួលជា ប៉ុល ពត មែនទេ ដែលយើងហៅថាមន្ទីរ ៨៧០ ជាទីគោរពស្នេហា? ហើយចុះឈ្មោះ សែ អ្នកផ្ញើទូរលេខនេះជាអ្នកណាដែរ?

**លោក នង សុផង់៖**

**ឆ៖** បាទ ទូរលេខនេះមិនមែនជូនមន្ទីរទេ គេដាក់ "គោរពជូនគណៈ៨៧០"។ គណៈហ្នឹងគឺមិនសំដៅលើបុគ្គលណាទេ គេ អ្នកណាដែលជាគណៈហ្នឹង គេជូនទាំងអស់គ្នាហ្នឹង។ ហើយ សែ ក៏ដូចជាសារទូរលេខមុនដែលខ្ញុំធ្លាប់ឃើញដែរ គឺជាលេខាភូមិភាគថ្មីមួយដែលបានរៀបចំឡើង គឺនៅហៅថាភូមិភាគ៨០១ បាទ។

[០៩:៣៦:២៨]

**ស៖** តើភូមិភាគហ្នឹងជាភូមិភាគស្វយ័ត ដែលផ្ញើជូនទៅគណៈ៨៧០ ហ្នឹងដោយផ្ទាល់មែនទេ?

**ឆ៖** បាទ គ្រប់ភូមិភាគ គេសុទ្ធតែមានសិទ្ធិឡើងត្រង់មក៨៧០ បានបាទ។ ឯតំបន់ស្វយ័តពីមុនដែលមាន ក្នុងនេះគឺមានខេត្តសៀមរាប ឧត្តរមានជ័យ ហើយនិងព្រះវិហារ ហ្នឹងកាលពីមុន គេឡើង *ឌីរិច* មកខាងមជ្ឈិម។ តែដល់មានការរៀបចំថ្មី ដែលមានឈ្មោះ សែ ជាលេខា ដូច្នេះភូមិ -- តំបន់សៀមរាប ឧត្តរមានជ័យ ហើយនិងព្រះវិហារ មិនមានលក្ខណៈជាតំបន់ស្វយ័តទៀតទេ។ មានបញ្ហាអ្វីគេត្រូវឆ្លងកាត់ភូមិភាគ៨០១ បាទ គឺឈ្មោះ សែ ហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយពីខ្លឹមសារនៃទូរលេខនេះ។ ក្នុងឯកសារនេះសរសេរថា "ស្នើសុំចាត់តាំងស្រុកសៀមរាប និងស្រុកបន្ទាយស្រីជាស្រុកតែមួយវិញ មូលហេតុស្រុកនេះនៅជាប់គ្នា។ ឯស្រុកសៀមរាប ប្រជាជនមាន៤០.០០០នាក់ តែភាគច្រើនជាប្រជាជនថ្មី ត្រូវបែងចែកតាមស្រុកមួយចំនួនទៀត។ ឯស្រុកបន្ទាយស្រី មានប្រជាជន២០.០០០នាក់ ភាគច្រើនជាប្រជាជនចាស់។ បើចាត់តាំងតែស្រុកមួយ ទើបឯកភាពគ្នារវាងប្រជាជនចាស់ និងប្រជាជនថ្មី ងាយស្រួលក្នុងការគ្រប់គ្រង។ ចំពោះស្រុកបន្ទាយស្រី ដីស្រែតិច ហើយដីមិនត្រូវមានជីវជាតិ ស្រុកសៀមរាបមានដីតាមមាត់ទន្លេ ភាគច្រើនជាដីខ្លាញ់មានជីវជាតិ។ ចាត់តាំងដូច្នេះទើបប្រមូលកម្លាំងវាយដីខ្លាញ់បានអស់ ហើយម្យ៉ាងយើងជ្រើស

រើសកម្មាភិបាល ចង់ប្រមូលកម្លាំងកម្មាភិបាលវាយឲ្យបានខ្លាំងផង"។ តើលោកមានចាំថា លោកបានបកប្រែទូរលេខនេះទេ? ឬក៏បកប្រែទូរលេខណាដែលមានខ្លឹមសារប្រហាក់ប្រហែលហ្នឹង ដែលធ្លាប់បកប្រែនោះ?

**ឆ៖** បាទ នេះគឺក្រុមខ្ញុំអ្នកបកប្រែហើយសារហ្នឹងបាទ។ អ៊ីចឹងគឺ -- ឯទូរលេខដែលប្រហាក់ប្រហែលនឹងហ្នឹង មិនមាន ដែលខ្ញុំមិនមានដែល មានស្រុកណាដែលគេបង្រួបរួមគ្នា ស្រុកពីរធ្វើជាស្រុកមួយអ៊ីចឹងទេបាទ។ មិនមានទាល់តែសោះតែម្តង។ មានតែមួយហ្នឹងទេ។

[០៩:៤០:៣២]

**ស៖** ខ្ញុំសូមបញ្ជាក់ថា ទូរលេខនេះត្រូវបានចម្លងជូន អ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ, ឯកសារ។ ឥឡូវនេះ ខ្ញុំសូមចូលទៅទូរលេខមួយទៀត ដែលទូរលេខនេះធ្លាប់បានបង្ហាញជូនហើយដោយអ្នកស៊ើបអង្កេតនៃការិយាល័យចៅក្រមស៊ើបអង្កេត។ ហើយខ្ញុំមានឯកសារក្រដាសដែលត្រូវផ្តល់ជូនសាក្សី។

ទូរលេខនេះ ជាទូរលេខ១៥ ដែលមានលេខ E3/154 ERN ជាភាសាខ្មែរ 00008494 ទៅដល់ 95, បារាំង 00386260, អង់គ្លេស 00008495 ហើយមានឯកសារមួយទៀតដែលមានលេខ ERN 00185064 ទៅដល់ 65។ ទូរលេខនេះ យើងបាននិយាយកាលពីម្សិលមិញរួចហើយ ហើយបង្ហាញអំពីការមិនឯកភាពគ្នារវាងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ។ ទូរលេខនេះផ្ញើជូនសមមិត្តបងប៉ុល ជាទីស្នេហា ហើយអ្នកចុះហត្ថលេខាគឺឈ្មោះ ឆុន។ ឯកសារនេះ គឺបង្ហាញពីការមិនឯកភាពគ្នារវាងភូមិភាគពីរ គឺភូមិភាគបូព៌ាត្រូវតែដកចេញនូវជនជាតិអ៊ីស្លាម។ ហើយមានបញ្ហាពាក់ព័ន្ធទៅនឹងការទទួលប្រជាជនអ៊ីស្លាមដែលត្រូវបានជម្លៀសនេះ។

ភាគីបានសួរលោកពាក់ព័ន្ធនឹងឯកសារនេះរួចហើយ។ ហើយខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាចាំបាច់ផ្ញើទូរលេខនេះជូន បងប៉ុល? តើនៅភូមិភាគទាំងហ្នឹងគេមិនអាចដោះស្រាយដោយខ្លួនឯងផ្ទាល់ទេ ឬក៏យ៉ាងណា ចាំបាច់អីទៅផ្ញើជូន បងប៉ុល ទៅវិញនោះ?

[០៩:៤៣:២៣]

**ឆ៖** បាទ ទូរលេខនេះគឺជាការមិនឯកភាពគ្នារវាងថ្នាក់ដឹកនាំបូព៌ា និងឧត្តរ មិនមែនពាយ័ព្យទេបាទ។ ខ្លឹមសារហ្នឹង គឺឧត្តរបាទ។ ហើយមូលហេតុដែលគេផ្ញើជូន បងប៉ុល ហ្នឹង គឺខ្ញុំមើលទៅតាមខ្លឹមសារទេ គឺថា ពីព្រោះអ្វីក៏ដោយគឺ បងប៉ុល ហ្នឹងគាត់ជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបង្អស់។ អ៊ីចឹង

អ្វីៗដែលបានពិភាក្សាគ្នាហើយ បែរជាមិនឯកភាពគ្នាទៅវិញ។ ដូច្នេះគឺគេមិនបានអាចដោះស្រាយបាន គឺមានតែរាយការណ៍មកអ្នកណាដែលធំជាងគេបង្អស់ ដែលអាចសម្រួលបញ្ហានេះបាន។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំ។ តើអាចទេ ថាមានការទំនាក់ទំនងគ្នាពីភូមិភាគមួយ ទៅភូមិភាគមួយ? ឬមួយក៏ការទំនាក់ទំនងរវាងភូមិភាគមួយទៅភូមិភាគនោះ ត្រូវតែឆ្លងកាត់តាមមន្ទីរ ៨៧០? តើលោកយល់សំណួរខ្ញុំទេ?

[០៩:៤៥:០៥]

**ឆ៖** ខ្ញុំមិនដឹងនូវការទំនាក់ទំនងគ្នា រវាងពីភូមិភាគមួយទៅភូមិភាគមួយនោះទេ។ ហើយក៏មិនដឹងថា អ្វីៗទាំងអស់បើត្រូវទាក់ទងពីភូមិភាគមួយទៅភូមិភាគមួយ គឺត្រូវតែឆ្លង៨៧០សិននោះទេ ព្រោះខ្ញុំមិនដែលមានដឹងអំពីការទាក់ទងនៅមូលដ្ឋានអ្វីទាល់តែសោះតែម្តង។

**ស៖** ខ្លឹមសារនៃទូរលេខនេះ ពន្យល់ថា មានគោលការណ៍មួយ ដែលត្រូវបានបង្កើតឡើងគឺថា ត្រូវតែបំបែកជនជាតិអ៊ីស្លាម តើលោកធ្លាប់ឮគេនិយាយអំពីសារ ដែលលើកឡើងអំពីភាពចាំបាច់ក្នុងការបំបែកជនជាតិចាមទេ?

**ឆ៖** បាទ តាមខ្ញុំពិនិត្យ ដែលខ្ញុំធ្លាប់បកប្រែសារទាំងអស់ គឺមិនមានភូមិភាគណា តំបន់ណាដែលលើកពីរឿងបំបែកប្រជាជនអ៊ីស្លាមទេ គឺមានតែបូព៌ាមួយហ្នឹងបាទ។ ហើយក៏មានតែទូរលេខហ្នឹងមួយគត់តែម្តង ដែលខ្ញុំបានឃើញ តែមិនមែនជាទិសរបស់ខ្ញុំទេ ទើបតែអស់លោក លោកស្រីជូនខ្ញុំបានខ្ញុំឃើញនេះ កុំអីខ្ញុំមិនដឹងទេបាទ។

**ស៖** ខ្ញុំដូចជាមិនយល់ចំពោះការពន្យល់របស់លោកនេះ។ មានន័យថា លោកមិនចាំថា មានទូរលេខដែលនិយាយអំពីចាមទេ មាននិយាយតែពីជនជាតិអ៊ីស្លាម តើលោកចង់មានន័យអ៊ីចឹងទេ?

[០៩:៤៧:៣៨]

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ ពីព្រោះសារដែលខ្ញុំបក មិនដែលមានទាក់ទងនឹងរឿងអ៊ីស្លាមទេ ក៏ប៉ុន្តែន័យពាក្យអ៊ីស្លាម និងចាម គឺដូចតែគ្នាទេបាទពាក្យហ្នឹង។

**ស៖** បាទ សូមបញ្ជាក់ថា នៅក្នុងឯកសារនេះ គឺថាមានអ្នកទទួលនោះគឺ មានបងប៉ុល, បងនួន, បងខៀន, បងយ៉េម ហើយមានជាឯកសារផងដែរ។ ឥឡូវនេះ ខ្ញុំសូមចូលទៅទូរលេខមួយចំនួនទៀត ដែលមានពាក់ព័ន្ធទៅនឹងបញ្ហា ដែលយើងទើបតែលើកឡើងអម្បាញ់មិញនេះ គឺបញ្ហាទំនាក់ទំនងគ្នារវាងភូមិភាគមួយទៅភូមិភាគមួយ។ ទូរលេខដំបូងនោះគឺមានលេខ E3/1221 ខ្ញុំមានឯកសារក្រដាស

សម្រាប់ផ្តល់ជូនសាក្សី។ ទូរលេខនេះ លេខ១៤ ERN ជាភាសាខ្មែរ 00001263, បារាំង 00623007, អង់គ្លេស 00776988។ ទូរលេខនេះផ្ញើជូនអង្គការជាទីគោរពស្នេហា ទូរលេខនេះចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧។ អ្នកផ្ញើនោះគឺ ម-៤០១។ ទូរលេខនេះបញ្ជាក់អំពីការចាប់ខ្លួនមនុស្ស២៤នាក់ ដោយពួកឈ្លបនៃសហករណ៍ព្រៃគ្រី ស្ថិតនៅក្នុងស្រុកកំពង់ហ្លួង តំបន់កំពង់ឆ្នាំង។ អ្នកសរសេរទូរលេខនេះបញ្ជាក់ថា ពួកនេះមានគោលបំណងរត់ចេញពីភូមិភាគឧត្តរ ហើយអ្នកផ្ញើនេះគឺចង់បានការពន្យល់ ហើយសុំយោបល់ពីអង្គការ គឺកថាខណ្ឌ៤ "រយៈពេលវារត់ចំនួន១២០ថ្ងៃហើយ ដូច្នេះសូមស្នើអង្គការទាក់ទងទៅខាងឧត្តរ តើមានមនុស្សរត់មែនឬក៏ទេ? ហើយអង្គការមានវិធានការយ៉ាងណាដែរ?" ខ្ញុំមានសំណួរស្រដៀងគ្នាទេ។ តើលោកធ្លាប់ឃើញទូរលេខមួយដែលថាមានខាងភូមិភាគស្នើទៅមន្ទីរ៨៧០ ឬក៏អង្គការសូមព័ត៌មានពីភូមិភាគមួយទៀត? តើលោកដឹងទេ ថាតើការធ្វើហ្នឹងគឺជាការ -- ជាទម្លាប់ធម្មតាទេនៅសម័យនោះ?

[០៩:៥២:០១]

**ឆ៖** បាទ ខ្ញុំមិនសូវយល់ដែរសារហ្នឹង គឺពីព្រោះមិនមែនជាទិសដែលខ្ញុំបកប្រែ ហើយជាទម្លាប់តាមមើលគឺគេគ្មានមធ្យោបាយទាក់ទងគ្នាទៅ -- ពី ម-៤០១ នេះទៅខាងភូមិភាគឧត្តរ។ អ៊ីចឹងហើយបានជាគេជូនសារហ្នឹង ដើម្បីសួរមកខាងអង្គការនេះ។ អង្គការហ្នឹងគឺសំដៅ ៨៧០ ហ្នឹងហើយ។ ហ្នឹងគឺដូចជាទូរលេខមុនហ្នឹងដែរ គឺថា ពេលណាដែលគេមិនមានមធ្យោបាយទាក់ទងផ្ទាល់ទៅកន្លែងហ្នឹងបាន គេត្រូវតែឡើងមកតាមរយៈអង្គការ៨៧០ ហ្នឹងហើយបាទ។

**ស៖** ប៉ុន្តែតាមការអនុវត្តនៅសម័យហ្នឹងលោកសាក្សី ភូមិភាគនីមួយៗមានផ្នែកតេឡេក្រាមរបស់ខ្លួនដោយឯករាជ្យ គឺថាភូមិភាគមួយហ្នឹងតើមានផ្នែកបកប្រែតេឡេក្រាម និងបញ្ជូនតេឡេក្រាមរៀងៗខ្លួនឬក៏យ៉ាងម៉េច? បើតាមការអនុវត្តនោះ គឺថាតើភូមិភាគមួយនោះអាចផ្ញើទូរលេខទៅភូមិភាគផ្សេងទៀតបានទេ?

**ឆ៖** បាទ គ្រប់ភូមិភាគ សុទ្ធតែមានតេឡេក្រាម មានកន្លែងវាយទូរលេខ កន្លែងបកប្រែទូរលេខគឺឯករាជ្យរបស់គេ គ្រប់ភូមិភាគគេមាន។ ក៏ប៉ុន្តែការទំនាក់ទំនងរវាងភូមិភាគមួយទៅភូមិភាគមួយ ខ្ញុំមិនដឹងថា គេមានសិទ្ធិទាក់ទងគ្នាដែរឬទេ នេះខ្ញុំមិនដឹងគោលការណ៍រៀបចំរបស់អង្គការយ៉ាងម៉េចទេបាទ។

[០៩:៥៤:៤៨]

**ស៖** បាទ អ្វីដែលលោកនិយាយហ្នឹងគឺថាតាមការអនុវត្តនោះអាច ក៏ប៉ុន្តែជាក់ស្តែងនោះលោកមិនដឹងថា មានការណែនាំជាក់លាក់យ៉ាងម៉េច ដែលគេណែនាំទៅភូមិភាគ ទាក់ទងនឹងលទ្ធភាពក្នុងការទាក់ទងរវាងភូមិភាគនិងភូមិភាគនោះទេ។

បាទ ខ្ញុំសូមបញ្ជាក់ថា ទូរលេខនេះ ត្រូវបានផ្ញើ អ៎! ចម្លងជូនទៅ អ៊ំ ដូច្នេះ គឺ ប៉ុល ពត ហើយមួយទៀត អ៊ំនួន , បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ និងឯកសារ។ បាទ សូមលើកឧទាហរណ៍ ទូរលេខមួយទៀត គឺថា គឺឯកសារ E3/254។ បាទ គឺខ្ញុំមានឯកសារជាក្រដាសដើម្បីផ្តល់ជូនទៅសាក្សី។ ឯកសារអម្បាញ់មិញនេះ គឺឯកសារ E3/254។ បាទ ឯកសារ E3/254 នោះ គឺថាមានលេខ ERN ដូចខាងក្រោមគឺថា ERN ជាភាសាខ្មែរគឺថា 00020972, ជាភាសាបារាំង 00504013, អង់គ្លេស 00377840។ បាទ គឺជាទូរលេខដែលផ្ញើជូនទៅ បងស៊ី ហើយនិង ប៉ អ៎! ពក ហើយចុះហត្ថលេខា ម-៨៧០ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨។ ជាតេឡេក្រាមខ្លីបំផុត ខ្ញុំសូមអាន “បាទ សូមជូនជាព័ត៌មានភូមិភាគបូព៌ាបានផ្ញើសេចក្តីរាយការណ៍ពីសកម្មភាពខ្មាំងនៅមុខកំពូលមួយច្បាប់ មកជូនមន្ទីរដោយសុំឲ្យមន្ទីរផ្ញើជូនទៅខាងបង។ សូមតាមដានសភាពការណ៍នេះ ហើយនិងវិធានការ តាមសភាពការណ៍ជាក់ស្តែង ដោយទាក់ទងមកជាមួយខាងមុខកំពូលផង”។ បាទ ដូច្នេះ យើងឃើញឧទាហរណ៍មួយដែលសុំឲ្យទៅភូមិភាគផ្ញើរបាយការណ៍ ឬក៏រាយការណ៍ទៅភូមិភាគមួយទៀត។ តើលោកអាចបញ្ជាក់ទេថា បងស៊ី ហើយនិង បងពក នោះ ជាអ្នកណា បើតាមលោកដឹង?

[០៩:៥៧:២៩]

**ឆ៖** បាទ សារនេះ ពុំមែនជាសារទូរលេខទេ ពីព្រោះវាគ្មានក្បាល គ្មានលេខរៀង គ្មានអីនោះទេ។ ឯចំពោះជូនទៅនរណា គឺថាបានផ្ញើជូនទៅបងស៊ី។ ស៊ី ហ្នឹង គឺតាមខ្ញុំចាំ ដូចគាត់នៅសម័យហ្នឹងគឺគាត់ជាថ្នាក់ដឹកនាំភូមិភាគមួយដែរ។ ស៊ី នោះ ដូចជាខាង១បស្ចិម តាមខ្ញុំរំឭកឡើងវិញ។ ឯ បងពកនេះ គឺជាលេខាភូមិភាគឧត្តរ បាទ។

**ស៖** តើអ្នកណាជាចុះជាអ្នកហត្ថលេខា ម-៨៧០ តើលោកធ្លាប់ឃើញហត្ថលេខាគេចុះ ម-៨៧០ នោះទេ? ហើយឧទាហរណ៍ដូច ប៉ុល ពត អី គាត់ចុះហត្ថលេខាហ្នឹង ដាក់ថា ម-៨៧០ ហ្នឹងទេ គាត់ធ្លាប់ធ្វើអីចឹងទេ?

**ឆ៖** បាទ “ម” នោះ គឺក្នុងនាមថា “មន្ទីរ” ហើយបាទ។ សម័យនោះ គឺឲ្យ “ម” ពីមុខ គឺ “មន្ទីរ”។ អ៊ីចឹង គឺបានន័យថា អ្នកដែលចុះហត្ថលេខានៅលើសារលិខិតនេះ គឺមន្ទីរ៨៧០ ហ្នឹងហើយ

ដែលយើងចំណាំឃើញហើយថា ចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងខៀវ, ហើយមន្ទីរ។ មន្ទីរ បានន័យថា អ្នកដែលទទួលខុសត្រូវមន្ទីរ៨៧០ ហ្នឹងហើយ ដែលជាអ្នកចុះហត្ថលេខាហ្នឹង។

[១០:០០:០០]

**ស៖** បាទ ខ្ញុំយល់លោកសាក្សី ក៏ប៉ុន្តែទូរលេខនេះផ្ញើចេញពី ម-៨៧០ តើលោកដឹងដែរឬទេថា តើអ្នកណាជាបុគ្គលតំណាងឲ្យ ម-៨៧០ នោះ? តើអ្នកណាជាអ្នកសរសេរទូរលេខនេះ ហើយនិងផ្ញើទូរលេខនេះចេញទៅដោយប្រើឈ្មោះថា ម-៨៧០ នេះ ព្រោះថា ម-៨៧០ មិនមែនជាមនុស្សម្នាក់នោះទេ?

**ឆ៖** បាទ បើដែលឯកសារដែលខ្ញុំបានឃើញមួយកំភ្លូសធំនេះ គឺខ្ញុំអាចយល់ ហើយបើអស់លោកបែរទៅក្រោយ មើលការប្រជុំអចិន្ត្រៃយ៍ អស់លោកនឹងអាចដឹងថាគណៈអចិន្ត្រៃយ៍លោកបានចាត់តាំងអ្នកណាម្នាក់ដែលជា -- ទទួលខុសត្រូវមន្ទីរនយោបាយ ឬមួយក៏មន្ទីររដ្ឋាភិបាលរបស់៨៧០។ ហ្នឹងអស់លោកស្រាវជ្រាវតាមហ្នឹងទៅឃើញហើយ។ ការប្រជុំអចិន្ត្រៃយ៍ថ្ងៃទី១០ ឬទី៩ ទេលោកស្រាវជ្រាវឯកសារហ្នឹងឃើញហើយ អ្នកណាទទួលផ្នែកអី អ្នកណាទទួលផ្នែកអី។ មិនចាំបាច់ខ្ញុំបកស្រាយអីវែងឆ្ងាយទេ។

[១០:០១:៥០]

**ស៖** បាទ យើងនឹងពិនិត្យមើលកំណត់ហេតុនៃកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍ហ្នឹង ប៉ុន្តែអ្វីដែលសំខាន់នៅថ្ងៃនេះគឺថា សក្ខីកម្មរបស់លោក បើតាមការចងចាំរបស់លោកនោះ តើលោកជាបុគ្គល តើលោកអាច -- លោកសាក្សី តើលោកអាច -- បើថាមានគំនិតអ្វីមួយ តើលោកដឹងថា តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការតំណាងឲ្យមន្ទីរ ម-៨៧០ នេះ?

**ឆ៖** បាទ បញ្ហានេះហើយដែលខ្ញុំ ខ្លួនខ្ញុំផ្ទាល់ក៏មិនដឹងថានរណាជា ម-៨៧០, នរណាជាមន្ទីរ -- បើឃើញឯកសារចាត់តាំងគឺថា មានម្នាក់ហ្នឹង គឺឈ្មោះ ឌឿន គាត់ទទួលជាមន្ទីរខាងមន្ទីរនយោបាយរបស់៨៧០, ឯម្នាក់ទៀតគឺ ប៉ង់ ជាមន្ទីររដ្ឋាភិបាលបាទ។ អ៊ីចឹងមិនដឹងជាពីរនាក់ហ្នឹងនរណាដែលមានសិទ្ធិដាក់ថា ម-៨៧០ នោះទេ។ អ្វីដែលខ្ញុំមិនច្បាស់បានខ្ញុំក៏មិនបកស្រាយបាទ គឺខ្ញុំក៏មិនដឹងដែរ។

**ស៖** តើលោកដឹងថា ឌឿន ហើយនិង ប៉ង់ ហ្នឹងរងគ្រោះពីការបោសសម្អាតដែរឬទេ? តើលោកដឹងថាពួកគាត់ត្រូវគេចាប់ខ្លួន? ហើយតើពួកគាត់ហ្នឹងត្រូវបានជំនួសដោយអ្នកណាទេ?

**ឆ៖** ខ្ញុំ ចំពោះឈ្មោះ ប៉ង់ ដែលធ្លាប់ជាមេដឹកនាំអប់រំពីលើខ្ញុំដែរ គឺខ្ញុំដឹងថាគាត់បាត់ខ្លួននៅមុនដែលថ្ងៃ៧ មករា។ ឯឈ្មោះ ឌឿន គឺខ្ញុំមិនដឹងថាគាត់បាត់ខ្លួនពេលណាអីពេលណា គឺអត់ដឹងទេបាទ។

[១០:០៤:២១]

**ស៖** តើលោកដឹងថាអ្នកណាជាអ្នកជំនួស ប៉ង់ ដែរឬទេ?

**ឆ៖** បាទ ព្រោះដល់ពេលដែលវាកៀកពេលដែលវានឹងថ្ងៃ៧ មករា ហើយ ដូច្នេះខ្ញុំមិនដឹងជាខាងអង្គការរៀបចំនរណាជំនួស ប៉ង់ ហ្នឹងទេបាទ។

**ស៖** បាទ ឥឡូវខ្ញុំសូមចូលទៅទូរលេខផ្សេងទៀត។ បាទ ជាដំបូងគឺថាទូរលេខ E3/1070 -- ខ្ញុំមាន អ៊ំ! 1077 (សូមទោស) បាទ ខ្ញុំសូមផ្តល់ឯកសារជាក្រដាសទៅសាក្សី។

បាទ គឺជាទូរលេខដែលបានបង្ហាញជូនលោកហើយហើយលោកសាក្សី បើខ្ញុំមិនច្រឡំទេនោះ។ បាទ គឺជាតេឡេក្រាមលេខ ៣២៤ ដែលចុះហត្ថលេខាជា សែ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ នៅក្នុងទូរលេខនេះ នៅខាងលើខាងឆ្វេងដៃមានចំណារមួយ តើលោកឃើញចំណារនៅខាងលើខាងឆ្វេងនេះដែរឬទេ? ហើយលោកអាចអានចំណារហ្នឹងជូនតុលាការបានទេ។

**ឆ៖** បាទ ចំណារហ្នឹងដាក់ថា "អ៊ំនួន" បាទ។

**ស៖** បាទ សូមអរគុណ។ ទូរលេខនេះគឺជូនទៅគណៈ៨៧០ ជាទីស្នេហា គឺជារបាយការណ៍លើស្ថានភាពមួយចំនួនទាក់ទងទៅនឹងស្ថានភាពខ្មាំងតាមព្រំដែនថៃ និងលាវ។ គឺថាជាការបូកសរុបនៃស្ថានភាពប្រជាជន ហើយនិងការ -- និងទិន្នផលកសិកម្ម។ ខ្ញុំសូមនិយាយអំពីកថាខណ្ឌ៣ នៃឯកសារនេះ ដែលនិយាយដូចតទៅនេះ៖

[១០:០៦:៥៨]

"ស្ថានភាពខ្មាំងនៅក្នុងគ្មានអ្វីប្រែប្រួលធំដុំទេ ជាសភាពធម្មតា។ យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត ហើយដែលវាប្រឆាំងបដិវត្តន៍យើងទាំងចំហក្តី ទាំងសម្ងាត់ក្តី។ ដោយយើងកាន់តែមានបង្អែករឹងមាំលើប្រជាជន ពិសេសប្រជាជនវណ្ណៈមូលដ្ឋាន គេកាន់តែឃើញមិត្តសត្រូវយ៉ាងច្បាស់។ នៅក្នុងតំបន់១០៣ យើងបានធ្វើដំណើរការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងដែលយើង -- យើងក៏បានផ្អែកលើប្រជាជនហើយធ្វើដំណើរការបោស -- ធ្វើដំណើរការបានល្អ ខ្មាំងវាងើបក្បាលឡើងមិនរួចក៏មកពីកម្លាំងប្រជាជនខ្លាំង ហើយកម្លាំងខ្មាំងនេះសង្កត់ៗវាជាប់ និងបោសសម្អាតសម្រិតសម្រាំងវាជាប់។ យើងបានជ័យជម្នះលើខ្មាំងទាំងនេះ តាំងពីដើមរហូតទល់ឥឡូវ ការបោសសម្អាតខ្មាំងនៅតំបន់១០៣ នេះជា មានការ -- រីឯប្រជាជនមានការរីករាយជាអតិបរមា"។ តើនៅតំបន់១០៣ នេះ ហើយនៅនេះ ពាក្យថា "បោសសម្អាត" នេះមានន័យយ៉ាងម៉េចដែរ?

[១០:០៨:២៩]

**ឆ៖** បាទ តំបន់១០៣ គឺជាតំបន់ស្វយ័ត ដូចខ្ញុំបានជម្រាបហើយ គឺជាខេត្តព្រះវិហារ ឥឡូវបានចូលមកការគ្រប់គ្រងរបស់ភូមិភាគ៨០១ ហើយបាទ។ ឯពាក្យទាំង "បោសសម្អាត" នេះខ្ញុំបានសរសេរក្នុងការពន្យល់លោកក្នុងអង្គចៅក្រមស៊ើបអង្កេតហើយ។ ខ្ញុំប្រើពាក្យថា "ប្រហែល" តាមខ្ញុំយល់អានេះការបោសសម្អាត គឺខ្ញុំមិនបានទៅបោសសម្អាតដូចគេ ហើយក៏មិនបានយល់ពីអង្គការណែនាំពីរឿងពាក្យ "បោសសម្អាត" ហ្នឹងទេ។ តាមន័យត្រង់ដែលយើងយល់ ន័យត្រង់របស់ពាក្យ "បោសសម្អាត" គឺថាធ្វើម៉េចឱ្យវាស្អាត។ ប៉ុន្តែបើន័យអនុវត្តជាក់ស្តែងនៃការគ្រប់គ្រងវិញ នៅក្នុងរបបណាក៏ដូចរបបណាដែរ គឺមានន័យថា "គេបានដកចេញនូវពួកដែលប្រឆាំងគេ" បាទ នេះគឺក្នុងន័យហ្នឹង។ អ្នកណាដែលប្រឆាំងក្នុងរបបគេ គឺគេបានបោសសម្អាតបាទ។

[១០:១០:០២]

**ស៖** បាទ ដូច្នេះបើខ្ញុំមិនច្រឡំទេនោះ គឺថាចំពោះលោកពាក្យ "បោសសម្អាត" នេះ ពាក្យ "កម្ទេច" ពាក្យ "សម្អាត" ឬក៏ពាក្យ "ធ្វើឱ្យបរិសុទ្ធ សម្រិតសម្រាំង" ហ្នឹង ពាក្យទាំងអស់នេះមានន័យស្មើគ្នា ឬៗក៏ថាគ្រាន់តែមានន័យថា គេដកមនុស្សម្នាក់ចេញ? ហើយតើគេដកហ្នឹងយកទៅធ្វើអី?

**ឆ៖** បាទ នេះគឺលោកឱ្យពន្យល់ ខ្ញុំក៏សូមពន្យល់ចុះ។ តាមន័យត្រង់ដែលខ្ញុំយល់ដឹងបាទ តែការបកស្រាយទៅខុសត្រូវយ៉ាងណាក៏សូមអង្គសវនាការពិនិត្យ ថាតើពិត ឬមិនពិត។ ពាក្យបីនេះ មានពាក្យ "សម្រិតសម្រាំង បោសសម្អាត និងកម្ទេច"។ ពាក្យ "បោសសម្អាត" អ៎! ពាក្យ "សម្រិតសម្រាំង" នេះន័យរបស់វា ន័យត្រង់គឺថា គេធ្វើឱ្យវាបរិសុទ្ធ អានេះជា ដូចលោកបានមានប្រសាសន៍អំមិញហើយ ខ្ញុំឯកភាព។ នេះជាន័យត្រង់។ ឯន័យ "សម្រិតសម្រាំង" ក្នុងន័យអនុវត្តពេលនោះ គឺមានន័យដែលខ្ញុំយល់ទេ គឺថាក្នុងការកសាងកម្លាំង គឺសំដៅឱ្យការជ្រើសរើសហ្នឹងដោយប្រយ័ត្នប្រយែង ឱ្យច្បាស់លាស់ត្រូវពិនិត្យតាំងពីប្រវត្តិរូប ពិនិត្យតាំងពីសីលធម៌រស់នៅ មុននឹងឱ្យគេទៅទទួលដឹកនាំការងារអ្វីមួយ និងពិនិត្យការងារជាបន្តបន្ទាប់របស់គេ ដើម្បីឱ្យគេកសាងជាគណៈកម្មការ ឬទទួលខុសត្រូវអង្គភាពណាមួយ។ អាហ្នឹងគឺគេប្រើពាក្យ ក្នុងសំដៅក្នុងការកសាងកម្លាំង។

[១០:១២:៤៣]

ឯពាក្យ "បោសសម្អាត" ន័យត្រង់ខ្ញុំបានពន្យល់លោកហើយ គឺថាវាធ្វើស្អាត។ ឯន័យអនុវត្ត គឺមានន័យតាមខ្ញុំយល់ គឺគេដកចេញនូវសមាសភាពទាំងឡាយណា ដែលប្រឆាំងនឹងរបបគេ។ នេះជាន័យ

អនុវត្ត។

ឯពាក្យ “កម្ទេច” គឺមានន័យជ្រៅ ហើយមានន័យធ្ងន់ជាងពាក្យ “សម្រិតសម្រាំង” ធ្ងន់ជាងពាក្យ “បោសសម្អាត” គឺ “កម្ទេច” ន័យត្រង់របស់វា គឺថាធ្វើឲ្យខ្ទេច។ ឯក្នុងសម័យនោះ គឺប្រើពាក្យកម្ទេចបានទូទៅ។ ឧទាហរណ៍ថា យើងកម្ទេចរថក្រោះខ្មាំងបានមួយគ្រឿង គឺបានន័យថា យើងធ្វើឲ្យសម្ភារៈហ្នឹងវាគាំង វាលែងប្រើប្រាស់បានហើយ បាទ។ អានេះគឺន័យកម្ទេចសម្ភារៈ។ ឯកម្ទេចចំពោះមនុស្សវិញ គឺមានន័យធ្ងន់ណាស់ គឺសម្លាប់តែម្តងបាទ។ បាទ សូមជម្រាបជូនអង្គសវនាការ តាមដែលស្មារតីដែលខ្ញុំយល់បាទ តែប៉ុណ្ណឹងតែបាទ។

[១០:១៤:៣០]

**សៈ** បាទ សូមអរគុណ។ បាទ ឥឡូវខ្ញុំសូមចូលទៅប្រធានបទថ្មី ព្រោះថាពេលវេលាកាន់តែទៅមុខ។ មានឯកសារមួយចំនួនទៀត គឺថាទាក់ទងនឹងបញ្ហាអម្បាញ់មិញនេះ គឺថាភាគីផ្សេងទៀតនឹងមានសំណួរសួរច្រើន។ បាទ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយបញ្ហាដែលមួយ ដែលបានលើកឡើងកាលពីម្សិលមិញ គឺថាទាក់ទងនឹងទំនាក់ទំនងជាមួយនឹងបរទេស។ តើលោកសាក្សី លោក -- ព្រោះថាខ្ញុំមិនយល់មិនច្បាស់ កាលពីម្សិលមិញនេះ តើមានទូរលេខដែលអាចផ្ញើចេញពីភ្នំពេញទៅបរទេសដែរឬទេ? ហើយនិងមានទូរលេខដែលទទួលពីក្រៅមកដែរឬទេ?

**ឆៈ** បាទ ចំពោះបញ្ហានេះ ខ្ញុំយល់ឃើញថា វាមិនមានទាក់ទិនអ្វីជាមួយការងារខ្ញុំ ហើយក៏ខ្ញុំយល់ឃើញថា ខាងផ្នែកក្រសួងការបរទេសគឺ គាត់ដឹង។ ឯខ្ញុំដឹងមិនច្បាស់។ ហើយក៏ទាក់ទិនជាមួយបរទេសជាមួយខាងផ្នែក ខាងក្រៅ តាមវិធានរបស់តុលាការថា មិនមានលទ្ធភាពចាប់កំហុស ឬដាក់ទោសប្រទេសដែលមានការពាក់ព័ន្ធនៅខាងក្រៅនោះទេ។ អ៊ីចឹងហើយការដែលខ្ញុំលើកគឺអត់មានន័យមានខ្លឹមសារអីទេ ទោះបីគឺ ខ្ញុំដឹងក៏ដោយ ក៏ខ្ញុំមិននិយាយ។ កុំឲ្យខុសពីវិធានរបស់តុលាការបាទ។ បាទសូមអធ្យាស្រ័យបាទ។

[១០:១៦:២៧]

តែបើប្រសិនណាជា អង្គការនេះមានសមត្ថភាពកាត់ទោសពួកបរទេស ដែលមានលូកដៃពាក់ព័ន្ធនៅក្នុងសង្គ្រាមកម្ពុជា។ ខ្ញុំនឹងរីករាយមកធ្វើសក្ខីកម្មទៀត ហើយក៏សុំអស់លោកប្រមូលឯកសារឲ្យបានច្បាស់លាស់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកសាក្សី។ ខ្ញុំគិតថា យើងកំពុងតែប្រាសចាកពីប្រធានបទហើយ។ នេះមិនមែនជាសំណួរដែលខ្ញុំចោទទៅលោកអម្បាញ់មិញទេ។ ឥឡូវនេះ ខ្ញុំសូមផ្តល់ទូរលេខមួយជូនលោកដើម្បីបំភ្លឺសំណួរដែលខ្ញុំចង់សួរទៅលោកនេះ។

បាទ អ៊ីចឹងសូមមន្ត្រីតុលាការផ្តល់ឯកសារនេះទៅដល់សាក្សី។

[១០:១៧:១៧]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ គឺជាទូរលេខ E3/1121 គឺជាទូរលេខចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៧ ផ្ញើជូនដល់បងជាទីគោរពស្នេហា។ ហើយបើតាមមើលទៅ គឺជាទូរលេខដែលផ្ញើពីក្រុងព្យុងយ៉ាង គឺថានៅកូរ៉េខាងជើង ផ្ញើដោយឈ្មោះ យ៉ែម។ កាលណោះ គឺថាយ៉ែម នេះទំនងជាឯកអគ្គរាជទូតកម្ពុជាប្រជាធិបតេយ្យនៅកូរ៉េខាងជើង។ អ៊ីចឹងសំណួរខ្ញុំសាមញ្ញទេ តើលោកធ្លាប់បានទទួលទូរលេខដែលផ្ញើជូនទៅ ប៉ុល ពត ទៅ ម-៨៧០ ហើយដែលបានផ្ញើពីបរទេស គឺថាមកពីស្ថានទូតបរទេស។ ឧទាហរណ៍ ស្ថានទូតចិន ឬក៏កូរ៉េខាងជើង ឬក៏ពីប្រទេសផ្សេងទៀតនោះ។ តើលោកធ្លាប់បានទទួលទូរលេខបែបនេះទេ?

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំមិនសូវច្បាស់ទេ ពីព្រោះការទំនាក់ទំនងទូតពេលហ្នឹងក៏ ពេលដែលរំដោះហើយក៏មានការរៀបចំអ៊ីចឹង -- មានការទាក់ទងដាក់ទូតអ៊ីចឹងមែន។ តែរឿងខ្លឹមសារទូរលេខនេះ គឺបានធ្វើឱ្យខ្ញុំនឹកឃើញថា ជាដំបូងគឺទូរលេខទាំងអស់ហ្នឹង គឺនៅក្នុងក្របខ័ណ្ឌរបស់ក្រុមការងារយើងខ្ញុំទទួលដែរ។ តែដល់ក្រោយមក ពេលដែលខាងបរទេសគេរឹងដៃ រឹងជើង គេមានក្រុមឯកទេសជំនាញរបស់គេហើយក៏ធ្វើនៅក្រសួងការបរទេស។ នេះគឺទូរលេខនេះ ឆ្នាំ៧៧ហើយបាទ។ បាទ គឺដូចលោកបានយល់ហើយ គឺ យ៉ែម ហ្នឹងក៏ដូចក្នុងលោកបានអធិប្បាយអំមិញ គឺថាជាអ្នកធ្វើការប្រចាំស្ថានទូតនៅកូរ៉េខាងជើងបាទ។ ត្រឹមត្រូវហើយបាទ។

[១០:២០:០៤]

**ស៖** បាទ ដូច្នេះមានទំនាក់ទំនង តាមទូរលេខរវាងទីក្រុងភ្នំពេញ ហើយនិងប្រទេសបរទេសមួយចំនួនតាមរយៈស្ថានទូត តើអ៊ីចឹងមែនទេ តើលោកអាចបញ្ជាក់ថាអ៊ីចឹងបានទេ?

**ផ៖** បាទ តាមខ្ញុំដឹងខ្លះៗគឺថា មិនបាច់ទាក់ទងជាមួយស្ថានទូតទេ គឺ ក-១៨ គឺមានក៏មាន

លទ្ធភាពគេបញ្ជូនសារទូរលេខតាមរលកអាកាស ទៅដល់ព្យុងយ៉ាងបានដែរ ជាសញ្ញាទិចៗតា ហ្នឹងអាចឮទៅដល់ឆ្ងាយ ដល់កូរ៉េបាន។

**ស៖** តើមន្ទីររបស់លោកនុ៎ង ធ្លាប់បានបកប្រែឯកសារ ទាក់ទងនឹងឯកសារពាណិជ្ជកម្ម ឧទាហរណ៍ទាក់ទងនឹងការនាំចេញ នាំចូលសម្ភារៈជាដើមនោះ នាំចេញទៅប្រទេសក្រៅ ឬក៏នាំចូលមកប្រទេសខ្មែរយើង?

**ឆ៖** បាទនៅក្នុងកន្លែងខ្ញុំគ្មានទេបាទ មិនដែលបានបកទេ។

[១០:២១:៣៨]

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វី ដែលលោកបានលើកឡើងកាលពីម្សិលមិញ ទាក់ទងទៅនឹងលោក ខៀវ សំផន។ នៅពេលដែលលោក ខៀវ សំផន ជាអ្នកទទួលឯកសារដោយផ្ទាល់ ឬក៏គេដាក់ថា គាត់ជាអ្នក -- គេចម្លងជូនឯកសារទៅគាត់។ តើគេកំណត់អត្តសញ្ញាណ ខៀវ សំផន យ៉ាងម៉េច? គឺចង់និយាយថា គេហៅ ខៀវ សំផន យ៉ាងម៉េចដែរ នៅពេលដែលគេចម្លងជូនគាត់ ឬក៏ពេលគេផ្ញើទូរលេខទៅគាត់ផ្ទាល់នោះ?

**ឆ៖** បាទ លោក ខៀវ សំផន គឺគេជូនបងហែម អ៊ីចឹងតែម្តងបាទ។ ហែម ហ្នឹងគឺលោក ខៀវ សំផន ហើយបាទ។

**ស៖** តើគាត់មានឈ្មោះហៅក្រៅផ្សេងទៀតទេ គាត់មានឈ្មោះជាលេខកូដអីទេ មានរបៀបផ្សេងសម្រាប់កំណត់អត្តសញ្ញាណគាត់ទេ?

**ឆ៖** បាទ មិនមានអ្វីក្រៅពី ហែម ហ្នឹងទេបាទ។

**ស៖** បាទ នៅពេលដែលលោក ខៀវ សំផន ផ្ញើសារចេញនោះ តើគាត់កំណត់អត្តសញ្ញាណខ្លួនយ៉ាងម៉េច គឺថា ហៅខ្លួនឯង ហែម បងហែម ឬក៏គាត់ហៅខ្លួនគាត់ផ្សេងក្រៅពីហ្នឹង?

**ឆ៖** បាទ សាររបស់គាត់គឺ ជាសារចំហ ដូច្នេះគាត់អាចដាក់ ហែម អ៊ីចឹងក៏បាន ឬមួយក៏គាត់ដាក់ថា ខៀវ សំផន អ៊ីចឹងតែម្តងក៏បាន។ ឧទាហរណ៍ពីការណែនាំធ្វើឲ្យបងប្អូនយើងនៅតាមមូលដ្ឋានរង់ចាំស្តាប់សេចក្តីថ្លែងការណ៍របស់គាត់ ហើយក៏ណែនាំឲ្យបងប្អូនទាំងអស់បានឈប់សម្រាក ដើម្បីស្តាប់សេចក្តីថ្លែងការណ៍របស់គាត់ គាត់ដាក់ថា ខៀវ សំផន អ៊ីចឹងតែម្តងបាទ។

[១០:២៤:០៥]

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ ពីអ្វីដែលលោកបាននិយាយកាលពីម្សិលមិញនោះ គឺថា

លោកមាន លោកអាចទាក់ទងលោក ខៀវ សំផន តាមទូរស័ព្ទដោយផ្ទាល់ ហើយលោក ខៀវ សំផន នេះបានប្រើផ្នែកសេវារបស់លោក ដើម្បីបំភ័ន្តអក្ខរៈដែល -- របស់សារ ដែលលោកនឹងផ្ញើចេញ។ តើលោក ខៀវ សំផន មានឋានន្តរស័ក្តិហ្នឹងស្មើនឹងមន្ទីរ ក-១ ហើយគាត់មានលក្ខខណ្ឌស្ថិតនៅក្នុងលក្ខខណ្ឌដូចគ្នានឹង ក-១ នេះដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ សិទ្ធិរបស់គាត់ គឺមានសិទ្ធិប្រើក្រុមខ្ញុំ បានដូចខាង ក-១ដែរ។ ឯលក្ខខណ្ឌ ដែលសាររបស់គាត់គឺថា មិនមានអ្វីពី ក្រៅពីការចែកចាយ ចាត់ចែងខាងសម្ភារៈនោះទេបាទ។ វាខុសគ្នាត្រង់ហ្នឹង។ ខុសគ្នាត្រង់ថា ខាង ក-១ លោកមានសិទ្ធិធ្វើសារហ្នឹងគ្រប់ទិដ្ឋភាព ឆ្លើយតបគ្រប់បែបយ៉ាង ឯលក្ខណៈរបស់ខាងលោក ខៀវ សំផន គឺសារដែលភាគច្រើនរបស់លោក គឺជាសារបែងចែកសម្ភារៈបាទ។

[១០:២៥:៥៩]

**ស៖** កាលពីម្សិលមិញលោកបានពន្យល់ពីអក្សរមួយ ដែលលោកបាន -- អំពីគំនូសបំព្រួញមួយដែលលោកបានធ្វើជូនសហចៅក្រមស៊ើបអង្កេត ហើយនៅខាងលើគំនូសបំព្រួញនោះ លោកមាន -- ហៅថាមាន ម-៨៧0, ក-១ ហើយមានគណៈប្រធានរដ្ឋ ហើយនិងសភាតំណាងប្រជាជនជាដើម។ ប៉ុន្តែទាក់ទងទៅនឹងគណៈប្រធានរដ្ឋនេះ ហើយមានព្រួញមួយទាញចុះមកក្រោម ដែលចង្អុលមកចំក្រសួងនានា។ តើបើតាមលោកនេះ តើសញ្ញាព្រួញនេះ ចង់មានន័យថាយ៉ាងម៉េច? ថាតើមានន័យថា លោកខៀវ សំផន មានអំណាចលើក្រសួងទាំងអស់នេះ បានន័យថាលោក១ ខៀវ សំផន ទទួលទូរលេខពីក្រសួងទាំងអស់នេះ ឬក៏គេចម្លងជូនគាត់? ហេតុអីបានជាលោកគូសសញ្ញាព្រួញរវាងគណៈប្រធានរដ្ឋ ហើយនិងក្រសួងនានានេះ? ខ្ញុំយោងទៅលើឯកសារ D200/9.12។

**ឆ៖** បាទ គឺក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ គណៈប្រធានរដ្ឋក៏គាត់ជាអ្នកមើលការខុសត្រូវពីលើក្រសួងនានាដែរ គឺថា ខាងផ្នែកស៊ីវិល គឺគាត់មានលទ្ធភាព មានសិទ្ធិអាចដឹង អាចចាត់ចែងលើក្រសួងផ្សេងៗដែរ។ នេះតាមធម្មតានៃរដ្ឋនីមួយៗ ព្រោះថារាជរដ្ឋាភិបាល ឬរដ្ឋាភិបាលហ្នឹង ជាអ្នកទទួលផ្នែកស៊ីវិល។ ដោយឡែកតែមុខព្រួញនេះ ខ្ញុំមិនបានគូសទៅលើក្រសួងការពារជាតិ ឬមួយក៏ព្រួញទៅណាទេ គឺមានតែខាងផ្នែកស៊ីវិលទេ ដែលគាត់មានលទ្ធភាពគាត់មើលការខុសត្រូវអាចដឹងបាន។ ឯឋានៈរបស់គាត់មកមានឥទ្ធិពលលើកងទ័ព ក្រសួងការពារជាតិអីៗគឺអត់មានទេបាទ។ នេះខាងផ្នែកការពារជាតិគឺគេមានអគ្គបញ្ជាការមួយដ៏ធំគឺលោក សុន សេន បាទ ដែលក្នុងសម័យហ្នឹងគាត់គ្មានឥទ្ធិពលលើកងទ័ព

មិនមានសិទ្ធិគ្រប់គ្រងកងទ័ពទេ។ នេះជាសញ្ញាដែលខ្ញុំគូសហ្នឹង គឺមានន័យអ៊ីចឹង ដើម្បីចង់ឲ្យអស់លោកដឹងអ៊ីចឹង។ វាមានខាងស៊ីវិល និងខាងយោធា--

[១០:២៩:៣០]

**ស៖** បាទ ខ្ញុំសូមចោទសំណួរមួយទាក់ទងទៅនឹងអ្វីដែលលោកដឹង លោកឃើញ មិនមែនទាក់ទងទៅនឹងអ្វីដែលលោកទើបតែដឹងឥឡូវទេ។ កាលនៅសម័យនោះ នៅពេលដែលលោកទទួលខុសបន្ទុកខាងបកប្រែ ឬក៏បំភ័ន្តអក្ខរៈទូរលេខ លោកបានទទួលទូរលេខដែលផ្ញើជូនទៅក្រសួងមួយចំនួន តើទូរលេខទាំងអស់នោះបានផ្ញើ មានចម្លងជូនលោកខៀវ សំផន ដែរឬទេ? ហើយកាលនោះ លោកដឹងទេលោកមានដឹងអំពីទំនាក់ទំនងរវាងក្រសួងមួយចំនួន និងលោក ខៀវ សំផន ដែរឬទេ បើសិនជាលោកដឹងលោកជម្រាបថាដឹង បើមិនអ៊ីចឹងទេលោកមិនបាច់ឆ្លើយក៏បានដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** បាទ ខ្ញុំសូមត្រឡប់និយាយអំពីពេលដែលលោកនៅ ប-២០។ នៅរយៈកាលពេលរំដោះទីក្រុងភ្នំពេញ លោកបានពន្យល់ការផ្នែកថាបកប្រែ ឬបំភ័ន្តអក្ខរៈទូរលេខនេះបាន ត្រូវបានបែងចែកពីរផ្នែកគឺថាមួយផ្នែកនៅមន្ទីរ ប-២០ ហើយមួយទៀតនៅជាមួយ ប៉ុល ពត គឺថានៅសមរភូមិ នៅភាគខាងលិចនៃទីក្រុងភ្នំពេញ។ លោកបាននិយាយដោយភាពចម្រូងចម្រាសថា លោកនិយាយថាលោកមិនបានទទួលទូរលេខ ការណែនាំទាក់ទងទៅនឹងការកំណត់ផែនការវាយប្រហារលើទីក្រុងភ្នំពេញនោះទេ ហើយលោកក៏មិនចាំផងដែរអំពីសារទាក់ទងទៅនឹងការជម្លៀសពីទីក្រុងភ្នំពេញ។ តើខ្ញុំសង្ខេបអ្វីដែលលោកបាននិយាយនេះត្រឹមត្រូវដែរឬទេ?

[១០:៣១:២៨]

**ឆ៖** បាទ ជាការត្រឹមត្រូវ និងជាការពិត។

**ស៖** ពេលដែលលោកមន្ទីរប-២០ លោកបាននិយាយថាលោកអាចទាក់ទង ប៉ុន ជាអចិន្ត្រៃយ៍ដែល ប៉ុន នោះនៅជាប់នឹង ប៉ុល ពត។ ហើយបើសិនជាយល់ -- ខ្ញុំយល់មិនច្រឡំទេគឺថា ផ្នែក -- មន្ទីរ ប-២០ហ្នឹង គឺទទួលខាងបកប្រែ ហើយនិងបំភ័ន្តអក្ខរៈទូរលេខដែលផ្ញើជូនទៅមូលដ្ឋាន។ សំណួរខ្ញុំដូចតទៅនេះ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកបានទទួលទូរលេខទាក់ទងទៅនឹងការបង្កើត ឬក៏ថាការណែនាំទាក់ទងទៅនឹង -- ណែនាំទាក់ទងនឹងប្រជាជនដែលគេជម្លៀសចេញពីទីក្រុងភ្នំពេញ តើលោកបានទទួលទូរលេខដែលក្នុងទូរលេខនោះ គេពន្យល់ គេប្រាប់ជាមុនថានឹងមានប្រជាជនជម្លៀស

មក ហើយយើងត្រូវទទួល ហើយត្រូវថែទាំពួកគាត់ ហើយនិងផ្តល់អាហារហូបចុកដល់គាត់ ហើយនិងឲ្យគាត់ស្នាក់នៅ តើលោកបានទទួលទូរលេខបែបនេះដែរឬទេ ចំពោះប្រជាជនដែលគេនឹងជម្លៀសទៅតាមមូលដ្ឋាននោះ?

**ឆ៖** បាទ ខ្ញុំមិនដែលបានទទួលទូរលេខបែបនេះទេបាទ។

[១០:៣៣:១៥]

**ស៖** បាទ ខ្ញុំមានសំណួរពីរទៀត ដើម្បីសួរទៅលោក ទី១ ទាក់ទងទៅនឹងការរៀបចំមន្ទីរ "ក"។ ខ្ញុំសូមជូនឯកសារមួយទៅលោក គឺថាឯកសារ E3/858 សូមផ្តល់ឯកសារនេះទៅលោកសាក្សី។ បាទ ឯកសារនេះរៀបរាប់អំពីសមាជិកមន្ទីរ "ក"។ បាទ ខ្ញុំកត់សម្គាល់ឃើញថាមានផ្នែក ក-១ នោះមានពីរផ្នែក គឺថា "ក" ជាទូទៅ ហើយនិងក-១ ដែលមានសរសេរនៅក្នុងចុងឯកសារហ្នឹងគឺថា មានមន្ទីរក-១ នៅខាងក្រៅផ្ទះអ៊ំ។ តើលោកអាចបញ្ជាក់បានទេ ថាតើមានបណ្តុំ ក-១ គឺថាៗមានអ្នកដឹកនាំខុសគ្នា?

**ឆ៖** បាទ ដែលខ្ញុំចាំមន្ទីរ ក-១ ដែលគេដាក់ថា បងលីន នេះគឺនៅក្នុងឯកសារដែលខ្ញុំបានឆ្លើយជាមួយសាក្សីហ្នឹងគឺសំដៅ កែន ហ្នឹងហើយបាទ។ កែន ហ្នឹងគឺឈ្មោះគាត់ពីរ កែន ឬ លីន គឺមនុស្សតែមួយទេបាទ។ ឯរឿងទីតាំងរបស់ ក-១ នេះដែលគាត់មានសិទ្ធិគ្រប់គ្រងមិនមែនតែក្រៅអា *ប៉ូលីង* ហ្នឹងទេ ប៉ុន្តែទាំងក្នុងទាំងក្រៅបាទ ការពារសន្តិសុខនៅ ក-១ ហ្នឹង។ ឯ ក-១ ហ្នឹងគេគិតទាំងក្នុងបរិវេណទាំងក្រៅបរិវេណបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំមានសំណួរមួយចំនួនទៀតដែលត្រូវសួរលោក ប៉ុន្តែឥឡូវនេះប្រហែលជាដល់ពេលសម្រាកហើយ។

[១០:៣៦:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់សម្រាកសម្រាប់សាក្សីក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៦ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០១:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

សូមផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរចំពោះដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។

លោកសាក្សី ប្រសិនបើលោកមានអារម្មណ៍ថា អស់កម្លាំង ហើយលោកត្រូវការសម្រាកនោះ សូមឲ្យលោកបញ្ជាក់ប្រាប់យើងផង។ ពីព្រោះយើងមើលឃើញថា លោកដូចជាមិនសូវស្រួលខ្លួនប៉ុន្មានទេ។

[១១:០២:៤៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីឯកសារ E3/858 អម្បាញ់មិញនេះ។ លោកបានផ្តល់ការពន្យល់ខ្លះៗហើយពាក់ព័ន្ធទៅនឹងសមាសភាពនៅមន្ទីរ ក-១ ហើយជាពិសេសនៅទំព័រដំបូងនោះ យើងមានឃើញឈ្មោះ បងលីន ជាប្រធានរួមមន្ទីរ ក-១ និង ក-៤។ តើ បងលីន ហ្នឹងក៏មានឈ្មោះថា កែន ដែរ មែនទេលោកសាក្សី?

**លោក នង សុផង់៖**

**ឆ៖** បាទ គឺឈ្មោះ កែន ដែរ។

**ស៖** សូមលោកពិនិត្យមើលបញ្ជីឈ្មោះនេះបន្តិចទៅ ហើយតើលោកមានឃើញឈ្មោះណាដែលលោកស្គាល់ទេ? ដូចឧទាហរណ៍ឈ្មោះ បងតាន ជាប្រធានមន្ទីរ ក-១, បងស៊ិន ដែលមានលេខ

រៀងទី៣ ប្រធានការពារ ពេលអំំចេញដំណើរ។ តើឈ្មោះទាំងអស់នេះ លោកមានស្គាល់អ្នកណា ហើយមានដឹងថាធ្វើអ្វីខ្លះទេ?

[១១:០៣:១៧]

**ឆ៖** បាទ សុទ្ធតែធ្លាប់ដែរណ៎ាដូច តាន ក៏ស្គាល់, ស៊ិន ក៏ស្គាល់, ហាន ក៏ស្គាល់ និយាយរួម គឺសុទ្ធតែអ្នកធ្លាប់ស្គាល់គ្នា។

**ស៖** តើលោកស្គាល់ឈ្មោះ សែន? តើលោកស្គាល់ទេឈ្មោះ--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកចៅក្រមបញ្ជាក់ឈ្មោះឲ្យបានច្បាស់ ព្រោះអ្នកបកប្រែស្តាប់អត់បាន ជាភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក និយាយពីឈ្មោះឡើងវិញ ព្រោះអ្នកបកប្រែបកប្រែអត់បានទេ។ សូមបញ្ជាក់សាឡើងវិញ!

[១១:០៤:២០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំនិយាយអំពីឈ្មោះ សែម ឈ្មោះថា កេត ថោ ឈ្មោះពេញ តើលោកស្គាល់ឈ្មោះ សែម នេះទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ឈ្មោះ សែម ហ្នឹងគឺជាប្រពន្ធរបស់ លើន គឺ កែន ហ្នឹងហើយបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅទំព័រផ្សេងទៀត នៅក្នុងភាសាបារាំងគឺទំព័រ៩។ នៅខាងលើនោះ ដាក់ថា ក-៧។ សូមលោកចូលទៅមើលទំព័រ ក-៧ ជាភាសាបារាំង 00643488។ ទំព័រនេះនិយាយអំពី មន្ទីរ ក-៧។ ក្នុងឯកសារនេះដាក់ថា "ក-៧ នីរសារ ទូរស័ព្ទ ដឹកជញ្ជូន។ ឈ្មោះទី១ គឺឈ្មោះ ហាន ប្រធានមន្ទីរ ក-៧។ ទី២ គឺឈ្មោះ ថន"។ តើលោកអាចពិនិត្យមើលឈ្មោះទាំងអស់នេះនៅក្នុងបញ្ជីហ្នឹង ហើយលោកអាចប្រាប់បានទេថា លោកស្គាល់ឈ្មោះណាដែរ?

**ឆ៖** បាទ ហាន ហ្នឹងគឺធ្លាប់ស្គាល់ដែរ ប៉ុន្តែដូចជាមិនមែនជាប្រធានមន្ទីរ ក-៧ ទេបាទ។ ហាន ហ្នឹងដូចធ្លាប់ជាប្រធានខាងបង្កបង្កើនផលនៅ ក-៨ វិញបាទ។ អ៊ីចឹងការរៀបចំ វាមានការប្រែប្រួល

ច្រើនបាទ។ អ៊ីចឹងនេះជា ហាន ដែលខ្ញុំមិនធ្លាប់ស្គាល់។ ហាន ដែលខ្ញុំស្គាល់ គឺជាប្រធានខាងដាំបន្លែនៅក្បែរទន្លេបាសាក់ ហៅថា ក-៨ ទៅវិញបាទ។

[១១:០៧:៤៥]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅចំណុចមួយទៀត គឺ ក-១៣ គឺពីរទំព័រមកមុខបន្តិចមក។ មានបញ្ជាក់ថា ក-១៣ ខាងទូរលេខ។ ERN ជាភាសាបារាំង 00643490។ ក្នុងឯកសារនេះដាក់ថា ក-១៣ ខាងទូរលេខ ១ ប៉ុន ប្រធានមន្ទីរ ក-១៣ អតីតគ្រូបង្រៀននៅកំពង់ចាម។ កើតនៅទួលសម្បូរ។ នៅឆ្នាំ ១៩៧០ ចូលធ្វើយោធា។ ឈ្មោះទី២ យស់ អនុប្រធាន ម -- មន្ទីរក-១៣។ ទី៣ ឈ្មោះ អាត សមាជិកមន្ទីរ ក-១៣។ ទី៤ ឈ្មោះ សែន ហើយទី៥ ឈ្មោះ ឡាក់ ហើយនិង ស្រ៊ាង។ តើលោកស្គាល់ឈ្មោះទាំងអស់នេះទេ? ខ្ញុំ -- ហេតុអីបានជាទៅជា ក-១៣ ខាងទូរលេខទៅវិញ? ព្រោះថាធម្មតា គឺ ក-១៨ ទេ ដែលខាងទូរលេខ។ នៅក្នុងឯកសារនេះ បែរជាដាក់ថា ក-១៣។ តើនេះជាកំហុស ឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំមិនយល់បាទ។ ព្រោះ ប៉ុន ធ្លាប់ធ្វើជាប្រធានខ្ញុំផង ហើយក៏គាត់គ្រប់គ្រងខាងទូរលេខនៅទូតអាមេរិក ដូចជា យស់ ដែរ។ ហ្នឹង -- ឯ ក-១៣ នេះ វាខ្ញុំមិនដែលឮ ហើយក៏មិនដឹងជាគេរៀបចំថ្មី ឬមួយយ៉ាងម៉េច។ បាទ ឯឈ្មោះ អាត, ឈ្មោះ ឡាក់ ក៏ធ្លាប់ស្គាល់, ស្រ៊ាង ក៏ធ្លាប់ស្គាល់ដែរ។ សែន នេះខ្ញុំភ្លេច។ តែច្បាស់ជាងគេគឺ ប៉ុន និង យស់ បាទ។ តែគាត់ គេដាក់ថា ក-១៣ ហ្នឹង គឺខ្ញុំក៏វាខុសការដែលកំណត់ គឺ ក-១៨ បាទ។

**ស៖** ចំណុចចុងក្រោយ គឺ "មន្ទីរ ក-១ ខាងក្រៅផ្ទះអ៊ំ"។ លោកអាចឃើញហើយនៅលើឯកសារនេះ គឺលើទំព័រ១៤ ERN 00643493 ជាភាសាបារាំង។ ក្នុងបញ្ជីនេះមានឈ្មោះមួយចំនួន ទី១ ឈ្មោះ ឌីម ប្រធាន ក-១។ ទី២ ឈ្មោះ តេង អនុប្រធាន ក-១។ ៣. ថៃ -- ថៃ (សូមទោស) គឺសមាជិកមន្ទីរ ក-១។ ៤. ភាក់, ៥. ជឿន, ៦. ឆាត, ៧. ឡុង ...។ល។ តើលោកធ្លាប់ស្គាល់ឈ្មោះទាំងអស់នេះទេ? លោកមាននឹកឃើញទេ?

[១១:១២:២១]

**ឆ៖** បាទ នេះជាក្រុមការពារខាងក្រៅ ក-១។ ខ្ញុំចាំមិនបានទេបាទ។ មិនសូវស្គាល់ដែរ។

**ស៖** ក្នុងចំណោមឈ្មោះទាំងអស់នៅក្នុងឯកសារនេះ តើលោកមានចាំទេ ថាមានអ្នកណាខ្លះដែលត្រូវបានបោសសម្អាតសម្រិតសម្រាំង ឬក៏កម្ទេចចោលនោះ? តើលោកដឹងអ្វីខ្លះអំពីអ្នកទាំងអស់ដែលនៅមន្ទីរប -- មន្ទីរ ក-១ ហើយដែលបានបាត់ខ្លួននោះ?

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ អ្នកនៅ -- ព្រោះក្នុងទំព័រនេះ វាទំព័រការពារខាងក្រៅ។ អ៊ីចឹង គឺខ្ញុំមិនស្គាល់គេទេបាទ។

**ស៖** ជាចុងក្រោយ ខ្ញុំសូមបញ្ជាក់ថា យើងមានឯកសារមួយចំនួនមកពីមន្ទីរស-២១។ ឯកសារដំបូងគឺ D108/26.227។ នេះគឺជាបញ្ជីដែលមានចំណងជើងថា “ផ្នែកក្រសួង ស-៧១” ហើយក្នុងនេះមានឈ្មោះមនុស្សជាច្រើន។ ឧទាហរណ៍ដូចជាឈ្មោះ លេខ៧ មានឈ្មោះថា សន ស៊ីម ហៅ អាត ហើយក្នុងនេះដាក់ថា “អនុប្រធានមន្ទីរ ក-១៨” ចូលនៅមន្ទីរ ស-២១ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៧៨។ ហើយចំពោះលេខ១៣ វិញ គឺមានឈ្មោះ អ៊ុច ថាន់ ហៅ ប៉ុន ប្រធានមន្ទីរទូរស័ព្ទ ចូលថ្ងៃទី៤ ខែមេសា ឆ្នាំ៧៨។

លេខ១៥ មានឈ្មោះ ថោង ហាន ប្រធានក្រុមនីរសារ មន្ទីរ៧។ ចូលថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៨។ ឈ្មោះ លេខ១៨ (សូមទោស) ១៩ ទូន គឹមស្រ៊ុយ ហៅ ស្រ៊ាង ប្រធានក្រុមន្ទីរ ក-១៨។ តើឈ្មោះដែលខ្ញុំអានអម្បាញ់មិញនេះ លោកមានដឹងទេ ដឹងថា ពួកគាត់មានបាត់ខ្លួនទេ?

[១១:១៥:៣៤]

**ឆ៖** បាទ ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងតែបាត់ប្រធានខ្ញុំហ្នឹង ឈ្មោះ ប៉ុន ហ្នឹងទេបាទ។ ឯអ្នកផ្សេងៗទៀត ខ្ញុំមិនដឹងគេបាត់ពេលណាៗអីទេ អត់ដឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី ដែលបានខិតខំប្រឹងប្រែងក្នុងការផ្តល់សក្ខីកម្ម។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី លោក នួន ជា!

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ ខ្ញុំលើកឡើងនេះគឺ ចង់និយាយអំពីឯកសារពីរ ដែលយើងបានដាក់នៅក្នុងសំណុំរឿងគឺ D200/3.11 និង D200/3.12 គឺជាប្រតិចារឹក គឺជាប្រតិចារឹកនៃការថតសំឡេងជាខ្សែអាត់ នៃកិច្ចសម្ភាសន៍របស់សាក្សីរូបនេះ ហើយ

យើងធ្វើទៅតាមអ្វីដែលចៅក្រម ហ្វេនស៍ បានសម្រេចកាលពីថ្ងៃមុន។ ហើយឯកសារនេះ យើងមិនទាន់បានដាក់នៅក្នុង*អ៊ីនធីហ្វេស* នៅឡើយ យើងទើបនឹងដាក់កាលពីម្សិលមិញមួយ នៅថ្ងៃនេះមួយ។ ដូច្នេះ ខ្ញុំចង់ជម្រាបឲ្យអង្គជំនុំជម្រះ ដើម្បីឲ្យបានដឹង ហើយជាការផ្ដល់ព័ត៌មាន ហើយខ្ញុំខាងភាគីយើងខ្ញុំនឹងមានចេតនាប្រើប្រាស់ឯកសារនេះ។

នេះគឺជាអ្វីដែលយើងបានធ្វើការគិតស្មានថា ប្រហែលជាផ្អែកតាមចម្លើយរបស់សាក្សី គឺនឹងមានការប្រើប្រាស់ដោយភាគីទាំងអស់។ ដូច្នេះ ខ្ញុំងើបឡើងនេះ ដើម្បីជម្រាបជូនដល់អង្គជំនុំជម្រះដើម្បីជាព័ត៌មាន។ សូមអរគុណ។

[១១:១៧:៥៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៩:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក គង់ សំអុន៖**

លោក នង សុផង់ សូមជម្រាបសួរផងដែរ។ ខ្ញុំបាទ គង់ សំអុន ជាមេធាវីការពាររបស់លោក ខៀវ សំផន។ ហើយក្នុងនាមលោក ខៀវ សំផន ក៏សូមថ្លែងអំណរគុណដល់លោកផងដែរ ដែលបានចំណាយពេលវេលាមកធ្វើជាសាក្សីផ្ដល់សក្ខីកម្មយ៉ាងល្អិតល្អន់ ហើយដែលបានឆ្លើយយ៉ាងច្បាស់ក្នុងរយៈកាលកន្លងមក សូម្បីតែលោកកំពុងតែមានជំងឺក៏ដោយ។

**ស៖** ខ្ញុំមានសំណួរមួយចំនួនដើម្បីបញ្ជាក់ សូមឲ្យលោកជួយបញ្ជាក់បន្ថែម ទៅលើសំណួរដែលបានតាំងរួចមកហើយចំពោះលោក ក្នុងរយៈពេលកន្លងមកនេះ។ ជាដំបូងខ្ញុំសូមឲ្យលោកបញ្ជាក់ទៅលើកិច្ចការរបស់លោកក្នុងនាមជាអ្នកបកប្រែសារនៅក្នុងមន្ទីរក-១៨ ដែលលោកបានបង្ហាញថា មានផ្នែកខាងក្រៅ និងខាងក្នុង។ ខ្ញុំចង់ដឹងថា តើការទទួលខុសត្រូវចំពោះសារដែលចូលមកក្នុងមន្ទីររបស់លោក

ផ្នែកខាងក្រៅ និងផ្នែកខាងក្នុងនោះមានលក្ខណៈខុសគ្នា ឬក៏ប្រភេទសារដូចតែគ្នាទេ? បានន័យថា ការបញ្ជូនសារចេញចូលគឺអាចទទួលបានដូចគ្នា មិនមានកំណត់ទៅលើភាពចាំបាច់នៃសារ។ ឧទាហរណ៍ថា សារដែលមានលក្ខណៈជាសម្ងាត់ខ្លាំង ឬសម្ងាត់ធម្មតា ឬក៏សារធម្មតានោះ? សូមលោកជួយបញ្ជាក់។

[១១:២១:៤១]

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំសូមបញ្ជាក់បំភ្លឺ។ ក្រុមរបស់ខ្ញុំ ដែលធ្វើការនៅ ក-១ បាទ មិនមែននៅ ក-១៨ ទេ។ ក-១ គឺមានអ្នកបកប្រែខាងក្នុង ឯខ្ញុំនៅសាលាសម្តេចសុធារស គឺជាក្រុមបកប្រែមួយដែរ ហើយនិងទទួលបន្ទុកខាងបង្រៀនបច្ចេកទេស រៀនលេខអក្សរ។ ឯភារកិច្ចនិយាយអំពីការងារដែលក្រុមទាំងពីរនេះ គឺដូចខ្ញុំបានជម្រាបជាហូរហែហើយ ជាទូទៅសារណាដែលមានលក្ខណៈមូលដ្ឋានណា ដែលមិនមានខ្លាំងឈ្លានពានអីប៉ុករុកទេ គេយកឯកសារហ្នឹងទិសហ្នឹងខ្ញុំអ្នកកាន់ ដើម្បីបង្រៀនឲ្យក្មេងៗហ្នឹងធ្វើជាក់ស្តែងផង រៀនផង ធ្វើផង។ ឯចំពោះសារដែលមានលក្ខណៈ -- ទិសណាដែលខ្ញុំកាន់ក៏ដោយ ឧទាហរណ៍ដូចទិសព្រៃសាន ក៏មានពីមុនខ្ញុំកាន់ដែរ ប៉ុន្តែដល់ពេលដែលមានសភាពការណ៍នៅតាមព្រំដែនតឹងតែងទៅ ដើម្បីការឆ្លើយឆ្លងឲ្យបានរហ័ស ក្តាប់សភាពការណ៍ឲ្យបានទាន់ពេលវេលា គេក៏យកសារភូមិភាគព្រៃសានហ្នឹងពីខ្ញុំទៅបកនៅខាងក្នុងដែរ។ បាទ នេះជាលក្ខណៈការងារខាងក្នុង និងខាងក្រៅ វាមានលក្ខណៈអ៊ីចឹង។ បាទ សូមបញ្ជាក់ប៉ុណ្ណឹង មានអីមិនច្បាស់ទៀតបាទ សូមសួរបន្ថែមទៀត។

[១១:២៣:៥៨]

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ ហើយនិងការកែតម្រូវដល់ខ្ញុំផងដែរ។ ខ្ញុំចង់សួរបន្តថា តើផ្នែកខាងក្រៅ មានគ្នាជាអ្នកធ្វើការហ្នឹងប៉ុន្មាននាក់ដែរសម្រាប់បកសារ? ហើយនិងខាងក្នុងហ្នឹងមានប៉ុន្មាននាក់ដែរ?

**ផ៖** ខាងក្នុង-- ខាងក្រៅខ្ញុំនេះមានកុមារដែលខ្ញុំបណ្តុះបណ្តាលមួយវគ្គហ្នឹងអាចបានបួននាក់។ ហ្នឹងវគ្គទី១ អាចជួយការងារជាមួយខ្ញុំ ដល់ចប់ទៅគឺបានសរុបទាំងអស់ក្មេងដែលមានសមត្ថភាព អាចធ្វើការងារជាមួយខ្ញុំបាន គឺបួនដប់នាក់បាទ។ ឯខាងក្នុងវិញ តាមខ្ញុំចាំដូចមានតែពីរបីនាក់ទេបាទ មិនមានច្រើនទេបាទ។

**ស៖** បាទ សូមអរគុណ។ សម្រាប់ផ្នែកខាងក្រៅរបស់លោក តើមានការបែងចែកមុខសញ្ញា ឬក៏មុខព្រួញសម្រាប់ទទួល និងបកសារជាក្រុមតូចៗទៀតទេ?

**ឆ៖** បាទ មានការបែងចែកដូច្នោះមែន គឺថាព្រោះសារហ្នឹងសរុបទៅក្នុងរយៈកាលហ្នឹងវាជាង ១០ទិសដែរ។ អ៊ីចឹងខ្ញុំកំណត់ថា អ្នកដែលគេបានចេះហើយក្នុងម្នាក់ហ្នឹងអាចទទួលបីទិសបាន ហើយ ប្អូននាក់វាពីរដណ្ដប់ទិសអាចរត់រួចហើយ។ អ៊ីចឹង គឺក្នុងម្នាក់អាចទទួលពីរ ឬបីទិសបាន។

[១១:២៦:២៧]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលបុគ្គលិករបស់លោកបានបកសារ តើលោកជាអ្នកត្រួតពិនិត្យបញ្ជាក់ទៅលើខ្លឹមសារ ហ្នឹងសាជាថ្មីដែរឬទេ?

**ឆ៖** បាទ ក្នុងឋានៈខ្ញុំជាអ្នកទទួលខុសត្រូវលើផ្នែកខាងក្រៅនេះ គឺខ្ញុំបានត្រួតពិនិត្យទាំងអក្ខរាវិរុទ្ធ ទាំងបញ្ហាឃ្លាឃ្លោងអីក៏ -- ហើយនិងកន្លែងណាដែលមិនច្បាស់ ឬក៏បកទៅវា គេមិនយល់អីគឺខ្ញុំជាអ្នកជួយសម្រួលទាំងអស់បាទ។ ទាំងខាងបច្ចេកទេស ទាំងខាងខ្លឹមសារ គឺមុននឹងបញ្ជូនទៅខាង ក-១ នេះគឺត្រូវបានទទួលការពិនិត្យរបស់ខ្ញុំជាមុនបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ថា -- ទៀតថាតើការិយាល័យរបស់លោកហ្នឹងមានការធ្វើផ្ទៀងផ្ទាត់ទៅលើព័ត៌មានដែលមាននៅក្នុងសារនីមួយៗនោះដែរទេ? ឧទាហរណ៍ថាសារមួយត្រូវបានបញ្ជូនមកការិយាល័យរបស់លោក ហើយលោកត្រូវធ្វើការបញ្ជាក់ថាតើខ្លឹមសារដែលមាននៅក្នុងសារនោះវាត្រឹមត្រូវ ឬមួយក៏លោកគ្រាន់តែបកសារនោះទៅតាមខ្លឹមសារដែលមាននៅក្នុងសារនោះតែម្ដង?

[១១:២៨:១៤]

**ឆ៖** បាទ ចំពោះខ្លឹមសារត្រឹមត្រូវ ឬមិនត្រឹមត្រូវ គឺបកទៅតាមតែខ្លឹមសារដែលគេបញ្ជូនមក ខ្ញុំមិនបានផ្ទៀងផ្ទាត់ថាព័ត៌មានហ្នឹង វា -- គេរាយការណ៍ថាវាជាព័ត៌មានពិតប្រាកដ ឬមួយក៏ព័ត៌មានដែលគេគ្រាន់តែរាយការណ៍មកនោះទេ គឺថាមិនដឹងជាពិត ឬមិនពិត ឲ្យមានតែនៅក្នុងខ្លឹមសារ ឲ្យតែមាននៅក្នុងអត្ថបទហ្នឹងគឺបកទៅតាមតែខ្លឹមសារទេបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការចម្លងជូន ក្នុងដាក់ថាចម្លងជូនទៅអ៊ំៗ ដែលលោកបានឆ្លើយជាហូរហែកន្លងមកនេះ លោកបានបញ្ជាក់ថាលោក នៅពេលដែលសរសេរបកសារនោះ លោកដាក់ត្រឹមតែថ្ងៃខែ ហើយចម្លង ការចម្លងជូននោះទៅឲ្យប្រធានរបស់លោកគឺ លោក ប៊ុន ជាអ្នកដាក់ថា "ចម្លងជូនអ្នកណា"។ ខ្ញុំចង់សួរបញ្ជាក់ថា តើការដាក់ថា ការចម្លងជូនទៅអ៊ំៗណាមួយនោះ ការិយាល័យរបស់លោកមាននីតិវិធីសម្រាប់ផ្ទៀងផ្ទាត់ថា ឯកសារដែលលោកបញ្ជូនទៅហ្នឹង ឬសារ

ដែលបញ្ជូនទៅហ្នឹង ត្រូវបានទៅដល់ដៃអ៊ីៗទាំងអស់នោះដែរទេ?

[១១:៣០:១២]

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ។ មិនដឹងជាបានទៅដល់ ឬមិនដល់។ ឯការដាក់ចម្លងជូនអ្វីៗដែលគេវាយម៉ាស៊ីនហើយ បើកន្លែងណាដែលខ្ញុំច្បាស់ក៏ខ្ញុំដាក់ចម្លងជូនអ៊ំនេះ អ៊ំនោះតែម្តង។ តាមគោលការណ៍ដែលគេបានកំណត់។ ជារួមគឺថា មានអីប្រែប្រួលទេ ក្នុងសម័យនុ៎ង គឺថាបើសារទូទៅត្រូវដែលត្រូវដឹងឮទាំងអស់គ្នា គេដាក់ទាំងអស់ហ្នឹងអ៊ំ, មន្ទីរ, ឯកសារ អីហ្នឹងហែដូចអ៊ីចឹង។ តែករណីសារខ្លះៗដែលខ្ញុំមិនច្បាស់លាស់ មុននឹងដាក់ថាចម្លងជូន ខ្ញុំមិនប៊ានសម្រេចដោយខ្លួនឯងដែរ ទាល់តែទូរស័ព្ទសួរគេសិនបាន ថាតើជូនអ៊ំៗណាខ្លះ? បាទ ហើយក៏ឱ្យគេវាយទៅតាមជាក់ស្តែងដែលខាង ប៉ុន គេបានផ្តល់ព័ត៌មានត្រឡប់មកវិញ។ អាហ្នឹងបើសិនណាមិនច្បាស់ ខ្ញុំសុខចិត្តជូនទាំងអ៊ីចឹងតែម្តង ឱ្យទៅគេតែម្តង។

**សៈ** បាទ សូមអរគុណ។ នៅក្នុងពេលបកសារនីមួយៗ តើលោកធ្លាប់ជួបសារណាមួយដែលមានសរសេរចម្លងជូនពីសារដែលលោកបានបកនោះរួចហើយទេ? បានន័យថា សារដែលទទួលថាចម្លងជូននោះបាននៅពេលដែលលោកទទួលមកភ្លាមគឺមានៗពាក្យថា "ចម្លងជូន" ហ្នឹងតែម្តង គឺមិនមានការដាក់បន្ថែមនៅៗការិយាល័យរបស់លោកទេ។

**ឆ៖** បាទ មិនមានទេ។

[១១:៣២:៣៤]

**សៈ** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងការកំណត់នូវអង្គការចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលលោកបានឆ្លើយបញ្ជាក់ច្រើនរួចមកហើយទាំងជាមួយសហ -- តំណាងសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងចំណុចនេះ ខ្ញុំបានពិនិត្យឃើញការប្រើប្រាស់ពាក្យរបស់លោកសំដៅទៅលើអង្គការបក្សមានភាពមិនសូវច្បាស់លាស់ អ៊ីចឹងខ្ញុំសូមឱ្យលោកជួយបញ្ជាក់បន្ថែមទៅលើពាក្យទាំងអស់នោះ។

ឧទាហរណ៍ពាក្យថា "មជ្ឈិម" កាលពីសវនាការកន្លងមកនេះ ខ្ញុំសូមលើកឧទាហរណ៍នៅថ្ងៃ -- នៅៗចំណុចមួយ នៅថ្ងៃទី០៣ ខែកញ្ញា ក្នុងទំព័រ១៦ ជាភាសាខ្មែរ និងទំព័រ១៩ ទៅ២០ ភាសាអង់គ្លេស និងទំព័រ២០ ជាភាសាបារាំង។ មានការប្រើពាក្យ ឧទាហរណ៍មន្ទីរមជ្ឈិម និងគណៈ៨៧០ ជាដើមនៅក្នុងនេះ ហើយលោកក៏បានឆ្លើយបញ្ជាក់ថា លេខសម្ងាត់៨៧០ គឺមានន័យថា លេខរបស់មជ្ឈិមជាដើម។ អ៊ីចឹងខ្ញុំចង់សួរថា តើការប្រើប្រាស់ពាក្យ ខ្ញុំនឹងសូមលើកជូនពាក្យថា "មជ្ឈិម, មន្ទីរមជ្ឈិម, គណៈ

មជ្ឈិម, ៨៧០, ម-៨៧០, មន្ទីរ៨៧០, គណៈ៨៧០, គណៈអចិន្ត្រៃយ៍” តើទាំងអស់នេះលោកអាចធ្វើការបែងចែក កំណត់ច្បាស់លាស់ទេថា តើពាក្យនីមួយៗ គេនិយាយសំដៅលើអ្វីជាក់លាក់? ហើយបើលោកអាចទាញយកពាក្យណាស្មើនឹងពាក្យណាបាន សូមលោកជួយបញ្ជាក់ផង។

[១១:៣៥:២៧]

**ឆ៖** បាទ យើងឃើញការប្រើពាក្យពេចន៍ហ្នឹងវាច្រើន។ តែអ្វីដែលយើងឃើញដូចគ្នា គឺលេខ ៨៧០ បាទ។ ទោះបីអ្នកណាប្រើមន្ទីរ ក៏នៅតែ៨៧០ អ្នកណាប្រើអង្គការ ក៏នៅតែ៨៧០ អ្នកណាប្រើគណៈ ក៏នៅតែ៨៧០។ ដូច្នេះចំពោះខ្លួនខ្ញុំ គឺខ្ញុំវាច្របូកច្របល់ហើយដល់អ៊ីចឹង មិនដឹងអ្នកណាជាគណៈអចិន្ត្រៃយ៍ អ្នកណាជាស្អីៗ។ ប៉ុន្តែតាមខ្ញុំយល់ដោយខ្លួនឯងទេ ឯន័យអនុវត្តរបស់ពួកខ្ញុំហ្នឹង គឺថាអត់ខ្វល់ពីរឿងគណៈ៨៧០មក ៨៧០ អង្គការ៨៧០ អីទេ ឲ្យតែឃើញសារគឺៗសំដៅទៅចូល ក-១ ទាំងអស់តែម្តង។ បាទនេះគឺន័យអនុវត្តរបស់ខ្ញុំ អត់ខ្វល់ពីរឿងដូចអស់លោក គណៈ, អង្គការអីនោះទេបាទ។ ឯខ្ញុំការបកស្រាយរបស់ខ្ញុំ ការយល់ដឹងរបស់ខ្ញុំ គឺមានកម្រិតណាស់ ពីព្រោះខ្ញុំជាអ្នកតូចតាចមិនអាចដឹងនូវការកំណត់គោលការណ៍របស់អចិន្ត្រៃយ៍យ៉ាងណាទេ អំពីការប្រើពាក្យពេចន៍ទាំងអស់នោះបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំអាចយល់បានថា លោកមានការលំបាកក្នុងការវាយតម្លៃទៅលើពាក្យនេះ។ ក៏ប៉ុន្តែខ្ញុំតាំងសំណួរនេះចំពោះលោក ដោយសារវាមានភាពចាំបាច់របស់យើង សម្រាប់ការពារលោក ខៀវ សំផន។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ទៅលើលោកថា ការប្រើប្រាស់កន្លងមកក្នុងការិយាល័យរបស់លោក មិនបានបញ្ជាក់ឲ្យដាច់ស្រេះថា -- ឲ្យដាច់ស្រឡះថា តើអ្វីច្បាស់លាស់ជាមន្ទីរ៨៧០ ឬគណៈ៨៧០ ឬអង្គការ៨៧០ ឬអង្គការមជ្ឈិម គឺខាងការិយាល័យរបស់លោក មិនបានធ្វើការបែងចែងទៅលើការប្រើប្រាស់ពាក្យនេះទេ? អ៊ីចឹងមែនទេ?

[១១:៣៧:៥៧]

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ អ៊ីចឹងខ្ញុំសូមសួរបន្តទៀតថា តើលោកអាចយល់ច្បាស់អំពីអង្គការពីរ។ ទី១ គឺគណៈអចិន្ត្រៃយ៍ និងទី២ គណៈមជ្ឈិមនៃអង្គការបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** បាទ រឿងនេះហើយដែលខ្ញុំឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹង អស់លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង។ ថាអស់លោកទាំងអស់សុទ្ធតែអ្នកធ្វើការធំៗ ហើយក៏លោកមិនយល់

ចុះទម្រាំបើខ្ញុំ គ្រាន់តែជាអង្គភាពបកប្រែមួយតូច ម៉េចនឹងអាចយល់អ្នកណាជាអចិន្ត្រៃយ៍ អ្នកណាជាមិនអចិន្ត្រៃយ៍នោះ បាទ។ ខ្ញុំឆ្លើយរួចមកហើយសំណួរនេះ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំអាចសង្ខេបនូវចម្លើយរបស់លោកមកវិញថា លោកមិនយល់ មិនអាចបែងចែកបានចំពោះពាក្យថា "គណៈអចិន្ត្រៃយ៍" និង "គណៈមជ្ឈិម" នោះទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវណាស់បាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក នង សុផង់។ ខ្ញុំអត់មានសំណួរអ្វីសម្រាប់សួរលោកទៀតទេ។ ហើយសូមអរគុណលោកប្រធាន សូមអរគុណ។

[១១:៤០:០៣]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អាកទូរ វែកគែន។ ខ្ញុំជាមេធាវីការពារក្តីលោក ខៀវ សំផន។ ខ្ញុំក៏មានសំណួរខ្លីៗដែលត្រូវចោទសួរលោក។ ខ្ញុំដឹងថា លោកប្រហែលជាធ្លាប់ឆ្លើយសំណួរនេះទៅហើយ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា បើតាមលោកដឹងនៅទីក្រុងភ្នំពេញក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលដែលលោកធ្វើការនោះ តើក្រសួងផ្សេងៗមានក្រុមការងាររបស់ខ្លួនសម្រាប់ធ្វើការបំភ័ន្តអក្ខរៈ ឬក៏បកប្រែទូរសារ ហើយនិងមានម៉ាស៊ីនទូរសារ ឬក៏ខ្សែទូរសារដោយខ្លួនឯងផ្ទាល់នៅតាមក្រសួងនីមួយៗទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ មិនមានទេបាទ។ ក្រសួងផ្សេងៗមិនមានក្រុមទូរលេខ ឬមួយក៏ក្រុមវាយទូរលេខ ទូរសារអីនោះទេ។ ដោយឡែកតែក្រសួងការបរទេស ខ្ញុំមិនច្បាស់ ហ្នឹងហើយបានខ្ញុំមិននិយាយទេណា។ តែក្រៅពីក្រសួងការបរទេសមួយ គឺមិនមានក្រសួងណាដែលមានអ្នកវាយទូរលេខ ឬបកប្រែទូរលេខនោះទេ គឺមានតែក្រសួងការពារជាតិទេ ដែលលោកមាន។ ហ្នឹងគឺមានច្រើនតែម្តង ទាំងជើងទឹក ជើងគោក ជើងអាកាសអី គឺលោកមានមធ្យោបាយគ្រប់បែប គ្រប់យ៉ាង ទាំងអ្នកវាយ អ្នកទាំងបក រហូតដល់ទូរស័ព្ទមានខ្សែ អត់ខ្សែអី គឺមានគ្រប់បែបគ្រប់យ៉ាងបាទ។

[១១:៤២:២២]

**ស៖** បាទ សូមអរគុណលោកសាក្សី។ លោកយល់ហើយ លោកសាក្សីថា តុលាការនេះមិនត្រឹមតែមានកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់លោកទេ។ យើងក៏មានទាំងខ្សែអាត់នៃការពិភាក្សា ដែលលោកបានពិភាក្សាជាមួយនឹងអ្នកស៊ើបអង្កេតតុលាការទៀតផង។ ចំពោះកិច្ចសម្ភាសន៍លើកដំបូងគឺថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ សូមទោស ២០០៩ គឺលេខ D200/3.11 ជាភាសាបារាំង--

**អ្នកបកប្រែ៖**

សូមអភ័យទោស លោកប្រធានសូមឲ្យលោកមេធាវីអានលេខ ERN ឡើងវិញ លោកប្រធាន។ ពីអ្នកបកប្រែ។

**សួរដោយលោក អាកឡូ វែកគែន៖**

**ស៖** ជាភាសាបារាំង 00843072, ជាភាសាអង់គ្លេស 00844067, ជាភាសាខ្មែរ 00838464។ លោកឆ្លើយថា "ខៀវ សំផន អត់មានទូរសារទេ។ គាត់ទាក់ទងតាមតែរយៈលិខិតសរសេរដៃ ឬក៏មិនអ៊ីចឹងទេ គាត់ទូរស័ព្ទពីមន្ទីររបស់គាត់មកខ្ញុំតែម្តង។ ហើយគាត់សុំឲ្យខ្ញុំធ្វើជាលិខិតហើយឲ្យខ្ញុំផ្ញើទៅតាមកន្លែងផ្សេងៗ"។ បន្ទាប់មកលោកបានពន្យល់ថា "បន្ទាប់ពីធ្វើការបកប្រែ ឬបំភ័ន្តអក្ខរៈរួចហើយ លោកបានផ្ញើចេញទៅក្រៅ"។ កាលពីថ្ងៃ២៩ ខែសីហា កន្លងទៅនេះ ក្រោយម៉ោង ១១:៥៧ នាទី នៅទំព័រ៥២ ជាភាសាបារាំង លោកបានឆ្លើយថា "សាររបស់ ខៀវ សំផន គឺត្រូវតែឆ្លងកាត់តាមមន្ទីររបស់លោក"។ តើលោកដឹងទេថា គឺៗមានន័យថា លោកជាអ្នកទទួលខុសត្រូវទៅលើសារទាំងអស់របស់លោក ខៀវ សំផន? តើអ៊ីចឹងមែនទេ?

[១១:៤៤:៥៧]

**លោក នង សុផង់៖**

**ផ៖** បាទ ចំពោះការទំនាក់ទំនងរវាងខ្ញុំ និងលោក ខៀវ សំផន និងក្រុមការងាររបស់លោកនៅសម័យនោះ គឺបើជាលិខិតលោកវាយអង្គុលីលេខរួចហើយ លោកផ្ញើសំបុត្រតាមរយៈនីរសារមកឲ្យកន្លែងយើងខ្ញុំ បំភ័ន្តអក្ខរៈ ឬមួយបើលោកមានការចាំបាច់ ឬប្រញាប់ ហើយបើសារហ្នឹងខ្លីៗអី លោកឬមួយក៏ក្រុមការងាររបស់លោក អាចធ្វើការទំនាក់ទំនងមកកន្លែងយើងខ្ញុំ តាមទូរស័ព្ទ ឬមួយក៏លោកក៏មានសិទ្ធិឲ្យគេយកសារអ្វីផ្សេងៗ របស់លោកទៅឲ្យក្រុមខាងក្នុង ឬ ក-១ រួចហើយបើមានសារអ្វីដែលទាក់ទងនឹងរឿងខាងខ្ញុំ ខាង ក-១ គេបញ្ជូនត្រឡប់មកខាងខ្ញុំនេះវិញ។ អ៊ីចឹងគឺមិនមែនគ្រប់តែសារ

នោះទេ ដែលលោកត្រូវតែឆ្លងកាត់ការិយាល័យរបស់ខ្ញុំ។ គឺលោកអាចមានសិទ្ធិទាក់ទងទៅក្នុងក្រុមខ្ញុំមួយទៀត ដែលនៅក្នុង ក-១ បានដែរ។ នេះបើសិនណាជាលោកមានសារអ្វី។

[១១:៤៧:១៨]

**ស៖** ខ្ញុំចង់ស្នើសុំការពន្យល់របស់លោក ពាក់ព័ន្ធទៅនឹងការបំភ័ន្តអក្ខរៈ។ ខ្ញុំចង់ដឹងថា តើពាក្យថា "បំភ័ន្តអក្ខរៈ" នេះមានន័យថាជាការបកប្រែទៅជា ម៉ស គឺមានន័យថានៅពេលដែលយើងអំពីបំភ័ន្តអក្ខរៈហ្នឹង គឺយើងសរសេចចេញតែជាលេខទេ ដើម្បីឲ្យសារហ្នឹងក្លាយទៅជាសម្ងាត់។ ដូច្នេះតើលោកមន្ទីររបស់លោកហ្នឹង មានភារកិច្ចក្នុងការបំលែង ពីសារកូដមកជាសារធម្មតា ឬក៏ពីត្រឹមតែពីសារធម្មតាទៅជាសារកូដ ដើម្បីឲ្យមានការសម្ងាត់នោះ?

**ឆ៖** បាទ មន្ទីររបស់ខ្ញុំគឺមានតួនាទីបំភ័ន្តអក្ខរៈ។ បំភ័ន្តអក្ខរៈហ្នឹងគឺបានន័យថា ខ្លឹមសារជាអក្សរ ជាសារលិខិតផ្សេងៗ គេយកមកប្រែតាមឯកសារសម្ងាត់ តាមតារាង១០០ក្រឡា ឲ្យទៅជាលេខកូដទាំងអស់បាទ មិនមែនចេញឃើញជាអក្សរទេ។ អាហ្នឹងហៅថាសារ មិនទាន់ទៅជាសម្ងាត់ទេ ឃើញៗជាលេខ។ អ៊ីចឹងមិនទាន់សម្ងាត់នៅឡើយទេ បើចង់ទៅជាសម្ងាត់ គឺទាល់តែទៅបង្វែងដានមួយជាន់ទៀត។ អានេះបានហៅថា ពេលដែលយើងចេញជាលេខបំលែងជាលេខមួយផ្សេងទៀតហើយ អាហ្នឹងបានហៅថាជាទូរលេខសម្ងាត់។ ឯរឿង ម៉ស ហ្នឹងគឺមិនមែនជាសារទូរលេខសម្ងាត់ទេបាទ។ ម៉ស ហ្នឹងគឺៗវាចេញជាអក្សរតែម្តង ទិចតាក់ ទិចៗតា អីហ្នឹង ចេញជាអក្សរ ក អ៊ីចឹងមក អានេះគឺម៉ស ហើយបាទ។ គេពុំបាច់បកប្រែបំភ័ន្តអក្ខរៈនៅលើសារ ម៉ស ហ្នឹងទេបាទ ព្រោះ ម៉ស ហ្នឹង វាចេញជាខ្លឹមសារ គេអាចអានបាន យល់បាន។ បាទ លោកយល់ច្បាស់ហើយនៅ?

[១១:៤៩:៥៨]

**ស៖** បាទ លោកសាក្សី គឺពាក្យសម្តីរបស់លោក ត្រូវបានបកប្រែជាភាសាអង់គ្លេស និងបារាំង។ ដូច្នេះ វាអាចមានភាពខុសគ្នារវាងអ្វីដែលលោកនិយាយ ហើយនិងអ្វីដែលខ្ញុំស្តាប់ឮជាភាសាបារាំង។ ហើយលោកបានឆ្លើយថា គេបានបកប្រែឲ្យខ្ញុំថា "ឡូម៉ស ម៉សហ្នឹង ជាលេខកូដសម្ងាត់" ហើយដល់តែពេលចុងក្រោយមកទៀត គេបកប្រែថា "ម៉ស" ហ្នឹងមិនមែនជាកូដសម្ងាត់ទេ។ ដូច្នេះមានភាពផ្ទុយគ្នារវាងអ្វីដែលលោកឆ្លើយ។ ចំពោះខ្ញុំអ្វីដែលខ្ញុំដឹងនោះ គឺថា ម៉ស ហ្នឹងជាភាសាអន្តរជាតិដែលអ្នកណាៗក៏គេស្គាល់ ហើយការបំលែងពាក្យ អត្ថបទសរសេរធម្មតាជាភាសាបារាំង ទៅជា ម៉ស ហ្នឹងគឺថាមិនមែនជាកូដសម្ងាត់អីទេ គឺថា គេបំលែងទៅជាលេខ ហើយតើអ្វីដែលខ្ញុំនិយាយនេះត្រឹមត្រូវ

ដែរឬទេ ពាក់ព័ន្ធទៅនឹង ម៉ស ហ្នឹង?

[១១:៥១:០៦]

**ឆ៖** បាទ រឿង ម៉ស ហ្នឹងគឺដូចលោកមានប្រសាសន៍អំមិញ ត្រឹមត្រូវហើយគឺជា ពុំមានជាលេខកូដសម្ងាត់ទេ គឺជាអក្សរធម្មតា ដែលអ្នកណាក៏គេមើលដឹង គេយល់។ ឧទាហរណ៍ បើអស់លោកខាងបារាំង អង់គ្លេស គេវាយទិចៗតា មកចេញជាឧបមាថា កម្ពុជា លោកឃើញកម្ពុជាជាអក្សរឡាតាំងហ្នឹងស្រេចតែម្តង មិនបាច់លោកទៅបកអីនាំឈឺក្បាលទេបាទ។ ម៉ស របស់ខ្ញុំដែលប្រើគឺមាន ពីរប្រភេទ ម៉ស ដែលចេញមកជាអក្សរខ្មែរ និង ម៉ស ចេញមកជាអក្សរឡាតាំង គឺអក្សរបារាំង អង់គ្លេសហ្នឹងហើយ។ អ្នកខាងផ្នែកវាយទូរលេខនោះ គឺចេះទាំងម៉សខ្មែរ ទាំងម៉សសកល បាទ។

**ស៖** សូមអរគុណចំពោះចម្លើយដ៏ច្បាស់លាស់នេះ ដែលបានបំភ្លឺឱ្យខ្ញុំយល់។ ខ្ញុំចង់សួរលោកថា អ្វីដែលលោកហៅអម្បាញ់មិញនេះថា ជាលិខិតចំហានោះ គឺជាសំបុត្រដែលមិនសម្ងាត់ លោកនិយាយអំពីលិខិតមកពីលោក ខៀវ សំផន ថាជាលិខិតចំហានោះ។ ខ្ញុំដូចជាមិនសូវយល់ តើលោកចង់បានន័យថា ម៉េចលិខិតចំហហ្នឹង?

[១១:៥៣:០៦]

**ឆ៖** បាទ លិខិតចំហហ្នឹងចង់និយាយថា សារហ្នឹងមិនមែនជា ការសម្ងាត់អីណាស់ណាទេ គឺគ្រាន់តែជាការបែងចែកសម្ភារៈនេះ សម្ភារៈនោះ ដើម្បីឱ្យភូមិភាគហ្នឹងគេបានដឹងថា កន្លែងរបស់គេបាន -- មានសម្ភារៈអ្វីខ្លះដែលខាងលើបញ្ជូនទៅហ្នឹង ចំនួនប៉ុន្មាន ហើយគេជូនទៅថ្ងៃណាខែណាអីអាហ្នឹង ហើយឱ្យអស់លោកភាគីម្ខាងទៀតហ្នឹងរង់ចាំទទួលនៅឯណាៗ។ អានេះមិនជាបញ្ហាអីទាក់ទងដល់សារសម្ងាត់ដែលត្រូវបង្វែងដាន រហូតដល់ពីរបីជាន់ទេបាទ។ ជួនណាគេគ្រាន់តែបំលែងពីអក្សរធម្មតា ឱ្យទៅជាលេខកូដ ហើយវាយបញ្ជូនទៅតែម្តងក៏បានបាទ។ មិនបាច់បង្វែងដានច្រើនលើក ច្រើនជាន់បីបួនតង់ទេ នេះជាសារលក្ខណៈបែបនេះ។ ឯសារចំហមួយទៀត ដែលខ្ញុំនិយាយថា លិខិតចំហហ្នឹង ឧទាហរណ៍ថា លោកមានសេចក្តីថ្លែងការណ៍ សេចក្តីណែនាំអ្វីជាចំហ ដើម្បីអ្នកទាំងអស់ហ្នឹងស្តាប់ឮទូទៅ ក៏គេអាចវាយជាម៉សខ្មែរបានដែរបាទ។

[១១:៥៥:០៥]

ឧទាហរណ៍ថា ណែនាំពីរឿងធ្វើបុណ្យទានឱ្យគ្រប់មូលដ្ឋាន គ្រប់អង្គភាព រង់ចាំស្តាប់សេចក្តីថ្លែងការណ៍របស់លោកគណៈប្រធានរដ្ឋខៀវ សំផន អាហ្នឹងអីចឹងៗ ឧទាហរណ៍អីចឹង។ អាហ្នឹងគេជា

-- គឺជាសារលិខិតចំហ ដែលសម្រាប់ផ្សព្វផ្សាយនៅទូទាំងប្រទេស រហូតដល់គេអាចដឹងទាំងអន្តរជាតិខាងក្រៅប្រទេសក៏ដឹងបានដែរ។ ហ្នឹង លក្ខណៈហ្នឹងគេមិនចាំបាច់បំភ័ន្តអក្ខរៈអីទេ គេអាចវាយជា ម៉ស ក៏បាន។ បាទ នេះជាលក្ខណៈសម្ងាត់ និងមិនសម្ងាត់ ដែលបានជម្រាបជូន។ សូមលោកជ្រាប។

**ស៖** សូមអរគុណ។ ហើយលិខិតរបស់ -- លិខិតប្រភេទនេះក៏ត្រូវឆ្លងតាមផ្នែករបស់លោកដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អានេះគេហៅថា សារាចរណែនាំ។ ណែនាំហ្នឹងគឺ រាល់ពេលដែលលោករៀបចំធ្វើសេចក្តីថ្លែងការណ៍នៅពេលឱកាសឆ្នាំ -- ចូលឆ្នាំខ្មែរក្តី ឱកាសបុណ្យសាកលក្តី មុននឹងនេះ គឺលោកមានធ្វើសារាចរមួយដែរ ដើម្បីឱ្យបងប្អូនយើងនៅតាមមូលដ្ឋាននានាបានស្តាប់នូវសេចក្តីថ្លែងការណ៍របស់លោក។

[១១:៥៧:១៣]

**ស៖** ហើយសារាចរណែនាំហ្នឹងគឺឆ្លងតាមមន្ទីររបស់លោក តើអ៊ីចឹងទេ?

**ឆ៖** បាទ ភាគច្រើនរឿងការណែនាំអីលោកអាចចូលទៅ ក-១ ឱ្យគេចាត់ចែងថា ត្រូវធ្វើទៅណាៗខ្លះអី ហើយបានគេយកមក -- ពីព្រោះគេខាង ក-១ គេចាត់ចែងរួម គេដឹងថា ទិសណាដែលមាននៅខ្ញុំ ទិសណានៅគេ។ អ៊ីចឹងរឿងមួយហ្នឹង គឺគេអាចជូនបានគ្រប់ទិសទាំងអស់នៅទូទាំងប្រទេស។ ក៏ប៉ុន្តែទិសខ្លះវានៅខ្ញុំកាន់ ទិសខ្លះវានៅខាងក្នុងកាន់ អ៊ីចឹងគឺសេចក្តីសារាចរហ្នឹង គឺត្រូវឆ្លងតាម ក-១ សិន។ ឯរឿងសម្ភារៈ រឿងផ្តល់សម្ភារៈអីផ្សេងៗ គឺប្រាកដក្រុមការងាររបស់លោកប្រាកដថា គឺក្រុមខ្ញុំហ្នឹងហើយ មិនបាច់ឆ្លងទៅ ក-១ ក៏បានដែរ។

[១១:៥៧:៤២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ច្បាស់ហើយ។ ខ្ញុំចង់ដឹងថា តើនៅពេលដែលលោកធ្វើការនៅទីក្រុងភ្នំពេញនោះ មានការមិនទុកចិត្តទៅលើទូរស័ព្ទដែរឬទេ? ខ្ញុំចង់មានន័យថា អាចមានអ្នកណាម្នាក់ផ្ញើសារសម្ងាត់តាមទូរស័ព្ទ ឬមួយក៏គាត់ចង់ឱ្យ -- ប្រគល់ជាលិខិតផ្ទាល់ដៃតាមរយៈនីរសារវិញ មានន័យថា គេមិនទុកចិត្តទេការទាក់ទងគ្នាតាមទូរស័ព្ទអីអ៊ីចឹង។ តើមានអ៊ីចឹងទេលោកសាក្សី?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរបាទ។

**លោក អាកទ្វរ វែកគែន៖**

លោកប្រធាន ឥឡូវនេះពេលថ្ងៃត្រង់ហើយ ដោយសារខ្ញុំត្រូវចូលទៅប្រធានបទផ្សេងទៀត

ដូច្នេះតើលោកប្រធានត្រូវសម្រាកឬយ៉ាងណា?

[១១:៥៩:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទឥឡូវនេះដល់ពេលសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសាក្សីលោក នង សុផង់ តើរសៀលនេះលោកតាមប្រមើលមើល៍សុខភាពរបស់លោកអាចបន្តផ្តល់សក្ខីកម្មបានទេនៅរសៀលនេះ?

**លោក នង សុផង់៖**

បាទ លោកប្រធាន ខ្ញុំសុខភាពមិនប្រក្រតីមែន ប៉ុន្តែតាមទឹកចិត្តរបស់ខ្ញុំ គឺខ្ញុំនឹងពុះពារធ្វើតាមការកំណត់របស់អង្គសវនាការបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ ហើយនិងអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងមួយសាមសិបនាទី។ ហើយលោកសូមពិនិត្យផងដែរថា បើមានភាពចាំបាច់នោះគឺលោកអាចជូនគាត់ទៅជួបលោកគ្រូពេទ្យដើម្បីអាចពិនិត្យ និងផ្តល់ដំបូន្មានផ្នែកខាងសុខភាពដល់គាត់មុនពេលបន្តដំណើរការសវនាការនៅរសៀលនេះ។

សូមអញ្ជើញលោកមេធាវី!

[១២:០១:៣៤]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំបានជម្រាបមកខ្ញុំថា គាត់មានបញ្ហាឈឺក្បាល ឈឺខ្នង ឈឺចង្កេះ និងមិនអាចផ្តង់អារម្មណ៍បាន។ ហើយដោយសារហេតុផលទាំងអស់នេះ កូនក្តីខ្ញុំស្នើសុំអនុញ្ញាតដើម្បីធ្វើការតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោម ហើយយើងខ្ញុំនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិនេះជូនទៅអង្គជំនុំជម្រះ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយយូរតាមដាននៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការដោយផ្ទាល់បាន។ ហើយសំណើសុំរបស់លោក នួន ជា ហ្នឹងធ្វើឡើងមានមូលហេតុសមស្រប ដូច្នេះ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១រសៀលនេះ។ ហើយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។

[១២:០២:៤៤]

អង្គជំនុំជម្រះតម្រូវឲ្យលោកមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក នួន ជា ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់គាត់។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញ១យរសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម។ ដោយឡែកនៅរសៀលនេះទុកលោក នួន ជា ឲ្យនៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន បង្គាប់ឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោកសាក្សី ខ្ញុំនឹងបន្តចោទសំណួរពីរបីទៀត បាទខ្ញុំមិនចំណាយពេលវេលាយូរនោះទេ។ បាទ លោកបានជម្រាបជូន -- សូមលោកជម្រាបជូនដល់តុលាការថា មានការបែងចែកដាច់ពីក្រុមអ្នកបកប្រែបញ្ចូលអក្ខរាសម្ងាត់នៅផ្នែកខាងក្នុង និងផ្នែកខាងក្រៅ ហើយលោក ក្នុងឋានៈលោកជាអ្នកធ្វើការនៅខាងក្រៅ តើលោកដឹងអ្វីដែលកើតមានឡើងនៅក្នុងក្រុមខាងក្នុងដែរឬទេ? តើលោកដឹងពីស្ថានភាពនៃក្រុមខាងក្នុងដែរឬទេ?

[១៣:៣២:០៤]

**លោក នង សុផង់៖**

**ផ៖** បាទ ពុំបានដឹងទេ។

**ស៖** បាទ ដូច្នេះលោកមិនដឹងពីអ្វីដែលក្រុមខាងក្នុងធ្វើនោះទេ។ លោកមិនដឹងថា នៅក្នុងខ្លឹមសារសារទាំងអស់នៃក្រុមខាងក្នុងធ្វើនោះជាអ្វីនោះទេ។ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ អ៊ីចឹងមែន។ មិនដឹងជាថា ក្រៅពីគេធ្វើសារទូរលេខ តើពេលទំនេររួចពីការងារគេទៅធ្វើអីទៀតៗ ដូចជាខាងខ្ញុំ ថាពេលទំនេរ ខ្ញុំ ភារកិច្ចខ្ញុំវាច្រើនមុខ។ តាំងពីបង្រៀន តាំងពីបកសារ តាំងពីការបង្រៀនលេខអក្សរអី អានេះវាច្រើនផ្នែក។ ប៉ុន្តែខាងគេ ខាងក្នុងខ្ញុំក្តាប់មិនបានបាទ។

[១៣:៣៣:២២]

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំសូមការបំភ្លឺមួយនៅពេលដែលចៅក្រមស៊ើបអង្កេតបានសួរលោក ហើយនិងនៅក្នុងតុលាការនេះផងដែរ លោកបានជម្រាបថា ជួនកាលនៅពេលដែលលោក ខៀវ

សំផន ផ្ញើសារមួយចំនួនមកឲ្យលោកបំភ័ន្តអក្ខរៈ គឺថាដោយប្រើនីរសារបញ្ជូនមកឲ្យលោក ហើយមិនបានទូរស័ព្ទមកលោកទេ គឺកាលនោះ គឺថាមានលោក សំ ដែលជានីរសារនៅមន្ទីរ ក-១ បាននាំសារទាំងនោះមកឲ្យលោករហូតដល់ មកដល់ការិយាល័យរបស់លោកតែម្តង។ តើលោកចាំដែរឬទេ?

**ឆៈ** បាទ ចាំថាមានក្រុមនីរសាររបស់លោក សំ អ៊ីចឹងមែនបាទ។

[១៣:៣៤:២៩]

**សៈ** បាទ អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាអម្បាញ់មិញនេះលោកនិយាយថា ខៀវ សំផន អាចប្រើសេវាកម្មនៅមន្ទីរ ក-១ ដើម្បីផ្ញើសារទូរលេខ។ តើនៅពេលដែលលោកនិយាយអ៊ីចឹងប្រាប់ខ្ញុំអម្បាញ់មិញនេះ លោកចង់និយាយថា គឺ សំ ដែលធ្វើការនៅមន្ទីរ ក-១ ហ្នឹងហើយដែលនាំយកសារជាលាយលក្ខណ៍អក្សរមកឲ្យលោក។ តើនៅពេលដែលលោកប្រាប់ខ្ញុំព្រឹកមិញនេះ លោកចង់និយាយពីរឿងហ្នឹងឬក៏យ៉ាងម៉េច?

**ឆៈ** បាទ ខ្ញុំចង់និយាយប្រាប់អំពីការទំនាក់ទំនងរវាងសារ ដែលពីខាងលោក ខៀវ សំផន និងក្រុមការងាររបស់លោកអាចជូនសារមកខាងខ្ញុំនេះ តាមមធ្យោបាយម្យ៉ាងតាមទូរស័ព្ទក៏បាន ហើយម្យ៉ាងទៀតក៏លោកមាននីរសារដែលអាចជូនតាមរយៈក្រុម សំ យកមកឲ្យខាងខ្ញុំក៏បាន។ ហើយឬបើអ្វីដែលប្លែកក្រៅពីរឿងចាត់ចែងសម្ភារៈ លោកក៏អាចចាត់ចែងចូលទៅ ក-១ សិន ដើម្បី ក-១ គេចាត់ចែងបន្តមកអាណាដែល ទិសណាដែលជាទិសរបស់ខ្ញុំ ហើយទិសណាដែលគេផ្ញើនៅ ក-១ បាទ។ អ៊ីចឹងមែនបាទ ដែលខ្ញុំបាននិយាយ។

[១៣:៣៦:២៥]

**សៈ** បាទ សូមអរគុណ។ ក៏ប៉ុន្តែលោកមិនដឹងអ្វីផ្សេងក្រៅទៀតទេ ពីរឿងសាររបស់លោក ខៀវ សំផន ដែលថាអាចផ្ញើទៅមន្ទីរ ក-១ ដែលលោក ដែលថាគេមិនបានបញ្ជូនសារនោះទៅឲ្យក្រុមលោកនោះ អ៊ីចឹងមែនទេ?

**ឆៈ** អ្វីផ្សេងក្រៅពីទាក់ទងនឹងរឿងសារទូរលេខ អ្វីផ្សេងក្រៅពីមតិណែនាំជារួមដែលត្រូវបញ្ជូនតាមសារទូរលេខ អ្វីផ្សេងទៀតខ្ញុំពុំដឹង ខ្ញុំពុំអាចដឹងបានទេ។

**សៈ** បាទ ខ្ញុំសូមប្តូរប្រធានបទ។ លោកបានជម្រាបជូនតុលាការថា កាលពីម្សិលមិញនេះ ហើយព្រឹកមិញក៏លោកបាននិយាយផងដែរ ឆ្លើយតបទៅនឹងសំណួរមួយចំនួនដែលគេសួរទៅកាន់រហូតដល់ពេលនេះហ្នឹង។ គឺថាលោកធ្លាប់ដាក់ចម្លងជូនឈ្មោះនៅខាងក្រោមគេឡើក្រោមហ្នឹង ឈ្មោះទូរលេខ

មួយចំនួនហ្នឹង ដាក់ចម្លងជូនឈ្មោះមួយចំនួន ដែលថាចម្លងជូន ហើយយើងបាននិយាយពីបញ្ហាចម្លងជូននេះច្រើនហើយប៉ុន្មានថ្ងៃកន្លងមកនេះ។

[១៣:៣៨:០១]

ក៏ប៉ុន្តែតុលាការពុំមានទូរលេខទាំងអស់នោះទេ ទូរលេខដែលលោកបានបកប្រែកាលពីចន្លោះឆ្នាំ ៧៥ ដល់ ៧៩ ហើយកាលពីម្សិលមិញនេះផងដែរ លោកក៏បាន លោកបាននិយាយថា លោកបានដុតឯកសារចោលទាំងអស់ ទូរលេខទាំងអស់។ ដូច្នេះសំណួរខ្ញុំដូចតទៅនេះ តើនេះជាទម្លាប់របស់លោកថាក្នុងការដាក់បញ្ជីឈ្មោះអ្នកដែលយើងចម្លងជូន លើកលែងតែពេលដែលថា ប៉ុន ឬក៏មន្ទីរ ក-១ ហ្នឹងប្រាប់មកលោកថា កុំឲ្យដាក់ឈ្មោះមួយចំនួន ពីព្រោះថាអ្នកទាំងអស់នោះមិននៅភ្នំពេញទេ។ តើលោកអាចជម្រាបជូនបានដែរឬទេ អំពីបញ្ជីដែល -- បញ្ជីឈ្មោះអ្នកដែលលោកៗ ធ្លាប់តែធ្វើជូនទៅនោះចម្លងជូននោះ? បើតាមការចងចាំរបស់លោក ជាតាមទម្លាប់របស់លោកនោះ តើក្នុងបញ្ជីឈ្មោះដែលមានពាក្យថា “ចម្លងជូន” ហ្នឹង ឈ្មោះណាខ្លះដែលលោកធ្លាប់តែប្រើបញ្ជូនទូរលេខទៅនោះ?

[១៣:៣៩:១៣]

**ឆ៖** បាទ ជាទូទៅក្នុងសម័យហ្នឹងពាក្យ “ចម្លងជូន” ដូចដែលអស់លោកបានឃើញហូរហែមកហើយ គឺមាន អ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, អ៊ំ ខៀវ, មន្ទីរ និងឯកសារ។ គឺបើយ៉ាងច្រើនបំផុត គឺមានតែប្រាំពីរសន្លឹកហ្នឹងទេ -- បាទមានប្រាំពីរសន្លឹកទេ អាណាដែលមិនដិតហ្នឹង គឺឯកសារទុកនៅកន្លែងរបស់ខ្លួន តាមកន្លែងបកប្រែ។ ក៏ប៉ុន្តែបើមានអ៊ំណាមិននៅ គឺគេអាចដឹងថា គេអាចដឹងថាក្នុងរយៈនេះ ឧបមាថា មានអ៊ំ អៀង សារី គាត់ទៅបំពេញទស្សនកិច្ច នៅក្រៅប្រទេស ឬមួយក៏ អ៊ំ សុន សេន គាត់ធ្វើប្រតិបត្តិការនៅភូមិភាគបូព៌ាអីអីចឹងហើយ គេនឹងប្រាប់ថា ចាប់ពីថ្ងៃនេះតទៅហ្នឹង មិនបាច់ដាក់ជូន អ៊ំ ខៀវ ឬអ៊ំ អៀង សារី ទៀតទេបាទ មានករណីអីចឹងដែរ។ ព្រោះគេច្បាស់ហើយ ដើម្បីបញ្ជាឲ្យយើងវាយចម្លងជូនហ្នឹង ឲ្យហើយ កុំពិបាកជាពីរបីសា។

[១៣:៤០:៥១]

**ស៖** បាទ សូមអរគុណ។ អានេះ ខ្ញុំយល់ហើយ អ្វីដែលលោកបាននិយាយនេះ ក៏ប៉ុន្តែអម្បាញ់មិញនេះ ខ្ញុំចង់ឲ្យលោករំឭកឡើងវិញ។ អម្បាញ់មិញនេះ លោកបានឲ្យឈ្មោះបី គឺឈ្មោះ នួន, វ៉ាន់ ហើយនិង ខៀវ។ តើលោកអាចព្យាយាមរំឭកឲ្យបានលើសពីហ្នឹង ថាឈ្មោះរបស់អ្នកដែលគេចម្លងជូននៅក្នុងទូរលេខហ្នឹង ហើយយើងបាននិយាយពីបញ្ហានេះកន្លងមក លោកអត់បាននិយាយពីឈ្មោះ ប៉ុល

ពត នោះទេ តើលោកអាចព្យាយាមរំឭកឲ្យច្រើនជាងហ្នឹង ឲ្យឈ្មោះបងៗទាំងអស់ ដែលលោកដាក់ចម្លងជូន ដែលលោកចម្លងជូនជាប្រចាំនោះ?

**ឆ៖** បាទ ខ្ញុំជម្រាបលោកថាដល់ប្រាំពីរសន្លឹកសារជាធម្មតាហ្នឹង។ មាន អ៊ំ ដំបូងគេបំផុត គឺ អ៊ំ, អ៊ំ ទទេ នេះ គឺមានន័យថា អ៊ំ ប៉ុល ពត ហ្នឹងហើយមុនគេ។ អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, អ៊ំខៀវ ហ្នឹង ខៀវ មិនមែខ ខៀវ សំផន ទេ គឺ សុន សេន, មន្ទីរ ឯកសារ។ ជាទូទៅ បើអត់មានអ្វីខុសធម្មតាទេ គឺហ្នឹង សារទូទៅ គឺត្រូវវាយដល់ប្រាំពីរសន្លឹកនោះបាទ។

**ស៖** បាទ សូមអរគុណ។ តើជាការត្រឹមត្រូវដែរឬទេ នៅពេលដែលខ្ញុំនិយាយថា ច្បាប់ចម្លងទីប្រាំពីរនេះ គឺជាច្បាប់ដែលលោករក្សាទុកសម្រាប់លោកផ្ទាល់ តើអ៊ីចឹងមែនទេ ជាការត្រឹមត្រូវទេ?

[១៣:៤២:៤៨]

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ។

**ស៖** ចន្លោះឆ្នាំ១៩៧៥ ៧៩ តើលោកធ្លាប់ទទួលសេចក្ដីណែនាំក្នុងការបន្ថែមឈ្មោះហៅក្រៅរបស់ លោក ខៀវ សំផន នោះនៅក្នុងបញ្ជីឈ្មោះ អ្នកដែលយើង -- ដែលលោកចម្លងជូនដែរឬទេ?

**ឆ៖** បាទ មិនមានអ្វី ក្រៅពី ហែម និង ខៀវ សំផន ត្រង់ៗនោះទេ បាទ។

**ស៖** បាទ សំណួរអម្បាញ់មិញនេះ គឺថាចង់ដឹងថា ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ៧៩នេះ លោកចង់ដឹងថា លោកធ្លាប់បានចម្លងជូនទៅលោក ខៀវ សំផន ឬក៏ ហែម នូវរាល់ទូរលេខដែលលោកបានបកប្រែ។ តើលោកធ្លាប់បានដាក់ឈ្មោះ លោក ខៀវ សំផន ឬក៏ឈ្មោះ ហែម ដែលជាឈ្មោះហៅក្រៅរបស់គាត់នោះ វាដូចតែគ្នាទេ ឈ្មោះពីរហ្នឹង លោកធ្លាប់ដាក់ចម្លងជូនទៅឈ្មោះគាត់ទេ?

[១៣:៤៤:២០]

**ឆ៖** បាទ រាល់សារដែលក្រុមខ្ញុំធ្វើ គឺមិនដែលមានឃើញ គេណែនាំថា បងហែម ឬមួយក៏ ខៀវ សំផន ដូច្នេះទេ។ គឺមានឃើញតែប៉ុន្មាននាក់ ឯក្រៅពីហ្នឹង គឺមន្ទីរ, ឯកសារ។ គឺមានប្រាំ ដែលឃើញញឹក ដែលគេឲ្យដាក់ញឹកញាប់ មានអ៊ំ គឺអ៊ំប៉ុល ពត, នួន ជា, អៀង សារី គឺអ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, អ៊ំខៀវ។ បាទ នេះដែលឈ្មោះសម្រាប់សម្គាល់មនុស្ស ឯពីរទៀត គឺមន្ទីរ, ឯកសារ អានេះមិនសំដៅមនុស្សទេ។ ឯមនុស្សដែលមានជាធម្មតាប្រាំ។

**ស៖** ខ្ញុំសូមប្រាប់ឈ្មោះចំនួនបី ហើយនិងសុំយោបល់ពីលោក ចង់ដឹងថាលោកចាំឈ្មោះអ្នកទាំងបីហ្នឹងឬក៏អត់ ថាតើឈ្មោះទាំងបីហ្នឹងធ្លាប់គេបញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកដែលគេចម្លងជូន។ តើ

លោកចាំទេ ថាលោកធ្លាប់បានចម្លងជូនទៅឈ្មោះ កុយ ធួន ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនចងចាំទេ។ ហើយក៏សារដែលគេចម្លងតាដាក់ជូន កុយ ធួន ហ្នឹងវាមិនមានច្រើន បាទមិនមានជាគោលការណ៍ណែនាំដូចខ្ញុំបានរៀបរាប់ខាងលើហ្នឹងទេ។

**ស៖** តើលោកចាំថាលោកធ្លាប់ចម្លងជូន ណៃ សារ៉ាន់ ហៅ--

**អ្នកបកប្រែ៖**

លោកប្រធានខ្ញុំស្ដាប់ឈ្មោះៗហៅក្រៅអត់បានទេ លោកប្រធាន។ សូមឲ្យគាត់និយាយម្ដងទៀត។

[១៣:៤៦:៤៨]

**សួរដោយលោក អាកទូរ វ៉ែកគែន៖**

**ស៖** ខ្ញុំមិន -- អានឈ្មោះម្ដងទៀត ព្រោះថាខ្ញុំអានមិនត្រឹមត្រូវ។ បាទ ឈ្មោះ ណៃ សារ៉ាន់ ហៅ យ៉ា បាទ។ លោកចាំទេ ថាធ្លាប់បានចម្លងជូនទៅ ណៃ សារ៉ាន់ ហៅ យ៉ា នេះ?

**លោក នង សុផង់៖**

**ឆ៖** បាទ គ្មានទេ បាទ។

**ស៖** ចុះលោក កែ ពក វិញ ធ្លាប់បានផ្ញើជូនគាត់ទេ?

**ឆ៖** កែ ពក គឺមិនដែលបានចម្លងជូន កែ ពក នោះទេ គឺមានតែហត្ថលេខា ពក អ៊ីចឹងតែម្ដង គឺជាអ្នកផ្ញើជូនគេវិញទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនទៀត។ ខ្ញុំចង់ដឹងថា នៅក្នុងរយៈកាលដែលលោកធ្វើការនៅក្នុងទីក្រុងភ្នំពេញ លោកត្រូវទទួលសារទូរលេខដែលត្រូវបកប្រែតែពីឈ្មោះ ថាមានឈ្មោះដែលថាទទួលសារមកពីខាងក្រៅ ហើយផ្ញើជូនលោក ខៀវ សំផន នៅជួរទី១ គឺថាអាចឈ្មោះគាត់ផ្ទាល់ ឬក៏ឈ្មោះហៅក្រៅរបស់គាត់ ថាគាត់ជាអ្នកទទួលឯកសារ។ តើលោកធ្លាប់បកប្រែសារទូរលេខនៅចន្លោះឆ្នាំ១៩៧៥ និង៧៩ នេះទេ ឯកសារដែលថាផ្ញើជូនទៅលោក ខៀវ សំផន ដោយផ្ទាល់?

[១៣:៤៨:៣៩]

**ឆ៖** បាទ មិនដែលឃើញទេ។ មិនដែលឃើញឈ្មោះគាត់ផ្ទាល់ ឬឈ្មោះក្រៅរបស់គាត់ ហែមហ្នឹងគឺ មិនដែលឃើញគេដាក់ថាចម្លងជូនសោះតែម្ដង។

**ស៖** ខ្ញុំចង់ដឹង បើតាមលោកចាំនៅចន្លោះឆ្នាំ១៩៧៥ និង៧៩ ខ្ញុំចង់ដឹងថាតើលោកបានសង្កេត

ឃើញមានការប្រែប្រួលនៅក្នុងប្រធានបទនៃខ្លឹមសារនៃសារដែលលោក ខៀវ សំផន ឲ្យលោកបកប្រែ ឬក៏ដាក់ជាអក្ខរាសម្ងាត់ បំភ័ន្តអក្ខរា? លោកបាននិយាយជម្រាបជូនតុលាការថា អំពីការថាការងាររបស់លោក ខៀវ សំផន ទាក់ទងទៅនឹងការចែកសម្ភារៈ ហើយនិងចេញជាវិធានការនៅក្នុងពេលមានបុណ្យទាននានា តើចន្លោះឆ្នាំ១៩៧៥-៧៩ នោះ តើលោកធ្លាប់បានសង្កេតឃើញការវិវត្តនៃប្រធានបទរបស់សាររបស់លោក ខៀវ សំផន ដែលគាត់សុំឲ្យលោកហ្នឹងបំភ័ន្តអក្ខរៈ នៅក្នុង -- បំលែងទៅទូរលេខនោះ។ តើលោកធ្លាប់សង្កេតឃើញការប្រែប្រួលនេះទេ?

**ឆ៖** ខ្ញុំមិនមានអ្វីប្លែកដែលឃើញថា ការប្រែប្រួលរបស់សាររបស់គាត់ហ្នឹងទេ អត់ដែលឃើញអ្វីដែលប្លែកក្រៅពីហ្នឹងដែរ។

[១៣:៥០:៥៣]

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមចោទសំណួរទៅលោកមួយចំនួនទៀត គឺថាមិនទាក់ទងទៅនឹងសក្ខីកម្មលោកប៉ុន្មាននេះទេ ក៏ប៉ុន្តែទាក់ទងទៅនឹងរបៀបនៃការសម្ភាសរបស់លោក ការសម្ភាសដោយអ្នកស៊ើបអង្កេតរបស់តុលាការយើងនេះ។ នៅពេលដែលខ្ញុំអានការ -- ខ្សែអាត់លើកទី១ របស់លោកដែលកើតឡើង សន្មតថាកើតឡើងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលជា -- ហើយកាលបរិច្ឆេទនៃខ្សែអាត់នោះគឺអ៊ីចឹង។ ហើយក៏ប៉ុន្តែខ្ញុំសង្កេតឃើញថា នៅពេលណាមួយនោះ អ្នកស៊ើបអង្កេតម្នាក់សួរប្រាប់និយាយទៅកាន់លោក ហើយនៅក្នុងឯកសារ D200/3.11 ដែលជាខ្សែអាត់ គឺនៅទំព័រទី១ ERN ជាភាសាបារាំងគឺថា 00843061, អង់គ្លេស 00844056, ជាភាសាខ្មែរគឺ 00838453។ បាទ ដូច្នេះ ខ្ញុំសូមអានផ្នែកមួយនៅក្នុងទំព័រនេះ អ្នកស៊ើបអង្កេតនិយាយថា "ម្សិលមិញ លោកបាននិយាយអំពីប៉ង់"។ សំណួរខ្ញុំដូចតទៅនេះ តើលោកបានចាំថា នៅមុនថ្ងៃទី១៨ កុម្ភៈ ២០០៩ មួយថ្ងៃនេះ លោកក៏បានជួបអ្នកស៊ើបអង្កេតរបស់តុលាការយើងនេះដែរ។ តើលោកចាំទេ លោកថាមុនថ្ងៃហ្នឹងមួយថ្ងៃលោកបានជួយពួកគាត់?

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំប្រធាន ខ្ញុំសូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! សាក្សីកុំអាលទាន់ឆ្លើយ!

[១៣:៥៣:២០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំគិតថា វាហាក់ដូចជាមានគ្រោះថ្នាក់បន្តិច នៅពេលដែលយើងលើកយកមកបញ្ហាបែបនេះ។ ខ្ញុំមិនមែនចង់ចោទប្រកាន់ទៅលើសហភាតារបស់ខ្ញុំទេ ប៉ុន្តែចំណុចមួយដែលខ្ញុំចង់និយាយគឺថា តាមពិតទៅកំណត់ត្រា E3/64 ហ្នឹង គឺបានចង្អុលបញ្ជាក់ច្បាស់ថា ការសម្ភាសហ្នឹងគឺបានធ្វើរយៈពេល២ថ្ងៃ។ ខ្ញុំបានកត់សម្គាល់ឃើញថា ប្រតិចារឹកគឺដាក់ថ្ងៃ១៨ ខែកុម្ភៈ ប៉ុន្តែយើងមិនដឹងថា កាលបរិច្ឆេទហ្នឹងមកពីកន្លែងណានោះទេ។ ដូច្នេះ ខ្ញុំចង់ឲ្យសហភាតាខ្ញុំធ្វើការដោយប្រុងប្រយ័ត្ន ដោយសារតែយើងមិនដឹងថាតើការពិភាក្សាហ្នឹងនិយាយ ដូចថា និយាយថាពីម្សិលមិញហ្នឹង សំដៅទៅថ្ងៃ១៨ ឬក៏១៩។ ដូច្នេះខ្ញុំមិនប្រាកដថា សាក្សីចាំ ឬមិនចាំនោះទេ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយ គឺចង់ឲ្យមានការបញ្ជាក់ទៅលើបញ្ហានេះ។ សូមអរគុណ។

**លោក អាកទួរ វែកកែន៖**

ខ្ញុំមិនយល់ការកត់សម្គាល់របស់សហព្រះរាជអាជ្ញាច្បាស់នោះទេ។ ខ្ញុំសូមឆ្លើយទៅគាត់ថា វគ្គដែលមានសរសេរថា ការស្តាប់ចម្លើយគាត់នេះ ប្រព្រឹត្តទៅអស់រយៈ២ថ្ងៃ ប្រហែលជានេះអាចថាជាចម្លើយ ដែលខ្ញុំឆ្លើយទៅតបលោកសហព្រះរាជអាជ្ញា។

[១៣:៥៤:៥៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំរីករាយនឹងជួយដល់លោក។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយទី១ ដែលមាន ERN ខ្មែរគឺលេខ 00328029, ភាសាបារាំងគឺមានលេខ 00411698 និងភាសាអង់គ្លេសគឺមានលេខ 00334048 គឺមានបញ្ជាក់យ៉ាងច្បាស់ អំពីការផ្អាកកិច្ចសម្ភាសន៍នៅថ្ងៃទី១៨ ហើយបន្តទៅថ្ងៃទី១៩ បន្តទៅទៀត។ ហើយជាក់ច្បាស់ថាកំណត់ត្រាហ្នឹងគឺមានចុះហត្ថលេខានៅថ្ងៃទី១៩ ខែកុម្ភៈ គឺនៅទំព័រចុង --ទី២ បន្ទាត់ចុងក្រោយ ដែលមានបញ្ជាក់ច្បាស់ទៅលើកាលបរិច្ឆេទនេះ។

**លោក អាកទួរ វែកកែន៖**

បាទ ពិតជាត្រឹមត្រូវណាស់ លោកសហព្រះរាជអាជ្ញា។

**សួរដោយលោក អាកទួរ វែកកែន៖**

**ស៖** បាទ ខ្ញុំមានសំណួរមួយទៀត ទាក់ទងនឹងប្រធានបទនេះដដែលលោកសាក្សី។ តើលោកចាំថានៅពេលណា កាលបរិច្ឆេទណា ដែលកំណត់ហេតុស្តាប់ចម្លើយរបស់លោកចុះថ្ងៃទី១៨ កុម្ភៈ ឆ្នាំ

២០០៩ នោះត្រូវបានអាចជូនលោក ដើម្បីឲ្យលោកចុះហត្ថលេខា?

[១៣:៥៦:៣៦]

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំមិនមានការចងចាំទេ ពីព្រោះបីបួនឆ្នាំហើយ ព្រោះបើមានឯកសារនៅដៃខ្ញុំបានខ្ញុំដឹង បើអត់ឯកសារអ៊ីចឹងពិបាកចាំដែរ មិនដឹងជាថ្ងៃ១៨ ឬថ្ងៃ១៩។

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះ ខ្ញុំសូមរំឭកការចងចាំរបស់លោក ថានៅទំព័រចុងក្រោយនៃកំណត់ហេតុស្តាប់ចម្លើយលោកនោះគឺថា មានលើកឡើងថា មានការអានកំណត់ហេតុស្តាប់ចម្លើយនេះ គឺថាត្រូវបានធ្វើឡើងនៅថ្ងៃទី២៧ មីនា ឆ្នាំ២០០៩ នៅម៉ោងប្រាំបួន សែសិនប្រាំនាទី អ៎! ម៉ោងដប់មួយ សែសិបប្រាំនាទីគឺថាមុនពេលដែលស្តាប់លោកមួយថ្ងៃ គឺកើតនៅថ្ងៃទី២៨ មីនា គឺថាអត្ថបទដើមនៃកំណត់ហេតុស្តាប់ចម្លើយនេះ ផ្តល់ទៅជូនលោកៗនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ នៅម៉ោងដប់មួយជាង។ ហើយអានស្តាប់ហើយសាក្សីមិនបានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា។ តើលោកចាំទេ គឺថាកំណត់ហេតុស្តាប់ចម្លើយរបស់លោកត្រូវបានអានឲ្យលោកស្តាប់ ហើយនិងផ្តល់ច្បាប់ចម្លងឲ្យលោក បើមួយខែក្រោយមកហើយទេ ក្រោយពីពេលដែលគេបានសម្ភាសលោកនោះ តើលោកចាំទេ?

[១៣:៥៨:៣៣]

**ផ៖** ខ្ញុំមិនចងចាំទេបាទ ព្រោះខ្ញុំមានការងារមមាញឹកណាស់ក្នុងជីវភាពខ្ញុំ ដូច្នេះខ្ញុំមិនសូវបានចាប់អារម្មណ៍ពីរឿងឯកសារថ្ងៃណា ខែណា ឆ្នាំណាទេបាទ។

**ស៖** បាទ ខ្ញុំមិនសួរទាក់ទងកាលបរិច្ឆេទនៅលើឯកសារនោះទេ ប៉ុន្តែសួរទាក់នឹងកាលៈទេសៈដែលគេផ្តល់លទ្ធភាពដល់លោក ក្នុងការអានកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតឡើងវិញដើម្បីឲ្យផ្ទៀងផ្ទាត់ថា តើវាដូចនឹងអ្វីដែលលោកបានប្រាប់ពួកគាត់ពីពេលមុនដែរឬទេ? ប៉ុន្តែខ្ញុំសង្កេតឃើញថា បើសិនជាខ្ញុំទុកចិត្តទៅលើឯកសារដែលគេផ្តល់មកឲ្យខ្ញុំនេះ ខ្ញុំវាហាក់ដូចជាឃើញថា នែ៎ ពេលដែលលោកចុះហត្ថលេខា គេឲ្យអត្ថបទនេះឲ្យលោកចុះហត្ថលេខានោះគឺថា វាខុសគ្នានោះដល់រយៈពេលមួយខែ។ នេះជាសំណួររបស់ខ្ញុំ តើលោកចាំរយៈពេលនេះទេគឺថា ពេលដែលគេសម្ភាសលោក ហើយនិងចន្លោះពេលដែលគេសម្ភាសលោក ហើយនិងពេលដែលលោកចុះហត្ថលេខាលើកំណត់ហេតុស្តាប់ចម្លើយហ្នឹង ហើយនិងគេឲ្យផ្តល់ច្បាប់ចម្លងមួយឲ្យលោកហ្នឹង តើវារយៈពេល

ដល់ទៅមួយខែឯណោះ ដែលបានកន្លងផុតទៅនោះ?

[១៤:០០:១៤]

**ឆ៖** បាទ តាមការចងចាំដូចជា អស់លោកហ្នឹងចុះពីរដងបាទ។ លើកទី១ មានរយៈពេល២ថ្ងៃមែន ហើយដល់លើកទី២ ដឹងប៉ុន្មានថ្ងៃទេ ខ្ញុំមិនមានការចងចាំទេបាទ ខ្ញុំដឹងថាពីរដង។ អ៊ីចឹងអាចគម្លាតគ្នាពីលើកទី១ និងលើកទី២ ហ្នឹង គឺលោកអាចបូកដកអីទៅគឺឃើញហើយ អាចប៉ុន្មានខែៗអីឃើញហើយ ព្រោះខ្ញុំគ្មានឯកសារទេ។ ប៉ុន្តែនីតិវិធីរបស់គេ មុននឹងឲ្យខ្ញុំចុះហត្ថលេខា គឺអ្វីដែលមុននឹងចុះហត្ថលេខាគេបានអានឲ្យខ្ញុំស្តាប់ ហើយក៏បានសួរបញ្ជាក់ខ្ញុំថា ទាំងអស់នេះវាពិត ឬមិនពិតអីហ្នឹង។ អ៊ីចឹងគឺ គេបានសាកសួរអ៊ីចឹងមែន គេបានអានឲ្យស្តាប់មុនឲ្យខ្ញុំចុះហត្ថលេខាបាទ។

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកសំណួរទី១ របស់ខ្ញុំវិញ។ ទាក់ទងទៅនឹងកិច្ចសម្ភាសន៍មួយដែលកើតមុននឹង១ថ្ងៃ។ លោកសហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ការអានកំណត់ហេតុស្តាប់ចម្លើយនេះ អាចឲ្យយើងកត់សម្គាល់ឃើញថា កិច្ចសម្ភាសន៍ទី១ នោះកើត -- ប្រព្រឹត្តទៅអស់រយៈពេល២ថ្ងៃ។ បើតាមការផ្ទៀងផ្ទាត់នេះ ជាការត្រឹមត្រូវហើយ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ការដែលថាលោកនិយាយអំពី ប៉ង់ ទៅអ្នកស៊ើបអង្កេត ពេលមុននុ៎ងទៀតគឺថា ការនិយាយនេះវាមាននៅក្នុង -- គឺថាលោកនិយាយនៅក្នុងកំណត់ហេតុទី១ ទៅវិញ គឺថា នៅថ្ងៃទី១ ថ្ងៃទី១ ដែលគេសម្ភាសលោក។ បើយើងស្តាប់ខ្សែអាត់នោះ ដែលខ្ញុំបានឲ្យលេខយោងហើយអម្បាញ់មិញ ហើយយើងបានផ្ទៀងផ្ទាត់ផងគឺថាៗ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ដែលមានលើកឡើងថា មុនពេលផ្អាក ហើយដើម្បីជួបនៅថ្ងៃបន្ទាប់មកទៀតនោះ គឺថាមានចែង -- មាននិយាយពីសំណួររបស់ខាងស៊ើបអង្កេតនោះសួរ សំណួរគាត់នេះ គឺថាធ្វើឲ្យទាយថាលោក លោកសាក្សីបាននិយាយអំពី ប៉ង់ ក៏ប៉ុន្តែនៅក្នុងសំណៅជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ លោកមិនដែលបាននិយាយពី ប៉ង់ នោះទេ។

[១៤:០៣:២៥]

ដូច្នេះគឺថា បានន័យថាវាយោងទៅនឹងការសម្ភាសដែលកើតមានឡើងមុនពេលនុ៎ងទៀត បើសិនជាយើងជឿជាក់ទៅលើខ្សែអាត់ គឺថានោះអាចបានន័យថា ថ្ងៃទី១៧ បើសិនជាលោកចាំ តែបើលោកមិនចាំទេ ក៏មិនបញ្ហាដែរ។ តើលោកបានជួបអ្នកស៊ើបអង្កេតរបស់តុលាការយើងនេះ មុនថ្ងៃទី១៨ កុម្ភៈដែរឬទេ ហើយបើបានជួបបាននិយាយអំពីអ្វីដែរ?

**ឆ៖** បាទ ខ្ញុំចាំមិនអស់ទេបាទ។ សំណួរក៏មានច្រើន ហើយវាយូរឆ្នាំដែរហើយបាទ ខ្ញុំមិនសូវបានគិតផង។

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី នង សុផង់។

សូមអញ្ជើញ!

[១៤:០៥:០៣]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន សូមអរគុណលោកប្រធាន។ លោក នង សុផង់ ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា។ សូមជម្រាបសួរ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួន សំណួរខ្លះមានភាគីគេបានសួររួចទៅហើយ ប៉ុន្តែលោកឆ្លើយមិនបាន១ លម្អិត ខ្ញុំនឹងចង់សួរបន្ថែមលម្អិត ដើម្បីឲ្យបំភ្លឺតុលាការ។ ពី -- ខ្ញុំសូមបើកវង់ក្រចកបន្តិច ពីម្សិលមិញខ្ញុំឃើញលោកសាក្សីហាក់ដូចជា ពេលថ្ងៃរសៀលអ៊ីចេះហាក់ដូចជាខ្សោយ ហើយអស់កម្លាំងឆ្លើយតិច១។ ខ្ញុំសួរថាថ្ងៃនេះលោក សុខភាពលោកល្អធម្មតាទេ អាចបន្ត ខ្ញុំអាចសួរបន្តបានទៅមុខទេ ឬក៏យ៉ាងម៉េច? សូមអរគុណ។

[១៤:០៦:១៨]

**លោក នង សុផង់៖**

**ឆ៖** បាទ សុខភាពខ្ញុំពីម្សិលមិញ វាសម្ពាធឈាមឡើងខ្ពស់ដល់១៨ តែឥឡូវវាចុះមក១៦ វិញហើយ។ ដូច្នេះវាបានធូរស្រាលបន្តិចហើយបាទ ក៏អាចស៊ូទ្រាំនឹងការផ្តល់សក្ខីកម្មហ្នឹងបានបាទ។

**ស៖** អរគុណលោកសាក្សី នេះជាពលិកម្មមួយសំខាន់ណាស់របស់លោក។ ខ្ញុំសូមសួរថា នៅឆ្នាំ១៩៧៣ លោកបានចូលបដិវត្តន៍ដោយមានឈ្មោះ ហង្ស នៅតំបន់ព្រះវិហារ បានជ្រើសរើសលោកឲ្យធ្វើការនៅគណៈមជ្ឈិមបក្ស នៅគីនៅ ប-១៧ ពេលនោះមានលោកមានអាយុ២១ឆ្នាំពិតប្រាកដអ៊ីចឹង

ទេ ឬក៏ខ្ញុំខុស?

**ឆ៖** បាទ រឿងអាយុខ្លួនឯង ខ្ញុំមិនបានគិតទេកាលមកតស៊ូហ្នឹង ពេលណាអីពេលណា ប៉ុន្តែលោកអាចគិតមើលទៅពីឆ្នាំ១៩៧៣ បាទ ឥឡូវមកដល់ខ្ញុំអាយុ៦០ ហើយ។ បាទលោកបូកដកទៅឃើញហើយ បាទអីចឹងគឺឃើញ បើឃើញម្ភៃប៉ុន្មានហ្នឹងវាត្រូវហើយបាទ ២១ អីចឹង! បាទ។

[១៤:០៨:០០]

**ស៖** អរគុណ។ នៅមុនបដិវត្តន៍ លោកចូលមុន -- លោកចូលបដិវត្តន៍ឆ្នាំ១៩៧៣ ពេលហ្នឹងលោកមានមុខងារ ប្រកប ឬក៏ប្រកបវិជ្ជាជីវៈអ្វី? បើក្នុងឯកសារថាលោកៗ នឹងធ្វើ មានការងារមួយធ្វើជាគ្រូបឋម។ អីចឹងពិតទេ?

**ឆ៖** បាទ ពិតប្រាកដមែនបាទ។

**ស៖** អរគុណ។ លុះដល់លោកចូលបាន -- មកក្នុងបដិវត្តន៍ លោក សុផង់ ធ្វើជាប្រធាននៅមន្ទីរសារទូលេខ ប-១៧ គឺសមរភូមិក្រោយ។ នេះជាចម្លើយរបស់លោកជូនសហព្រះរាជអាជ្ញាថ្ងៃទី២៩ ខែ៨ ឆ្នាំ២០១២។ អំពីសារបញ្ជូនពីក្រោម ពីក្រោយឡើយ -- ពីក្រោមឡើងលើ ភាគច្រើនជូន ប៉ុល តាមស្ពាន គឺ ប៉ុល ពត។ ឯសារម្តងម្កាលជូន បងនួន។ ខ្ញុំសួរថា តើលោកអាចដឹងថា សារនោះនិយាយអំពីអ្វីទេ បងទាំង -- ទាំងបង ប៉ុល ពត ទាំងបង នួន ជា?

**ឆ៖** បាទ រឿងសារ នៅក្នុងចន្លោះ -- នៅក្នុងពីចុងឆ្នាំ៧៣ ដែលខ្ញុំបានបកប្រែហ្នឹង វាមានពីរកន្លែង។ មួយកន្លែង ដូចខ្ញុំប្រាប់ថា ខ្ញុំរៀនផង ធ្វើផង នៅក្នុងព្រៃ ហើយដល់ពេលឆ្នាំ ចុងឆ្នាំ៧៤ បានខ្ញុំដូរពី អ៎! ដូរកន្លែងមក មិនមែននៅ ប-១៧ ទេ គឺនៅក្នុងព្រៃចេកមួយ នៅកៀនហៅថា ក្នុងបរិវេណ ប-២០ ទេ បាទ មិនមែន ប-១៧ ទេ។ ឯខ្លឹមសារក្នុងមួយរយៈដែលនៅក្នុងព្រៃនោះ ភាគច្រើន គឺគេជូនបងប៉ុល បាទ។ ខ្លឹមសារ ដែលជូនបងប៉ុល គឺវាគ្រប់ផ្នែកទាំងអស់ហ្នឹងហើយ បាទ។ ហើយក៏ឯរឿងខ្លឹមសារជូន បងនួន ដូចខ្ញុំបានជម្រាបលោកហើយ គឺថាអ្វីដែលជាការងារខាងមូលដ្ឋានខាងក្រោយដែលបានរំដោះហើយបាទ។

[១៤:១១:២៧]

**ស៖** នៅក្នុងសារមួយៗ ដែលលោកបានកាន់ ហើយនិងបានធ្វើ ធម្មតាសារទាំងអស់ ប្រហាក់ប្រហែលគ្នា គឺមានក្បាល ហើយនិងក្រោម ចុងកន្ទុយវា។ ខាងលើបំផុត សារច្រើនដាក់ថា ចម្លងជូនចម្លងជូនបងៗ ជាទីគោរព ឬក៏ អ៊ំអីអីចឹងទៅ។ ខាងក្រោម អឺ! សូមទោស ខ្ញុំនិយាយអំមិញបែបខុស។

អឺ! ខាងលើដាក់ថា “ជូន” ខាងក្រោមដាក់ថា “ចម្លងជូន” ខ្ញុំនិយាយនេះ ត្រឹមត្រូវទេ ដើម្បីខ្ញុំបន្តទៅទៀត?

**ឆ៖** បាទ ខាងក្បាលហ្នឹង គេដាក់ថា “ជូន” អ៊ីចឹងមែន ឯខាងកន្ទុយហ្នឹង មិនមែន “ចម្លងជូន” ទេ គឺជា -- អាកន្ទុយនេះ ដោយអ្នកដែលគេសរសេរនោះ ទម្រង់សរសេរខាងក្រោយចុងបំផុតនោះ ខ្លះគេថា “ជូនពរបង សុខសប្បាយជ័យជម្នះ” ឬមួយក៏ “ដោយភាតរភាព បដិវត្តយ៉ាងកក់ក្ដៅបំផុត” អ្នកខ្លះក៏ថា “ដោយភារកិច្ច” អីៗអ៊ីចឹង អានេះជាទម្លាប់ទៅតាមបុគ្គលម្នាក់ ដែលគេសរសេរអារឿងកន្ទុយចុងក្រោយដើម្បីបញ្ចប់សាររបស់គេ។

[១៤:១៣:១៦]

ឯចុងបំផុតបន្ទាប់ពីអាហ្នឹងមក គេដាក់កាលបរិច្ឆេទដែលគេធ្វើសារហ្នឹង ថ្ងៃណាខែណាឆ្នាំណា ហើយចុងបញ្ចប់ គឺហត្ថលេខារបស់អ្នកដែលធ្វើសារហ្នឹងចេញមក។ គឺមិនមានពាក្យ “ចម្លងជូន” ស្រាប់នៅក្នុងសារនោះទេបាទ។ ព្រោះ “ជូន” នោះ គេដាក់ “ជូន” ពីលើរួចហើយ។ ជូនបងៗណាហ្នឹង បាទ។ ឯ “ចម្លងជូន” ហ្នឹង គឺជាភារកិច្ចជាអ្នកចាត់ចែងសារទូរលេខ។

**ស៖** អរគុណណាស់។ ខ្ញុំ -- នៅខាងក្រោមអំមិញលោកមានបានជម្រាបតុលាការថា ខាងលើដាក់ “ជូន” ប៉ុន្តែខាងក្រោមមាន “ជូនពរ” អ៊ីចឹងទៅ ហើយមាន “ហត្ថលេខា”។ ពាក្យថា “ហត្ថលេខា” នេះ បើបារាំង គេថា “ស៊ីញ៉េ”។ លោក ហត្ថលេខានេះ គ្រាន់តែដាក់ឈ្មោះ ខ្ញុំឃើញមានសារទូរលេខច្រើនណាស់ មានដាក់ឈ្មោះផ្ញើ ហើយមានតែឈ្មោះទេ មានតែឈ្មោះទទេរហ្នឹង កាលសម័យហ្នឹងប្រែថា ហត្ថលេខា អ៊ីចឹង ឬយ៉ាងម៉េច?

[១៤:១៤:៥៤]

**ឆ៖** បាទ ហត្ថលេខា ហ្នឹង មិនសំដៅលើអាគំនូសក្រវេមក្រវាមដែលគេសម្គាល់ថា ជាសញ្ញាទីរ៉េហ្នឹងទេ គឺឈ្មោះតែម្ដងបាទ។

**ស៖** អ៊ីចឹង ខ្ញុំចង់បញ្ជាក់បន្ដិចទៀតថា ហត្ថលេខា និងដាក់ឈ្មោះហ្នឹង កាលពីសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង មានន័យថាដូចគ្នាអ៊ីចឹង គ្រាន់តែដាក់ឈ្មោះទៅជាហត្ថលេខា ឬក៏ហត្ថលេខាផ្សេង? ហើយគ្រាន់តែដាក់ឈ្មោះអ៊ីចឹងទៅ មានន័យថាអ៊ីចឹង?

**ឆ៖** បាទ គឺមកពីខ្ញុំនិយាយពន្យល់អស់លោកខុសទេ តាមពិតគឺជាឈ្មោះហ្នឹងហើយ។ ឈ្មោះរបស់អ្នកធ្វើសារទូរលេខហ្នឹងបាទ។ គេមិនអាចស៊ីញ៉េអីផ្ញើនៅឲ្យឃើញជាស្នាមស៊ីញ៉េរបស់គេនោះទេ

បាទ នៅក្នុងសារទូរលេខហ្នឹង។

[១៤:១៥:២៣]

**ស៖** អរគុណ។ នៅពេលដែលលោកបានទទួលសារទូរលេខស្ដីអំពីផែនការវាយភ្នំពេញ វាយផ្ដាច់យកភ្នំពេញស្ដីអំពីគ្រាប់រំសេវ និងភស្តុភារផ្សេងៗ តើសារទូរលេខទាំងនោះមកពីណាទៅណា? លោកអាចបញ្ជាក់បានទេ ផ្ញើពីណា ហើយទៅកន្លែងណា?

**ឆ៖** បាទ ខ្ញុំមិនបានទទួលសារអំពីការណែនាំពីរឿងធ្វើផែនការរំដោះវាយបុកភ្នំពេញនោះទេ។ ឯរឿងបញ្ជូនសារពី រឿងភស្តុភារ គ្រាប់រំសេវអ្វី គឺតាមខ្ញុំចាំ គឺនៅ ដែលនៅក្នុងព្រៃគឺមានអង្គភាពមួយគេទទួលខាងភស្តុភារហ្នឹង គេដាក់ឈ្មោះ យ៉ា អ៊ីចឹងដែរ ជាអ្នកបញ្ជូនសម្ភារៈខាងគ្រាប់រំសេវហ្នឹងទៅសមរភូមិមុខដោយផ្ដល់ថា មានគ្រាប់នេះប៉ុន្មាន គ្រាប់នោះប៉ុន្មាន គេមានធ្លាប់ឃើញតាមសារទូរលេខដែរបាទ។ ពីអ្នកចុះហត្ថលេខាពីក្រោមរឿងសម្ភារៈ អាវុធយុទ្ធភណ្ឌអីហ្នឹង គឺអង្គាល់ហ្នឹងគឺឃើញឈ្មោះ យ៉ា បាទ។

**ស៖** អរគុណ។ លោកសាក្សីបានធ្វើការនៅជាមុខងារជាអ្នកកាន់សារទូរលេខនៅគណៈមជ្ឈិម ជាអ្នកបកប្រែសារទូរលេខនៅគណៈមជ្ឈិម។ គណៈ -- កន្លែងលោកធ្វើការហ្នឹងទៅការិយាល័យរបស់ថ្នាក់ដឹកនាំហ្នឹង មានចម្ងាយប៉ុន្មានពីកន្លែងលោកហ្នឹង ទៅកន្លែងថ្នាក់ដឹកនាំ? ប្រហែល?

[១៤:១៩:៣១]

**ឆ៖** បាទ រឿងពីកន្លែងខ្ញុំទៅកន្លែងលោកអ្នកដឹកនាំ ពីព្រោះនៅក្នុងព្រៃហ្នឹងខ្ញុំមិនមានសិទ្ធិដើរហើរឆ្វេចឆ្វាចនៅក្នុងកន្លែងដឹកនាំនោះទេ។ ហើយនៅក្នុងព្រៃហ្នឹង គឺមិនអាចដឹងថាចម្ងាយពីគ្នាប៉ុន្មានទៅប៉ុន្មាននោះដែរ។ ពីព្រោះព្រៃស្អុកជិត សូម្បីតែ១០ម៉ែត្រពីគ្នា ក៏មើលមិនចង់ស្គាល់ផង ព្រៃម៉ាគីហ្នឹងបាទ។ អ៊ីចឹងគឺមិនអាចដឹងថា កន្លែងលោកដឹកនាំនៅឆ្ងាយប៉ុនណា ពីព្រោះខ្ញុំ -- ភារកិច្ចខ្ញុំធ្វើហើយខ្ញុំរៀនផងធ្វើផងហ្នឹង ឲ្យទៅ ប៉ុន ហ្នឹងគេអ្នកចាត់ចែង គេយកទៅឲ្យអ្នកណាក៏ខ្ញុំមិនដឹងបាទ ឆ្ងាយប៉ុនណាក៏ខ្ញុំមិនដឹង។

**ស៖** ចុះលុះដល់មកនៅភ្នំពេញ លោកអាចដឹងថា -- ភ្នំពេញវាល! លោកអាចអាចដឹងថាចម្ងាយពីប៉ុន្មានទៅប៉ុន្មានទេពីកន្លែងថ្នាក់ដឹកនាំ ហើយមកកន្លែងមន្ទីររបស់លោក ឬការិយាល័យរបស់លោក?

**ឆ៖** បាទ កន្លែងខ្ញុំគឺការិយាល័យរបស់ខ្ញុំ គឺសាលារៀនសម្ដេចសុធារស។ ឯថ្នាក់ដឹកនាំ គឺនៅ

ក-១ ឈ្មោះកន្លែងដែលអស់លោកបានឃើញក្នុងរូបហើយ គឺថាជាអគារខ្ពស់ៗពីរនៅមាត់ទន្លេបាសាក់ ដែលគេហៅថា ប៊ូលឌីង ហ្នឹង។ អ៊ីចឹងមានចម្ងាយជាក់ស្ដែងប៉ុន្មាន ខ្ញុំមិនដែលវាស់ទេ ប៉ុន្តែតាមប៉ាន់ស្មានវាមិនដល់មួយគីឡូផងបាទ។ ឯទៅកន្លែងផ្សេងទៀតខាងមួយផ្នែកទៀត ខាងការងារចាត់ចែងសម្ភារៈ ខ្ញុំមិនដឹងថា ប៉ុន្មានគីឡូដែរ ព្រោះមិនដែលវាស់ មិនដែលដឹង ហើយមិនដែលបានចូលទៅបាទ។

**ស៖** សូមអរគុណ។ ការទំនាក់ទំនងផ្ញើសារទូរលេខហ្នឹង គឺលោកផ្ញើនៅកន្លែងការិយាល័យរបស់លោក នៅកន្លែងរបស់លោក លោកមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងការិយាល័យរបស់ថ្នាក់ដឹកនាំទេ គឺតាមរយៈអ្នកណា តាមរយៈ ប៉ុន ឬតាមរយៈអ្នកណាអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ ការទំនាក់ទំនងគ្នា ទី១ គឺតាមទូរស័ព្ទហ្នឹងហើយបាទ បើ ប៉ុន គេចង់ទំនាក់ទំនងអ្វី គេអាចទូរស័ព្ទមកខ្ញុំ ហើយជួនណាគេមានសារអី គេអាចចេញមកជួបយើងខ្ញុំ ឬមួយក៏ផ្ញើតាមនីរសារដែលនៅមុខរោងយាមហ្នឹង មកឲ្យខាងខ្ញុំបាទ។

**ស៖** បើតាមចម្លើយរបស់លោកឆ្លើយអំមិញថា ការិយាល័យរបស់លោកជាមួយនឹងថ្នាក់ដឹកនាំមិនឆ្ងាយពីគ្នាប៉ុន្មានទេ ប្រហែលយ៉ាងយូរ ឆ្ងាយបំផុត ប្រហែលជាមួយគីឡូដឺ។ លោកមានដែលបានឃើញ ឬក៏ជួបប្រទះ ឬក៏ដែលឃើញអ្នកធំទាំងប៉ុន្មាន ដែលអស់លោកថ្នាក់ដឹកនាំទាំងប៉ុន្មានហ្នឹង ដែលមកកន្លែងលោក ឬក៏លោកដែលគេហៅទៅកន្លែងអ្នកធំទេ អស់លោកថ្នាក់ដឹកនាំហ្នឹងទេ?

[១៤:២៤:២១]

**ឆ៖** បាទ សាលារៀនខ្ញុំគឺ នៅមិនឆ្ងាយពី ក-១ ទេ។ ដូច្នេះ ជួនកាលក៏ខ្ញុំបានឃើញលោកបើកឡានឆ្លងកាត់សាលារៀនខ្ញុំហ្នឹងដែរ ដូចជាលោក ប៉ុល ពត ជាដើម។ លោកបរកាត់ ហើយលោកបានឆ្លងទៅឆ្លងមក កាត់សាលាខ្ញុំហ្នឹង លោកចេញទៅណាក៏កាត់តាមហ្នឹង ចូលក៏កាត់តាមហ្នឹង។

**ស៖** អរគុណ។ លោកដែលឃើញលោក នួន ជា ទេ?

**ឆ៖** បាទ លោក នួន ជា ខ្ញុំឃើញម្ដងដែរ ដែលលោកធ្លាប់ទៅម្ដងកន្លែងខ្ញុំហ្នឹង ហើយយកសារទូរលេខខ្លីៗដែលថា អញ្ជើញកម្មាភិបាល អញ្ជើញអស់លោកដែលជាសភាហ្នឹងមក ដើម្បីប្រជុំនៅឆ្នាំ៧៧ ហ្នឹង ខ្ញុំឃើញម្ដងដែរ ដែលលោកបានអញ្ជើញទៅកន្លែងខ្ញុំបាទ។

**ស៖** អរគុណ។ បើអ៊ីចឹងមានន័យថា លោកបាន -- លោក នួន ជា បានទៅកន្លែងលោកផ្ទាល់ លោកបាននិយាយស្ដី ឬក៏គាត់សួរលោករឿង ពីរឿងនេះ ពីរឿងនោះ ឬក៏លោក នួន ជា ហ្នឹងគាត់បាននិយាយជាមួយលោកខ្លះទេ ពេលដែលបានទៅជួបគ្នាហ្នឹង?

[១៤:២៦:២១]

**ឆ៖** បាទ អត់មានបានសំណេះសំណាលអីយូរទេ ព្រោះគាត់គ្រាន់តែហុចសារឲ្យខ្ញុំមក ឲ្យពួកខ្ញុំហ្នឹងបកប្រែតែប៉ុណ្ណឹង អត់មាននិយាយអីច្រើនទេបាទ។

**ស៖** រួចក្រោយមកទៀត លោកដែលជួបលោក នួន ជា ថែមទៀតទេ?

**ឆ៖** បាទ មិនបានជួបទេបាទ។

**ស៖** ពេលដែលលោកធ្លាប់ធ្វើការ នៅក្នុងកម្ពុជាប្រជាធិបតេយ្យយូរមកហើយ ហើយម្តងហ្នឹងដែលលោកបានជួបលោក នួន ជា តើលោកសម្គាល់ឃើញលោក នួន ជា ហ្នឹងមានចរិតយ៉ាងម៉េច? ហើយសក្តិសមជាថ្នាក់ដឹកនាំ ដើម្បីបដិវត្តន៍លោកស្រឡាញ់ជាតិ ឬលោកឃោរឃៅកាប់សម្លាប់ ចាប់ចងអីអ៊ីចឹង ចរិតមួយណាដែលលោកបានសម្គាល់ឃើញ?

[១៤:២៧:៤៥]

**ឆ៖** បាទ ខ្ញុំសម្គាល់ឃើញថា ចរិត ក៏ដូចជាអាកប្បកិរិយារបស់លោក នួន ជា ក្តីអស់លោកផ្សេងៗក្តី គឺគួរឲ្យគោរពដែរ មិនមានជាមនុស្សដែលហៅថា ប្រើអំណាច ដែលគួរឲ្យខ្លាច ឬមួយក៏ឃើញអស់លោកហ្នឹង ចាប់ចងកាប់សម្លាប់អ្នកណាផ្ទាល់ម្នាក់ក៏មិនដែលឃើញដែរ នឹងភ្នែកខ្ញុំមិនដែលជួបប្រទះដែរបាទ។ គឺអស់លោកមានសីលធម៌ ម្យ៉ាងគឺឃើញថា ជាអ្នកចាស់ទុំផង ហើយជាចេះដឹងគួរឲ្យគោរព មិនសមថាអស់លោកទៅជាឃាតករ ជាឧក្រិដ្ឋកម្មសង្គ្រាមប្រល័យពូជសាសន៍អី ដូចជាមិនសមសោះបាទ។

**ស៖** អរគុណ។ ខ្ញុំចង់ធ្វើការវិភាគ ពិភាក្សាជាមួយលោកចំពោះគំនូសមួយ ដែលលោកបានគូសជម្រាបទៅចៅក្រមស៊ើបអង្កេត ដែលលោកបានឆ្លើយជូនភាគីមួយចំនួនរួចមកហើយនោះ គឺលេខ D200/9.12 គឺលោកប្រហែលជាមាននៅចំពោះមុខលោកដែរ។ គំនូសនេះ លោកទទួលស្គាល់ថា ជារបស់លោកដែលបានគូសដោយដៃខ្លួនលោក មិនអ៊ីចឹងណ៎ះ?

[១៤:២៨:៥៥]

**ឆ៖** បាទ គំនូសពន្យល់នៅលើក្តារខៀននេះ គឺជាគំនូសដែលខ្ញុំបានគូសផ្ទាល់ដោយដៃខ្ញុំពិតប្រាកដមែន។

**ស៖** អរគុណ។ ក្នុងនេះខ្ញុំមានសំណួរចំនួនពីរបី។ ទី១ នៅក្នុងគំនូសនេះមានប្រអប់រាងបួនជ្រុងទ្រវែងបួនធំៗ។ ពីឆ្វេងទៅស្តាំ ពីឆ្វេងបង្អស់មានប្រអប់មួយដាក់លេខ ៨៧០ ហើយក្រៅប្រអប់ហ្នឹង

មាន ក-១ ហើយខាងលើប្រអប់ហ្នឹងដាក់បណ្ដាញទាក់ទង។ ដល់ប្រអប់ទី២ មានគណ: ៨៧០ នៅក្នុងប្រអប់ហ្នឹងដែរ ខាងក្រោមមានដាក់ ក-១ ដូចគ្នា ៨៧០ ពីមុន ហើយខាងស្ដាំប្រអប់ហ្នឹងមានដាក់ ប.ព។ ខ្ញុំសូមសួរលោកថា ប្រអប់ពីរហ្នឹង មួយដាក់៨៧០ទទេ មាន ក-១ ដូច -- ក៏ដូចនឹងប្រអប់ទី២ គណ:៨៧០ មាន ក-១ ដែរវាខុសគ្នាយ៉ាងម៉េច?

[១៤:៣១:២៨]

**ឆ៖** បាទ ប្រអប់ទាំងពីរនេះខុសគ្នា។ មួយមានចំណងជើងថា បណ្ដាញទាក់ទង។ នេះគឺក-១ ដែរ គឺថាបណ្ដាញទាក់ទង គឺរបស់៨៧០ បាទ បណ្ដាញទាក់ទងហ្នឹងរបស់ ៨៧០ ដែលមានអ្នកចាត់ចែងខាងផ្នែកទូរគមនាគមន៍ហ្នឹងនៅ ក-១ បាទ។ ឯប្រអប់មួយទៀតដាក់ថា គណ:៨៧០ ដែរ ដាក់ថា គណ:៨៧០ អានេះចង់និយាយពីស្ថាប័នមួយរបស់គណ:មជ្ឈិម ដែលមានគេហៅថា គណ:៨៧០ ហ្នឹង គឺគណ:៨៧០ ហើយ -- គណ:មជ្ឈិមហើយ។ ក្នុងនេះគឺមាន ប៉ុល ពត ហ្នឹងជាប្រធានគណ:ហ្នឹង ហើយលោកក៏មានទីលំនៅនៅ ក-១ ហ្នឹងដែរបាទ។ ទីចាត់ការ ទីស្នាក់ហ្នឹងនៅ ក-១ ហ្នឹងហើយ។ បាទចង់បញ្ជាក់អ៊ីចឹងបាទ។

**ស៖** អរគុណណាស់។ ប្រអប់ទី៣ ដាក់ថា "គណ:ប្រជាជន -- គណ:ប្រធានរដ្ឋ" ខាងក្រោមដាក់ ខ.ស.ផ ហើយមានព្រួញបាញ់មកក្រោមមានក្រសួងនានា មានក្រសួងឃោសនាការ -- ក្រសួងឃោសនាព័ត៌មាន៖ មាន ហ៊ូ នឹម, អប់រំសិក្សាធិការ យុន យ៉ាត, សង្គមកិច្ច អៀង ធីរិទ្ធ, រ៉ែនិងថាមពល... សេដ្ឋកិច្ចហិរញ្ញវត្ថុ ឈ្មោះនេះលោកបានកែពីម្សិលមិញម្ដងហើយ ខ្ញុំមិនបាច់សួរតទៅទៀត ហើយនិងការបរទេសលោក អៀង សារី។ អានេះខ្ញុំចង់សួរថា លោកចង់សម្គាល់ថា ជារដ្ឋាភិបាល ឬក៏ជាគណ:កម្មការអ្វីដែលក្នុងប្រអប់ហ្នឹង?

[១៤:៣៣:៥៥]

**ឆ៖** បាទ ចង់បង្ហាញឲ្យឃើញស្ថាប័នមួយទៀត ដែលជាស្ថាប័នខ្ពស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យដែរ គឺគណ:ប្រធានរដ្ឋ។ ស្ថាប័នគឺមានលោក ខៀវ សំផន, ខ.ស.ផ ហ្នឹង ខ្ញុំអក្សរកាត់របស់ខ្ញុំ គឺ ខៀវ សំផន ដែលលោកធ្វើជាប្រធានគណ:។ ហើយគូសព្រួញនេះ គឺខ្ញុំបានពន្យល់ហើយចង់ថា ទាំងអស់នេះជាផ្នែកស៊ីវិលដែលរាជរដ្ឋាភិបាល ដែលមានក្រសួងនានានៅក្រោមហ្នឹង គឺមានដូចខ្ញុំបានរៀបរាប់ហូរហែហ្នឹង។ អាកន្លែងចុចៗ គឺខ្ញុំមិនស្គាល់ឈ្មោះ ហើយចុចៗអាខាងក្រោមទៀតហ្នឹង គឺខ្ញុំរៀបរាប់មិនអស់ទេ ព្រោះខ្ញុំមិនចាំបាន។ នេះបាទ បញ្ជាក់អ៊ីចឹង។

**ស៖** អរគុណ។ ក្រសួង -- គណៈប្រធានរដ្ឋហ្នឹង មានក្រសួងនានា។ ហើយចុះក្រសួងការពារជាតិនោះ ដែលលោក សុន សេន កាន់នោះ អត់នៅក្នុងគណៈប្រធានរដ្ឋទេ? នៅក្រោម ឃើញព្រួញមកបាញ់ពីអាកន្លែងគណៈ៧៨៧០ ទៅវិញ។ អាហ្នឹង មិនមែនជារដ្ឋាភិបាល ឬក៏យ៉ាងម៉េច អាហ្នឹង ខ្ញុំអត់យល់ឃើញដូចវាមានការ ខ្ញុំមានការភ័ន្តច្រឡំកន្លែងហ្នឹង។ ខាងក្រោម៨៧០ ហ្នឹង មានក្រសួងការពារជាតិ ដាក់ សុន សេន ហើយមានកងទ័ព ហើយមាន ស-៧១ ទាំងអស់ហ្នឹង វាជាក្រសួងដែរ ឬក៏យ៉ាងម៉េច បានជាមិនដាក់ជាមួយគ្នានឹងខាងក្រោមក្រសួងនានានេះ?

[១៤:៣៦:០៦]

**ឆ៖** អាហ្នឹង គឺមកពីខ្ញុំក្តាប់មិនបាន មិនដឹងជាក្រសួងការពារជាតិហ្នឹង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋឬអត់។ ខ្ញុំមិនប៊ានធ្វើអត្ថាធិប្បាយ ពីព្រោះក្រសួងការពារជាតិហ្នឹង គឺលោកមានអំណាចគ្រប់គ្រង គ្រប់កងពល ទាំងជើងទឹក ជើងគោក ជើងអាកាស។ អ្វីដែលខ្ញុំមិនអាចដាក់ថា នៅពីក្រោមគណៈប្រធានរដ្ឋបាន ពីព្រោះការងារជាក់ស្តែង ហាក់ដូចជាលោកមិនមានឥទ្ធិពលលើកងទ័ព មិនដែលឃើញលោកបញ្ជាកងទ័ព អាហ្នឹងបានជាខ្ញុំ -- ប៉ុន្តែសរសេរនៅក្នុងរង្វង់ជាប់គ្នាជាមួយក្រសួងនានាដែរ ប៉ុន្តែមិនសរសេរដាក់ថា នៅពីក្រោមលោក ខៀវ សំផន ហ្នឹងបាទ។ គឺមានន័យអ៊ីចឹង។

**ស៖** បើដូច្នោះ លោកមិនច្បាស់ក្នុងខ្លួន ថាលោកហ្នឹងស្គាល់រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលច្បាស់ទេ។ អ៊ីចឹងទេ?

**ឆ៖** បាទ សម័យហ្នឹង គឺអ៊ីចឹងមែន។ ខ្ញុំមិនច្បាស់ទេបាទ។

[១៤:៣៧:៣៨]

**ស៖** កាលពីសម័យហ្នឹង លោកដែលឮថាមានក្រសួងសន្តិសុខទេ?

**ឆ៖** បាទ ខ្ញុំបានឮថា ផ្នែកសន្តិសុខ គឺវាស្ថិតនៅក្នុងក្រសួងការពារជាតិ ដែលមានលោក សុន សេន ជាអ្នកដឹកនាំបាទ។

**ស៖** អរគុណណាស់។ បើអ៊ីចឹងមានន័យថា នៅក្រោមក្រសួងការពារជាតិ លោកភ្លេចដាក់ក្រសួងសន្តិសុខមួយ នៅក្នុងរង្វង់ជាមួយគ្នាហ្នឹង អ៊ីចឹង?

**ឆ៖** បាទ ព្រោះ សុន សេន ហ្នឹងគឺគាត់ជាឧបនាយករដ្ឋមន្ត្រីក្រសួងការពារជាតិ ហើយក៏គាត់ទទួលការងារសន្តិសុខក្នុងផ្ទៃប្រទេសទាំងមូលបាទ។ ដូច្នេះ គឺខ្ញុំមិនបានដាក់ថា ក្រសួងសន្តិសុខអីមួយ

ទៀតទេ ពីព្រោះថា ការពារជាតិហ្នឹង គឺវាក្តោបទាំងសន្តិសុខ ទាំងអី ទាំងអស់នៅហ្នឹងអស់ហើយបាទ។

**ស៖** សូមអរគុណសាជាថ្មី។ ខ្ញុំនឹងឆ្លងទៅដល់ប្រអប់ទី៤ គឺសភាតំណាងប្រជាជន។ ក្នុងនោះខាងក្រោមមានដាក់ នួន ជា។ ហើយខាងក្រោម នួន ជា ហ្នឹង មានដាក់ថា សរសេរអក្សរឡាតាំង នាម *ម៉ូវ្រ៉ូត្រ័រ សេវ៉ូត្រ័រ* មានន័យថា លេខ៣ ហើយខាងបន្ទាប់ហ្នឹងទៀត មានប្រអប់បួនជ្រុងមួយទៀតដាក់ "តុលាការ" មានន័យយ៉ាងម៉េច សូន្យបីហ្នឹង? លេខសូន្យបីហ្នឹង ហើយនិងតុលាការ?

[១៤:៤០:០៥]

**ឆ៖** បាទ គឺការគូសពន្យល់នេះវាមានច្រើនបញ្ហា ដែលចៅក្រមស៊ើបអង្កេតមិនបានញែកឲ្យដាច់នូវអ្វីនីមួយៗហ្នឹង។ អ៊ីចឹងអានេះគឺជារឿងមួយផ្សេងទេ។ សូមឆ្លើយតបសារលេខ០៣, សេកា ១០៥, ដេដេ ប្រញាប់អីហ្នឹង។ គឺលោកនិយាយពីរឿងអីផ្សេងហ្នឹងទៀតទេ មិនមែនចូលក្នុងប្រអប់ដែលថានៅក្នុងក្រោមអំណាចរបស់លោក នួន ជា នោះទេបាទ។ និយាយពីរឿងការឆ្លើយឆ្លងសារ ដែលថាបើយើងត្រូវប្រញាប់ យើងសុំឲ្យគេឆ្លើយតប។ ឧបមាថា សារណាដែលប្រញាប់ ឧបមាថា ថ្នាក់ដឹកនាំឬមួយក៏មូលដ្ឋានគេសុំយោបល់ប្រញាប់ហើយ ប៉ុន្តែពីរបីថ្ងៃហើយ មិនទាន់ឆ្លើយតប អ៊ីចឹងគេមិនបាច់សរសេរខ្លឹមសារហ្នឹងឡើងវិញទេ គឺគ្រាន់ថាសុំឲ្យឆ្លើយតបនឹងសារដែលមានលេខរៀង០៣ ចង្កោមប៉ុន្មានៗហ្នឹងទៅដែលមានសញ្ញាប្រញាប់ហ្នឹង។ សញ្ញាដេដេ ហ្នឹងគឺថាកម្រិតប្រញាប់របស់សារហ្នឹង គឺបានន័យថាប្រញាប់បំផុត។ អានេះគឺ ចង់និយាយថាបច្ចេកទេសក្នុងការឲ្យគេឆ្លើយតបនឹងសារអ្វីមួយដែលយើងចាំបាច់ឆ្លើយតប ហើយគេមិនឃើញឆ្លើយតបនុំង។ នេះជាការបញ្ជាក់ពន្យល់រឿងបច្ចេកទេស ដែលអស់លោកសួរពីរឿងទាក់ទងគ្នាពីលើទៅក្រោម ពីក្រោមឡើងលើហ្នឹង។ អ៊ីចឹងគឺ -- ឯតុលាការនេះ ខ្ញុំចង់ដាក់ថា ព្រោះលោកសួរបញ្ជាក់ថា ចុះរឿងតុលាការម៉េច អីម៉េច? ខ្ញុំក៏ចង់ដាក់ថាបានតុលាការហ្នឹងនៅស្មើគ្នានៅខាងលើដែរ បាទ គឺជាស្ថាប័នរដ្ឋមួយដែរ គឺមានស្ថាប័នតុលាការមួយដែរនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង។ ហើយតាមគេផ្សាយក្នុងវិទ្យុហ្នឹង គឺថាមានលោក កង ចាបហ្នឹងធ្វើជាប្រធានតុលាការហ្នឹងបាទ។

[១៤:៤២:៤៣]

អ៊ីចឹងគឺចង់បញ្ជាក់ថា នៅសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេមានស្ថាប័នបួនណោះ។ គឺមានគណៈ៨៧០, គណៈប្រធានរដ្ឋ, សភាតំណាងប្រជាជន ហើយនិងតុលាការផងដែរបាទ។ នេះវាស្មើគ្នាទេស្ថាប័នកំពូលទាំងប៉ុន្មានហ្នឹង។ ចង់ដាក់ឲ្យស្មើដែរ ប៉ុន្តែដល់ក្តារខៀនវាផុតទៅហើយបាទ។

**ស៖** សូមអរគុណណាស់បានបំភ្លឺអំពីនីតិ គេហៅនីតិទាំងបួនរបស់រដ្ឋនៅសម័យនោះ។ ដូចបាន លោកសាក្សីបានជម្រាបតុលាការអំមិញអ៊ីចឹង។ បើអ៊ីចឹងមានន័យថា មាននីតិតុលាការមួយដាច់ដោយ ឡែកពីនីតិបីទៀត អ៊ីចឹងទេ បើខ្ញុំមិនខុសទេ?

**ផ៖** បាទ វាមាននៅក្នុងការរៀបចំរដ្ឋហ្នឹង វាមានអ៊ីចឹងមែន គឺមានអំណាចតុលា -- មាន អំណាចវាដាច់ដោយឡែកពីគ្នាបាទ។ គណៈប្រធានរដ្ឋ ស្ថាប័នសភាតំណាងប្រជាជន និងតុលាការអ៊ីចឹង ដែរ។ នេះជារូបភាព យើងឃើញថាមានដូចគេ ដូចឯងទូទៅលើសកលលោកអ៊ីចឹងដែរ។

[១៤:៤៤:២៤]

**ស៖** អរគុណណាស់ ថ្ងៃនេះលោកបានបំភ្លឺច្បាស់លាស់អំពីអំណាចទាំងបួនចែកដាច់ពីគ្នា។ ហើយសុំសួរថា លោក នួន ជា ពេលហ្នឹង សម័យនុ៎ង ជាប្រធានសភាតំណាងរាស្ត្រប្រជាជន។ តាម លោកដឹងពិតជាអ៊ីចឹង ហើយលោកមានមុខងារអីផ្សេងក្រៅពីហ្នឹងទេ?

**ផ៖** បាទ រឿងការងាររបស់អស់លោកថ្នាក់ដឹកនាំ ខ្ញុំមិនអាចដឹងថា លោកមានការងារអ្វីផ្សេង ក្រៅពីការរៀបចំជាចំហឲ្យប្រជានកម្ពុជាទាំងមូល ក៏ដូចជាសកលលោកបានដឹង អំពីស្ថាប័នរបស់ លោកដែលជាសភាតំណាងប្រជាជននោះទេបាទ។ ខ្ញុំក៏ដឹងដូចជាអស់លោកទូទៅ ពេញប្រទេសពេញ សកលលោកដែរ គឺដឹងថា លោកជាសភាតំណាងប្រជាជនបាទ។ ឯអ្វីផ្សេង ខ្ញុំមិនដឹង។

**ស៖** អរគុណណាស់។ លោកមានដែលចូល--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅមានសំណួរច្រើនទេ? នៅមានសំណួរច្រើនទៀតទេ?

បាទឥឡូវនេះ ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងបី ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាក សម្រាប់សាក្សីរូបនេះ សម្រាកនៅ បន្ទប់រង់ចាំសម្រាប់សាក្សីក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់ សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតសំណួរ តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនៅមានសំណួរតែពីរបីទៀតអស់ហើយ ហើយនិងបន្ទាប់ទៅនេះសហភាតាខ្ញុំនឹងបន្ត។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកបន្តតែពីរបីសំណួរទៀតទេ។ មានឯកសារចម្លើយរបស់ -- ការសាកសួររបស់ចៅក្រមស៊ើបអង្កេត លេខ E3/64 លោកបានឆ្លើយថា តើ -- សួរសំណួរ សួរៗថា "តើបងខឿន និងបង យ៉ែម ជាអ្នកណា?" ពេលហ្នឹងលោកឆ្លើយថា "ខ្ញុំមិនសូវដឹងច្បាស់ទេ អំពីអ្នកទាំងពីរនាក់នេះ។ យ៉ែម អាចជាសមាជិកសភា ចំណែក ខឿន ប្រហែលជាសមា -- ប្រធានមន្ទីរអ្វីមួយធ្វើការជាមួយ នួន ជា ឬក៏ ខៀវ សំផន ឬជាសមាជិកសភាទទួលបន្ទុកខាងភូមិភាគឧត្តរ"។ ឃ្លារបស់លោកនេះ លោកបាននិយាយពាក្យ "អាច" និងពាក្យ "ប្រហែល" នោះបញ្ជាក់ថា លោកមិនច្បាស់លាស់ទេ គ្រាន់តែស្មានៗ ដែលពេលលោកឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេត។ តើការបកប្រែរបស់ខ្ញុំនេះ ត្រឹមត្រូវទេ? លោកគ្រាន់តែជាស្មាន លោកមិនបានច្បាស់លាស់ទេ លោកឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេតពេលនុ៎ង?

[១៥:០៨:២៣]

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំបានឆ្លើយយ៉ាងដូច្នោះមែន។ ពីព្រោះខ្ញុំប្រើពាក្យ "អាច និង ប្រហែល" ហើយដល់ខ្ញុំបានមកធ្វើសក្ខីកម្មនៅផ្ទាល់នៅកន្លែងតុលាការនេះ បានខ្ញុំយល់ថា ពាក្យ "អាច" ពាក្យ "ស្មាន" ពាក្យ "ប្រហែល" គឺពុំមែនជាការពិតទេ។ ដូច្នេះ ខ្ញុំក៏បានលើកសំណូមពរឲ្យអង្គសវនាការលុបចោលនូវពាក្យ

ទាំងឡាយណាដែលខ្ញុំបានផ្ដល់បទសម្ភាសន៍ជូនថៅក្រុមស៊ើបអង្កេត គ្រប់ពាក្យទាំងអស់នៅក្នុងបទសម្ភាសន៍ហ្នឹងដែលមានពាក្យ “ប្រហែល” ពាក្យ “អាច” ពាក្យ “តាមខ្ញុំស្មាន” ចេញទៅកុំទុកជាការ ពីព្រោះគឺខ្ញុំមិនដឹងបាទ។

**ស៖** អរគុណ លោកបានបំភ្លឺច្បាស់លាស់ចំពោះមុខតុលាការ ខ្ញុំយល់ថា នេះជាលើកទី២ ដែលលោកបានបញ្ជាក់។ ខ្ញុំសូមសួរសំណួរមួយទៀត នៅក្នុងទំព័រដែលខ្ញុំបានសួរអំមិញ ទំព័រដដែលហ្នឹង។ ពេលនុ៎ងលោកថៅក្រុមសួរថា “តើ នួន ជា មានទំនាក់ទំនងអ្វីជាមួយសារទូរលេខនេះ?” លោកឆ្លើយថា “ជាដំបូងទូរលេខនេះ គឺបញ្ជូនទៅតែ ប៉ុល ពត ម្នាក់គត់។ ប៉ុន្តែដោយសារអ្នកគ្រប់គ្រងសារទូរលេខគាត់ដឹងថា បញ្ហានេះ គឺត្រូវបញ្ជូនទៅខាងអ្នកទទួលខុសត្រូវខាងប្រជាជន ដោះស្រាយដូចជា នួន ជា ដើមនេះ”។ ត្រង់ចម្លើយរបស់លោកពេលនោះថា “បញ្ហានេះ គឺត្រូវបញ្ជូនទៅអ្នកទទួលខុសត្រូវខាងប្រជាជនដើម្បីដោះស្រាយ ដូចជា នួន ជា” ជាដើមនេះ តើមានន័យថាយ៉ាងម៉េច? ក្នុងឃ្លានេះបើលោក នួន ជា គ្រាន់តែជាប្រធានសភាប្រជាជនតែប៉ុណ្ណោះ? ហេតុអ្វីបានជាៗ ហេតុអ្វីបាន នួន ជា អ្នកទទួលខុសត្រូវប្រជាជនទៅវិញ បើលោកគ្រាន់តែប្រធានរដ្ឋសភា?

[១៥:១១:១៤]

**ឆ៖** បាទ ខ្ញុំមិនដឹងអស់អំពីកិច្ចការដែលខាងលោកៗ ប៉ុន គាត់ចាត់ចែងយ៉ាងម៉េចទេ។ ក៏ប៉ុន្តែអ្នកក្រុមស៊ើបអង្កេត ឲ្យខ្ញុំជួយវិភាគ ឲ្យខ្ញុំជួយពន្យល់ អ៊ីចឹងហើយខ្ញុំពន្យល់ហ្នឹងគឺក្នុងន័យថា វាអាចអ៊ីចេះ តាមស្មានអ៊ីចុះ អាហ្នឹងគឺក្នុង ខ ហ្នឹងក៏សូមកែដែរ គឺថាម្យ៉ាងសារហ្នឹងមិនមែនជាទិសរបស់ខ្ញុំផងម្យ៉ាងទៀតមិនមែនខ្ញុំជាអ្នកចាត់ចែងផង។ ឯខ្លឹមសារវិញ ខ្ញុំជួយពន្យល់គាត់ ថាក្នុងសារហ្នឹងវាគេដាក់ផ្ញើជូនសមមិត្ត បងប៉ុល។ ប៉ុន្តែរឿងហ្នឹងវា ខ្លឹមសារយើងមើលទៅ គឺថាមិនមែនតែ បងប៉ុល ម្នាក់ឯងទេ ដែលមានសិទ្ធិដែលត្រូវទទួលសារហ្នឹង។ អានេះជាតាមខ្ញុំស្មានប្រាប់ថៅក្រុមស៊ើបអង្កេតហ្នឹង។ អ៊ីចឹងហើយបានជាក្រុមអ្នកចាត់ចែងទូរលេខ គេចំណារដាក់ថា បងនួន នោះ បាទគឺហេតុផលអ៊ីចឹង។ តែឲ្យច្បាស់ថា ខ្ញុំថា សារហ្នឹងគឺត្រូវតែជូន បងនួន តែម្ដង អះអាងថាអ៊ីចឹង គឺខ្ញុំអត់ច្បាស់ទេ។ នេះគឺជាការវិភាគទេបាទ ជាការជួយពន្យល់ទេ។ បាទ ខ្ញុំអាចបំភ្លឺបានតែប៉ុណ្ណឹងទេបាទ។

[១៥:១៣:២៤]

**ស៖** ខ្ញុំ សំណួរចុងក្រោយរបស់ខ្ញុំសួរថា ពីម្សិលមិញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានសួរលោកថា បើមានអ្នកខុសនឹងសីលធម៌សង្គម គេធ្វើម៉េច? លោកបានឆ្លើយថា -- ពេលដែលលោកឆ្លើយ

ចំពោះមុខចៅក្រមស៊ើបអង្កេតនោះ លោកឆ្លើយថា បញ្ជូនទៅឱ្យ -- បើមានបញ្ហាខុសសីលធម៌ ទាក់
ទងទៅនឹង នួន ជា ទៅវិញ បើលោក នួន ជា ជាប្រធានសភាសោះ ម៉េចក៏គ្រប់គ្រងរឿងសីលធម៌អីណា
ទៅវិញ។ អានេះសូមលោកជួយបំភ្លឺត្រង់ហ្នឹងផង។

**ឆ៖** ខ្ញុំឱ្យលោក សូមឱ្យលោកពិនិត្យចម្លើយហ្នឹង តើមានដែលខ្ញុំប្រើពាក្យ ឬអាចដែរទេ? សូម
ផ្ទៀងផ្ទាត់ចម្លើយរបស់ខ្ញុំទៅជាមួយនឹងចៅក្រមស៊ើបអង្កេត។ បើ--

**ប្រធានអង្គជំនុំ៖**

កុំអាលៗសាក្សី! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:១៤:៤៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមានចំណុចពីរដែលចង់លើក។ ទី១ គឺថាមេធាវីការពារក្តីបាននិយាយយោងទៅ
លើផ្នែកមួយនៃចម្លើយ ហើយឯកសារនេះនិយាយអំពីភស្តុតាង។ ដូច្នេះគាត់គួរផ្តល់នូវលេខឯកសារ និង
លេខ ERN ដើម្បីឱ្យភាគីនានាធ្វើការតាមដាន។ ចំណុចទី២ ខ្ញុំមិនបានជំទាស់នៅពេលទី១ ប៉ុន្តែឥឡូវនេះ
ខ្ញុំត្រូវតែជំទាស់ ដោយសារតែសហភាតាខ្ញុំ គាត់បានលើកនូវផ្នែកមួយនៃការស្តាប់ចម្លើយដែលហាក់ដូច
ជាបានបញ្ជាក់ច្បាស់ថាបានទទួលស្គាល់។ គឺក្នុងនាមជាអនុលេខានៃបក្សកុម្មុយនីស្តកម្ពុជា នេះគឺជា
ផ្នែកមួយដែលមិនត្រឹមត្រូវ គឺជាផ្នែកមួយដែលមិនសមស្របទល់តែសោះ ហើយវាអាចនាំឱ្យមានការ
យល់ច្រឡំ ហើយនិងអាចនឹងមានការប្រើប្រាស់ដែលមិនត្រឹមត្រូវនូវភស្តុតាង។

ដូច្នេះ ខ្ញុំសូមលើកឡើងថា ប្រសិនបើសហភាតារបស់ខ្ញុំចង់ធ្វើការលើកឡើងទៅសាកសួរទៅ
លើសាក្សី គាត់មិនគួរបញ្ជាក់ច្បាស់ -- មិនគួរនាំឱ្យមានការយល់ច្រឡំនោះឡើយ ទាក់ទងទៅនឹងតួនាទី
របស់ នួន ជា ជាប្រធានសភាតំណាងប្រជាជន។

[១៥:១៥:៥៦]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅសហព្រះរាជអាជ្ញា។ ខ្ញុំបានយោងទៅលើ បានជម្រាបតុលាការអំពីលេខ
ឯកសារនោះរួចហើយ។ ហើយពេលនុ៎ងមិនមានជំទាស់ទេ ខ្ញុំបាននិយាយអំពីអង្គសេចក្តីទៅ។ តាំងពី
មួយ អ៊ំ! ដែលសំណួរទី១ចុងក្រោយបំផុតនេះ និងសំណួរទី២ដូចគ្នា ថានៅក្នុងឯកសារដដែល។ ប៉ុន្តែ
គ្រាន់សំណួរវាខុសៗគ្នា។ ហើយខ្ញុំថា សំណួររបស់ខ្ញុំ សាក្សីបានឆ្លើយបំភ្លឺហើយ។ គ្រាន់តែចុងក្រោយ

បំផុតនេះ។ សំណួរចុងក្រោយបំផុតរបស់ខ្ញុំនេះ លោកគ្រាន់សួរមកខ្ញុំវិញថា លោកមិនច្បាស់ថា តើលោកបាននិយាយមានពាក្យប្រហែលទេ? ឬអីអ៊ីចឹង? ខ្ញុំមិនទាន់បានឆ្លើយផង។ ប៉ុន្តែលោកព្រះរាជអាជ្ញាជំទាស់មានន័យថា ជំទាស់ក្រោយសាក្សីបានឆ្លើយហើយ។

សូមអរគុណ។ ខ្ញុំអស់សំណួរប៉ុណ្ណឹង។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា មានបន្តតាំងសំណួរទៀតទេ? បើមានសូមអញ្ជើញ!

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។

[១៥:១៧:៣០]

**សួរដោយលោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវចោទសួរចំពោះរូបលោក។ ជម្រាបសួរលោកសាក្សី។ ខ្ញុំជាមួយនឹងលោកមេធាវី សុន អរុណ គឺជាលោកមេធាវីដែលទើបតែបញ្ចប់ការសាកសួររបស់លោក។ ពួកខ្ញុំគឺជាមេធាវីការពារក្តីឲ្យលោក នួន ជា។ ហើយខ្ញុំមានសំណួរមួយចំនួនដែលត្រូវចោទសួរចំពោះលោក។ ហើយមុនពេលខ្ញុំសួរ ខ្ញុំសូមធ្វើការថ្លែងអំណរគុណចំពោះលោកដែលបានអញ្ជើញមកទីនេះ ដើម្បីផ្តល់សក្ខីកម្មនៅក្នុងអង្គតុលាការ។ ខ្ញុំគិតថា នេះគឺជាការងារដ៏លំបាកមួយ ហើយលោកចំណាយពេលវេលាដ៏ច្រើន។ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះលោកដែលលោកបានផ្តល់នូវចម្លើយទាក់ទងទៅនឹងអង្គហេតុ ក៏ដូចជាភស្តុតាងនានា។ ប្រសិនបើលោកដឹង គឺសូមលោកជម្រាប។ ប្រសិនបើមិនដឹងទេ សូមលោកជម្រាបតាមនេះទៅ។ ហើយខ្ញុំសូមចាប់ផ្តើមជាដំបូងដោយនិយាយអំពី -- ខ្ញុំសង្ឃឹមថា ខ្ញុំអាចបញ្ចប់នៅថ្ងៃនេះ ដែលមិនចាំបាច់បន្តដល់ទៅដល់ថ្ងៃស្អែកនោះទេ។ ហើយខ្ញុំមានការងារមួយចំនួនដែលខ្ញុំត្រូវសុំឲ្យលោកធ្វើការបញ្ជាក់ ដើម្បីឲ្យខ្ញុំអាចយល់ច្បាស់អំពីសក្ខីកម្ម ក៏ដូចជាភស្តុតាងដែលលោកបានផ្តល់ឲ្យ។

[១៥:១៨:៤៥]

ជាដំបូង លោកបានជម្រាបមកយើងថា ទោះបីថាមានប្រព័ន្ធដែលត្រូវប្រើប្រាស់នៅមូលដ្ឋានក៏ដូចជានៅភូមិភាគ ដែលបញ្ជាក់អំពីការទទួលសារទូរលេខនៅពេលដែលគេបញ្ជូនចេញ។ លោក ខ្លួន

លោកផ្ទាល់បានបញ្ជាក់ផងដែរថា លោកមិនអាចបញ្ជាក់ថា ទូរលេខដែលត្រូវបានបញ្ជូនចេញហ្នឹង តែងតែត្រូវបានគេទទួល។ ខ្ញុំគ្រាន់តែចង់ឱ្យលោកបញ្ជាក់ថា លោកមិនមានតួនាទីក្នុងការធានាថា ទូរលេខទាំងអស់ដែលបញ្ជូនចេញត្រូវបានទទួល។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**លោក នង សុផង់៖**

**ផ៖** បាទ ត្រឹមត្រូវណាស់។ ព្រោះអាហ្នឹង វាហួសពីសមត្ថភាពដែលខ្ញុំត្រូវតាមដាន។

**ស៖** សូមអរគុណលោកសាក្សី។ ហើយចំណុចមួយទៀត គឺលោកបានជម្រាបផងដែរថា វាមិនមែនជាតួនាទីរបស់លោក។ ហើយខ្ញុំចង់ឱ្យលោកបញ្ជាក់ទៅលើចំណុចនេះ។ លោកបាននិយាយព្រឹកនេះថា គឺលោកឆ្លើយទៅនឹងសំណួររបស់លោកមេធាវី គង់ សំអុន ដែលជាមេធាវីក្រុមលោក ខៀវ សំផន ហើយខ្ញុំជឿថា លោកបានជម្រាបដល់គាត់ថា លោកមិនដឹងថា សារទូរលេខដែលលោកធ្វើការបកប្រែហ្នឹង ត្រូវបានបញ្ជូនទៅដល់អ្នក -- ត្រូវបានបញ្ជូនទៅដល់អ្នកដែលបានទទួល គឺលោកមិនដឹងថា ទូរលេខហ្នឹង ត្រូវបានគេបញ្ជូនទៅដល់អ្នកដែលគេចង់ផ្ញើជូន ឬក៏អត់នោះ គឺបានន័យថា មិនបាន ដឹងច្បាស់ ថាអ្នកដែលទទួលហ្នឹង គឺបានទទួល ឬក៏អត់នោះទេ? តើខ្ញុំនិយាយបែបនេះ ត្រឹមត្រូវដែរឬទេ?

[១៥:២០:៣៣]

**ផ៖** បាទ អឺចឹងមែន វាមិនប្រាកដដែរ។

**ស៖** សូមអរគុណ។ ហើយខ្ញុំមានចំណុចមួយទៀត ពាក់ព័ន្ធទៅលើចំណុចនេះ។ តើខ្ញុំអាចនិយាយបានដែរឬទេ ថាតាមការយល់ដឹងរបស់លោក គឺថាខ្លួនលោកផ្ទាល់ គឺនិយាយអំពីទូរលេខហ្នឹងបានគេដាក់នៅក្នុងស្រោមសំបុត្រ ដែលលើស្រោមសំបុត្រហ្នឹង គេសរសេរថា ក-១។ ដូច្នេះ វាហួសពីការដឹងរបស់លោក ដែលថាសំបុត្រហ្នឹង ត្រូវបានគេដាក់នៅក្នុងប្រអប់មួយនៅខាងមុខ ក-១។ តើខ្ញុំនិយាយបែបនេះ ត្រឹមត្រូវដែរឬទេ?

**ផ៖** បាទ មិនមែនដាក់នៅក្នុងប្រអប់មួយនៅកន្លែងរោងយាមមុខ ក-១ នោះទេ គឺថាពេលនីរសារខាងខ្ញុំបញ្ជូនទៅ គឺជូនទៅដល់អ្នកដែលប្រចាំការនៅកន្លែងរោងយាមមុខ ក-១ ហ្នឹងហើយបាទ។ មិនមែនជាប្រអប់សំបុត្រដែលទុកចោលប៉ុន្មានម៉ោងៗ ដែលបានគេមកបើកមើលម្ដង ដូចជាស្រោមសំបុត្រធម្មតា តាមប្រៃសណីយ៍នោះទេ។ គឺគេយកទៅភ្លាម មានអ្នកប្រចាំការនៅមុខហ្នឹង គេយកទៅភ្លាមតែម្ដង។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំយល់មិនខុសទេ សំបុត្រដែលលោករៀបរាប់ដែលមានសរសេរ ក-១

នៅខាងលើហ្នឹង គឺដាក់នៅកន្លែងមួយ នៅខាងក្រៅ ក-១ ហើយមានមនុស្សមកយកពីកន្លែងនុ៎ង។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៥:២២:៤៥]

**ឆ៖** បាទ មានមនុស្សយាមជាប់២៤ម៉ោង នៅមុខកន្លែងផ្លូវចេញចូលទៅ ក-១ ហ្នឹង នៅមុខអគារហ្នឹងម្ដង។

**ស៖** សូមអរគុណលោកសាក្សី។ ដូច្នេះ អ្វីដែលកើតឡើងចំពោះសារទូរលេខនោះ គឺថា ប៊ុន គឺជាអ្នកទទួលខុសត្រូវ ចាប់ពីពេលដែលគេដាក់នៅកន្លែងមុខ ក-១ ហ្នឹងទៅ គឺលោកលែងដឹងរឿងអស់ហើយ គឺមានតែ ប៊ុន ម្នាក់ ដែលអ្នកទទួលខុសត្រូវ។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ក្រុមនីរសារ អ្នកដែលយាមនៅ ក-១ ហ្នឹង គេនឹងយកបន្តទៅជូន លោក ប៊ុន ជាអ្នកចាត់ចែងបាទ។

[១៥:២៣:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំគិតថា លោកបានជួយឲ្យខ្ញុំចំណេញពេលវេលាយ៉ាងច្រើន។ ឥឡូវនេះ ខ្ញុំសូមបន្តទៅនឹងនូវបញ្ហាទូទៅមួយទៀត។ បន្ទាប់មក យើងនឹងនិយាយអំពីបញ្ហាជាក់លាក់បន្ថែមទៀត។ លោកមេធាវី សុន អរុណ បានសួរលោកនូវសំណួរមួយចំនួន គឺសំណួរនិយាយអំពីការសន្មត ឬក៏ស្មាន ដែលលោកបានបញ្ជាក់ច្បាស់រួចទៅហើយ ថាលោកបាននិយាយថា គឺទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចទៅលើការសន្មត ឬក៏កាសន្និដ្ឋានរបស់លោកទៅលើចម្លើយជាមួយសហចៅក្រមស៊ើបអង្កេតនោះ។ ខ្ញុំឥឡូវនេះ ចង់ឲ្យលោកពិភាក្សាអំពីបញ្ហាដែលលោកបានជជែកជាមួយនឹងអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតនោះ។ ដូច្នេះ ខ្ញុំសូមដកស្រង់នូវប្រតិចារឹកពង្រាង ដើម្បីកុំឲ្យមានការយល់ច្រឡំទៅលើអ្វីដែលលោកបាននិយាយ ហើយនេះគឺជាប្រតិចារឹកកាលពីម្សិលមិញ ហើយខ្ញុំជឿជាក់ថា លោកបានឆ្លើយទៅនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយខ្ញុំសូមដកស្រង់ពីប្រតិចារឹកនោះ គឺថ្ងៃ០៤ ខែ៨ គឺទំព័រទី -- គឺជួរទី១៧ "ខ្ញុំមិនដឹងថានៅពេលដែលមនុស្សបាត់ខ្លួននោះ ត្រូវបាន គេចេញ ឬក៏យកទៅណានោះទេ។ មេធាវី -- សហចៅក្រមស៊ើបអង្កេតព្យាយាមសួរខ្ញុំដដែលៗទៅលើបញ្ហានេះ ហើយខ្ញុំបានបញ្ជាក់ពីដើមថាខ្ញុំមិនបានដឹងតាំងពីដំបូងមកម្ល៉េះ។

[១៥:២៥:២៥]

ដំបូងគាត់សួរខ្ញុំឲ្យពន្យល់អំពីការដកមនុស្សចេញ ហើយខ្ញុំបានពន្យល់រួចទៅហើយ ហើយ

បន្ទាប់មកមានសំណួរដដែលៗបានសួរមកខ្ញុំបន្ថែមទៀតទាក់ទងទៅនឹង ប៉ង់ ហើយនិង ថេរ។ ហើយចម្លើយហ្នឹងមិនអាចប្រើប្រាស់ជាភស្តុតាងនោះឡើយ ព្រោះដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ ថាខ្ញុំមិនបានដឹង។ ហើយខ្ញុំមិនបានដឹងអំពីអ្វីដែលកើតឡើងចំពោះមនុស្សដែលត្រូវបានគេដកចេញនៅមូលដ្ឋាននោះទេ។ ហើយខ្ញុំមិនដឹងគេដកយកទៅណានោះទេ”។

អ្វីដែលខ្ញុំចង់លោក គឺឃ្លាមួយដែលលោកនិយាយថា “លោកបានបញ្ជាក់ច្បាស់ថា គេបាន -- សហចៅក្រមស៊ើបអង្កេតបានដាក់នូវសំណួរច្រើនចំពោះលោក” តើលោកចង់មានន័យយ៉ាងដូចម្ដេច? លោកចង់និយាយថា នៅពេលដែលគេសួរនុ៎ង គឺលោកមិនដឹង ឬក៏មួយក៏លោកបានបញ្ជាក់ច្បាស់ថា លោកមិនដឹងហើយ ប៉ុន្តែអ្នកស៊ើបអង្កេតនៅតែសួរសំណួរដដែលៗ សួរម្ដងហើយម្ដងទៀត ដោយសារតែមិនពេញចិត្តជាមួយនឹងអ្វីដែលលោកឆ្លើយ។ តើលោកអាចជម្រាបបានដែរឬទេ ការដែលគេប្រើពាក្យថា “គេសួរដដែលៗទៅលើ--” លោកសាក្សី លោកកុំទាន់អាលឆ្លើយសំណួរនេះ ព្រោះខាងព្រះរាជអាជ្ញាគាត់បានងើបឈរដើម្បីធ្វើការជំទាស់រួចហើយ។

[១៥:២៦:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំហាក់ដូចជាស្ទាក់ស្ទើរបន្តិច ខ្ញុំមិនចង់ជាកាត់ប៉ុន្មានទេ ប៉ុន្តែខ្ញុំត្រូវធ្វើការកាត់ដោយសារតែបញ្ហាពាក់ព័ន្ធនៃឯកសារ។ យើងបានស្ដាប់នូវភស្តុតាងដោយផ្ទាល់ពីសាក្សី យើងបានស្ដាប់នូវការពន្យល់របស់សាក្សីបញ្ជាក់អំពីការយល់ដឹងរបស់គាត់ ហើយគាត់បានបញ្ជាក់បំភ្លឺទៅលើបញ្ហានេះរួចទៅហើយ ហើយយើងបានស្ដាប់ថាគាត់បានបញ្ជាក់លម្អិតទៅលើចម្លើយដែលគាត់បានផ្ដល់ ហើយគាត់ក៏បាននិយាយហើយទៀតអំពីអ្វីដែលគាត់ចង់បញ្ជាក់។ ដូច្នេះយើងសូមស្នើថា សំណួរបែបនេះ គឺថាមិន -- ដែលជាសំណួរសួរអំពីបច្ចេកទេសក្នុងការចោទសំណួររបស់អ្នកស៊ើបអង្កេត គឺវាមិនពាក់ព័ន្ធនោះឡើយ។ ប្រសិនបើមេធាវីចង់ដឹងអំពីការយល់ដឹង អំពីចំណេះដឹងរបស់សាក្សីទៅលើភស្តុតាងនោះ គាត់គួរតែសួរបែបនេះ។ អ្វីដែលគាត់សួរបែបនេះ គឺវា គឺការសួរអំពីបច្ចេកទេសរបស់ការស៊ើបអង្កេតរបស់បច្ចេកទេសក្នុងការស្ដាប់ចម្លើយរបស់អ្នកស៊ើបអង្កេតគឺហាក់ដូចជាមិនពាក់ព័ន្ធនោះឡើយ។ ខ្ញុំសូមបញ្ចប់នូវការលើកឡើងរបស់ខ្ញុំ។

[១៥:២៧:៥០]

**លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី៖**

ខ្ញុំសូមឆ្លើយសង្ខេប អ្វីដែលខ្ញុំយល់ គឺយល់ពីផ្ទុយពីនេះ។ ព្រោះថាបច្ចេកទេសក្នុងការសាកសួរដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់នេះ គឺខ្ញុំចង់និយាយអំពីអង្គសេចក្តី អំពីខ្លឹមសារក៏ដូចជាភាពពាក់ព័ន្ធនៃសំណួរ ក៏ដូចជាគុណភាពនៃភស្តុតាងដែលត្រូវដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ គឺចម្លើយរបស់សាក្សីនេះ។ អ្វីៗទាំងអស់ហ្នឹង គឺផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ មិនមែនយើង ដោយសារតែយើងមិនធ្វើការសាកសួរដេញដោលទៅលើសាក្សីនេះ។ ដូច្នេះ បច្ចេកទេសរបស់សហចៅក្រមស៊ើបអង្កេតនេះ គឺពាក់ព័ន្ធយ៉ាងខ្លាំង គឺពាក់ព័ន្ធទៅនឹងគុណភាពនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ ហើយដោយសារសាក្សីនៅចំពោះមុខយើង នៅទីនេះ គឺយើងអាចឲ្យគាត់ឆ្លើយពាក់ព័ន្ធទៅនឹងការដែលគាត់និយាយថា មានការសួរសំណួរបន្ថែម ហើយដដែលៗច្រើនទៅលើគាត់។ គាត់មានសមត្ថភាពក្នុងការប្រាប់យើង ថាតើមានអ្វីដែលបានកើតឡើង។

[១៥:២៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ែខល កាណាវាស! មានបញ្ហាអីទៅ?

**លោក ម៉ែខល កាណាវាស៖**

សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ សូមជម្រាបសួរដល់ភាគី និងអស់លោកទាំងអស់គ្នា។ ខ្ញុំសូមគាំទ្រដល់ការឆ្លើយតបរបស់មេធាវី នួន ជា ហើយខ្ញុំសូមបន្ថែមដូចតទៅនេះ។ ហេតុការណ៍នេះបានកើតឡើងកាលពីជាង៣០ឆ្នាំមុន។ ហេតុអ្វីក៏អ្នកស៊ើបអង្កេតធ្វើឡើងនូវការសង្ខេប ហើយផ្តល់នូវការជួយទៅដល់សាក្សី ដើម្បីឲ្យចាំទៅលើព្រឹត្តិការណ៍នានា ហើយបង្ហាញនូវឯកសារនានាដែលអាចធ្វើឲ្យគាត់នឹកឃើញឡើងវិញ។ បច្ចេកទេសបែបនេះ គឺៗជាផ្នែកមួយដែលយើងចង់ធ្វើការពិនិត្យមើល ដើម្បីពិនិត្យទៅលើភាពទុកចិត្តបាននៃសាក្សី ក៏ដូចជាការចងចាំរបស់សាក្សី ហើយនិងការយល់ដឹងរបស់សាក្សីនៅពេលនោះ គឺនៅពេលដែលហេតុការណ៍នេះបានកើតឡើង។

[១៥:២៩:៥៨]

ហើយយើងចង់ដឹងអំពីអ្វីដែលគាត់ដឹងនៅពេលនោះ មិនមែនចង់ដឹងពីអ្វីដែលគាត់បានដឹងនៅពេលនោះ មិនមែនចង់ដឹងពីអ្វីដែលគាត់បានដឹងតាមរយៈការផ្តល់ព័ត៌មានពីសហចៅក្រមស៊ើបអង្កេត

នោះឡើយ។ ដូច្នេះ អ្វីដែលយើងបានសួរហ្នឹង គឺយើងចង់សួរពីអ្វីដែលបានកើតឡើងនៅពេលអតីតកាល ហើយសហព្រះរាជអាជ្ញា ក៏មិនបាននិយាយអំពីអ្វីដែលខាងសហចៅក្រមស៊ើបអង្កេតបានធ្វើឡើង ដោយសារយើងដឹងច្បាស់ហើយ ហេតុអ្វីបានគេមិនសួរបែបនេះ។ ដូច្នេះ ចំពោះយើងៗយល់ថា វាជាដំណាក់កាលដ៏ចាំបាច់មុនពេលដែលយើងធ្វើ ហើយជាអ្វីដែលអង្គជំនុំជម្រះត្រូវបានធ្វើ ទាំងនៅក្នុងកម្រិតអន្តរជាតិ ក៏ដូចកម្រិតជាតិ ហើយនេះជាបទដ្ឋានដែលយើងគួរប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះមួយនេះផងដែរ។ សូមអរគុណ។

[១៥:៣០:៤១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អាកទួរ វែកតែន៖**

ខ្ញុំសូមបញ្ជាក់ដោយខ្លីថា ខ្ញុំគាំទ្រទៅនឹងគោលជំហររបស់សហភាតារបស់ខ្ញុំ។ ការជំនុំជម្រះក្ដីនេះគឺបង្ហាញភស្តុតាងថា យើងត្រូវតែមានវិធានជាក់លាក់ នៅពេលដែលយើងស្ដាប់ចម្លើយអ្នកណាម្នាក់នោះ គឺថាយើងត្រូវធ្វើយ៉ាងម៉េច ឲ្យមានភាពស្មោះត្រង់ ហើយចំពោះ -- យើងឃើញហើយថា តាំងពីមុនមកនោះ គឺហាក់ដូចជាថា ប្រសិនបើយើងជឿទៅលើកំណត់ហេតុស្ដាប់ចម្លើយណាមួយនោះ គឺយើងឃើញថា អ្នកស៊ើបអង្កេតនោះ គាត់បានជួបសាក្សីនៅមុនថ្ងៃទី១៨ ខែកុម្ភៈ ហើយនៅក្នុងកំណត់ហេតុ ហើយនិងប្រតិចារឹកសវនាការនោះ ពុំបានបញ្ជាក់អំពីអង្គហេតុដែលមានឆ្លើយដោយសាក្សីនោះទេ។ ដូច្នេះ ដើម្បីជាការដំណើរការល្អនោះ ខ្ញុំសូមគាំទ្រទាំងស្រុងទៅលើសហភាតារបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បន្ថែមៗបញ្ហាទៀត ឬក៏បញ្ហាដដែល? ហើយបើបញ្ហាដដែល លុះត្រាតែរសៀលនេះ យើងធ្វើតែបញ្ហានេះបានហើយ មិនបាច់តាំងសំណួរទេតាមទំនង។ អ៊ីចឹងមែនទេ ធ្វើតែកិច្ចដេញដោលតទល់គ្នាអ៊ីចឹង ឬក៏មិនបាច់តាំងសំណួរទេ?

[១៥:៣២:២០]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ខ្ញុំកំពុងតែត្រៀមនឹងពន្យល់ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបន្ថែមនូវចំណុចមួយទៀត។ ប៉ុន្តែខ្ញុំគិតថាអ្វីដែលខ្ញុំចង់និយាយគឺថា យើងកំពុងតែធ្វើការដោះស្រាយជាមួយនឹងការស៊ើបអង្កេត ដើម្បី

ជួសជុលដល់ការខូចខាត ឬក៏មានការបញ្ហាណាមួយនៅក្នុងដីកាដំណោះស្រាយ។ ដូច្នេះ អ្វីដែលយើងកំពុងតែចង្អុលបង្ហាញនោះ គឺយើងឃើញថាវាមានកើតឡើងនៅក្នុងករណីជាច្រើន។ ឧទាហរណ៍ដូចជាចម្លើយ ឬក៏កំណត់ត្រាខ្សែអាត់ ទាំងអស់នេះគឺជាអ្វីដែលខ្ញុំគិតថា វាហាក់ដូចជាហួសនូវការសន្មតទៅលើភាពត្រឹមត្រូវ ឬក៏ភាពធម្មតា។ នេះគឺជាបញ្ហាធ្ងន់ធ្ងរ មិនមែនជារឿងធម្មតានោះឡើយ។ ហើយនេះគឺជាអ្វីមួយដែលយើងបានលើកឡើង នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ គឺថាជាបញ្ហាសំខាន់ដែលយើងបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ហើយសូម្បីនៅព្រឹកនេះ ក៏ខ្ញុំបាននិយាយអំពីបញ្ហានេះដែរ គឺយើងទទួលបាននូវប្រតិចារឹករបស់សាក្សី គឺថាបន្ទាប់ពី៣ថ្ងៃ។ ហើយអានេះគឺកើតឡើងបន្ទាប់ពីអ្វីដែលបាន -- ដូច្នេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា អង្គជំនុំជម្រះនេះគួរ មិនគួរឲ្យមានការសន្មត ឬក៏ការស្មានទាក់ទងទៅនឹងការផ្តល់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំសូមទោស ដែលខ្ញុំបានលើកឡើងអំពីបញ្ហានេះ។

[១៥:៣៤:០៤]

**ប្រធានអង្គជំនុំ៖**

ទី១ យើងរំឭកឡើងវិញ យើងបានកត់សម្គាល់បញ្ហានេះ ញឹកញាប់ហើយ។ ទី១ បញ្ជាក់នៅក្នុងការជម្រាបប្រាប់អំពីករណីយកិច្ចសាក្សីនីមួយៗ ក្នុងការផ្តល់សក្ខីកម្ម។ ប្រសិនបើមិនច្រឡំទេ លោកអាចពិនិត្យនូវការប្រាប់អំពីសិទ្ធិ និងករណីយកិច្ចសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ យើងបានប្រាប់ច្បាស់លាស់អំពីឲ្យគាត់ឆ្លើយតែការណ៍ណាដែលពិត ដែលគាត់បានដឹង បានឮ បានឃើញ និងបានចងចាំ បន្ថែមគឺបទពិសោធន៍ ហើយនិងការកត់សម្គាល់របស់គាត់ ពាក់ព័ន្ធទៅនឹងអង្គហេតុ ព្រឹត្តិហេតុទាំងឡាយ ដែលទាក់ទិននឹងសំណួរ ដែលភាគី ឬអង្គជំនុំជម្រះបានសួរ។ នេះជាកិច្ចការរបស់អង្គជំនុំជម្រះ។ ជាបន្តបន្ទាប់ ទោះបីមិនមានការជំទាស់ក៏ដោយ គឺយើងតែងតែរំឭក និងប្រាប់ថា វាឥតមានតម្លៃទេ ប្រសិនបើការឆ្លើយស្មានៗ ដោយការសន្និដ្ឋាន ប្រើពាក្យ “អាច” អីអីចឹង ព្រោះសាក្សីមិនមែនជាអ្នកជំនាញដែលមានសិទ្ធិក្នុងស្វែងយល់ ហើយធ្វើសេចក្តីសន្និដ្ឋានវាយតម្លៃអំពីព្រឹត្តិការណ៍ណាមួយជូនមកអង្គជំនុំជម្រះទេ។

[១៥:៣៥:១៤]

បញ្ហាមួយទៀត លោកបាននិយាយអំមិញ មានសារៈសំខាន់ណាស់ អង្គជំនុំជម្រះជម្រាបច្រើនដងហើយថា បើមានបញ្ហាវាធ្ងន់ធ្ងរដល់ម្លឹង សូមឲ្យអស់លោករៀបចំនូវសំណើសុំរបស់លោកជាលាយ

លក្ខណ៍អក្សរដើម្បីបង្ហាញសព្វគ្រប់ នៅក្នុងសំណើសុំរបស់លោក ដើម្បីអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានក្នុងការទៅពិចារណានៅលើអ្វីដែលជាសំអាងហេតុរបស់លោក ដើម្បីចេញសេចក្តីសម្រេចកំណត់អំពីបញ្ហានេះ ដើម្បីដោះស្រាយបញ្ហាទូទៅតែម្តង។ ដោយសារនៅក្នុងសំណុំរឿងក្តីនេះ វាមានឯកសារជាច្រើន វារាប់លានទំព័រឯណោះ អ៊ីចឹងយើងមិនអាចបែងចែកប្រភេទឯកសារហ្នឹងឲ្យបានច្បាស់លាស់ទេ។ ថាតើឯកសារហ្នឹងវាមានប៉ុន្មានបែប ដែលយើងដោះស្រាយតែម្តងឲ្យចប់នោះ។ រហូតដល់ពេលនេះយើងមិនទាន់ដោះស្រាយបាននៅឡើយទេ នៅតែមានបញ្ហាថ្មីៗនៅឡើយទេ។ ប៉ុន្តែអង្គជំនុំជម្រះព្យាយាមដោះស្រាយម្តងហើយម្តងទៀតបញ្ហាឯកសារនេះ រហូតដល់ថ្ងៃនេះ ក៏នៅតែមានបញ្ហាដដែល។

[១៥:៣៦:១២]

ប៉ុន្តែស្តាយណាស់ ដោយសារលោកប្រើពាក្យថា "វាធ្ងន់ធ្ងរណាស់" ប៉ុន្តែបែបជាលើកឡើងនូវពាក្យ គ្រាន់តែការតាំងសំណួរប៉ុណ្ណឹង គ្រាន់តែជំទាស់ -- ទាល់មានការជំទាស់ពីសហព្រះរាជអាជ្ញាបានលើកឡើងថាវាធ្ងន់ធ្ងរ។ បើវា ជំងឺវាធ្ងន់ធ្ងរយ៉ាងនេះ សូមឲ្យលោករៀបចំនូវជាសំណើសុំជាឯកសារពាក់ព័ន្ធនឹងអាបញ្ហានេះ ប្រឈមនេះ ដើម្បីដោះស្រាយបញ្ហានេះឲ្យបានជ្រះស្រឡះតែម្តង អាហ្នឹងជាការល្អប្រសើរ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណចំពោះការបញ្ជាក់របស់លោកប្រធាន។ ដូច្នេះ ខ្ញុំគួរតែដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងការជំទាស់នេះ ឬមួយក៏យ៉ាងម៉េចដែរលោកប្រធាន? ខ្ញុំបានធ្វើការសួរហើយខាងព្រះរាជអាជ្ញាគាត់បានជំទាស់ ហើយខ្ញុំងើបឡើងបន្តដើម្បីធ្វើការ--

[១៥:៣៧:០០]

**ប្រធានអង្គជំនុំ៖**

យើងនឹងសម្រេចឥឡូវនេះ ចំពោះបញ្ហានេះ យើងមិនអនុញ្ញាតឲ្យសាក្សីនេះនៅរុំរ៉ៃរាប់អាទិត្យទៀតទេ នៅចំពោះមុខអង្គជំនុំជម្រះ។ ប៉ុន្តែយើងឆ្លើយតបអម្បាញ់មិញនេះ ដោយសារលោកឆ្លៀតឱកាសនេះ ប្រើពាក្យពេចន៍វាសារៈសំខាន់នៃបញ្ហានេះ វាយូរហើយ វាច្រើនហើយ។ ឆ្លៀតឱកាសនេះទើបយើងពន្យល់លោកថា បើវាសំខាន់យ៉ាងដូច្នេះ វាជំងឺនេះ វាកើតឡើងគ្រប់ដំណាក់កាល គ្រប់សាក្សីរបៀបនេះ សូមឲ្យលោករៀបចំនូវជាលាយលក្ខណ៍អក្សរមកវាមានភាពហ្មត់ចត់ជាង។ វាមានសំអាងហេតុច្បាស់លាស់ជាង។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមថ្លែងអំណរគុណចំពោះការបញ្ជាក់។ ខ្ញុំសូមអភ័យទោស។

[១៥:៣៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៥:១០]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីដោះស្រាយបញ្ហាកំពុងតែប្រឈមនេះ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតឡើង -- កំពុងតែកើតមានឡើងនេះ។ ហើយទន្ទឹមនឹងនេះ សូមឲ្យលោកមេធាវីពាក់ព័ន្ធនឹងបញ្ហាតាំងសំណួរចំពោះសាក្សីរូបនេះ សុំបន្ថយល្បឿនរបស់ខ្លួន ព្រោះមានការនិយាយញាប់ នាំឲ្យការបកប្រែភាសាហ្នឹង ពិបាកបកស្រាយ ពិបាកបក ហើយបកមិនបានពេញលេញនូវខ្លឹមសារដែលលោកនិយាយ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមរំឭកថា យើងបានទទួលសំណើជាច្រើនដែលពាក់ព័ន្ធទៅនឹងភាពមិនប្រក្រតីនៃវិធីសាស្ត្រក្នុងការសួរសំណួរ ហើយយើងក៏បានឆ្លើយតបទៅនឹងសំណើជាលាយលក្ខណ៍អក្សរ។ សំណួរដែលចោទសួរនៅក្នុងសវនាការ គឺធ្វើឡើងជាចំហ ដោយមិនគិតទៅលើការចោទប្រកាន់ ដែលថាការស៊ើបអង្កេតប្រហែលជាអាចធ្វើឡើងដោយមិនទៀងត្រង់ ឬក៏មានការបន្លំ។

ខ្ញុំគិតថា ការចោទប្រកាន់បែបនេះ គឺមិនត្រឹមត្រូវទេ ក្នុងដំណាក់កាលនេះ។ ដូច្នេះសូមឲ្យលោកសួរសំណួរណាដែលមិនមានការលើកឡើងនូវការចោទប្រកាន់បែបនេះ។ ហើយសូមសួរសំណួរជាចំហ ដូច្នេះ ខ្ញុំគិតថានេះជាចំណុចសំខាន់បំផុតដែលខ្ញុំចង់ជម្រាបជូនហើយ។

[១៥:៤៧:០៥]

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកចៅក្រម ឡាវែន៍ ចំពោះការបញ្ជាក់ដ៏ច្បាស់នេះ។ ខ្ញុំនឹងតាមសំណូមពររបស់លោកប្រធាន ហើយខ្ញុំនឹងនិយាយឲ្យបានយឺតៗ។ តាមសំណើរបស់ខ្ញុំ គឺខ្ញុំសូមស្នើថា ចម្លើយពីសាក្សី

នេះ គឺជារឿងមួយដែលត្រឹមត្រូវ។ ដូច្នេះ ខ្ញុំអាចនឹងទទួលស្គាល់ថា យើងត្រូវតែមានសុច្ចរិតភាព ខ្ញុំមិនបាននិយាយចំឈ្មោះអ្នកណាម្នាក់ថា អ្នកស៊ើបអង្កេតនេះគឺជាមនុស្សមិនល្អ ឬក៏យ៉ាងណានោះទេ។ ដូច្នេះ ខ្ញុំទទួលស្គាល់ និងទទួលយល់ព្រមទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ។ ដូច្នេះ ថាតើខ្ញុំអាចសុំសួរបន្តទៅសាក្សីបានតទៅទៀតទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី សូមត្រឡប់មកអ្វីដែលខ្ញុំសួរលោកពីមុននេះ។ ខ្ញុំមានសំណួរដដែលហ្នឹងឯង តើលោកមានន័យថាម៉េច? លោកចង់មានន័យថាម៉េច នៅពេលដែលលោកនិយាយថា គឺថាលោកត្រូវបានអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង គឺថាមានការបង្ខិតបង្ខំលោក -- តើមានអ្នកស៊ើបអង្កេតនេះជជីកដេញដោលសួរឲ្យលោកឆ្លើយនោះ?

[១៥:៤៨:៤៨]

**លោក នង សុផង់៖**

**ឆ៖** បាទ វាមានលក្ខណៈអ៊ីចេះដូចថា ឧទាហរណ៍ថា ប៉ង់ និង ថេរ ហ្នឹង ខ្ញុំក្នុងចម្លើយរបស់ខ្ញុំ "ថាខ្ញុំមិនដឹងថា គាត់ទៅណាអីទេ"។ ហើយគាត់នៅតែសួរថា "អ្នកណាបាត់មុន អ្នកបាត់ក្រោយអី?" អាហ្នឹងជាសំណួរដែលខ្ញុំពិបាកនឹងឆ្លើយណាស់បាទ។ វាអ៊ីចឹងទេ បើមានថា ខ្ញុំថាមិនដឹងទៅហើយ គាត់ចង់សួរថា ប៉ុន និង ថេរ ហ្នឹងអ្នកណាគេដកមុន អ្នកណាគេដកក្រោយ។ នេះជាលក្ខណៈដែលថា គេថាមិនដឹងហើយ។ នៅតែថា មុនក្រោយឯណាទៀត បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ដូច្នេះខ្ញុំច្បាស់ហើយ បន្ទាប់ដែលលោកឆ្លើយថា លោកគិតថាជាចម្លើយត្រឹមត្រូវជូនដល់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយគឺថាលោកបញ្ជាក់ថា លោកមិនចង់ឆ្លើយតទៅទៀត ប៉ុន្តែគេនៅតែជជីកឲ្យលោកឆ្លើយ ហើយចំពោះអ្វីដែលលោកគឺថា អាចនឹងមិនបានដឹងនោះ។ ថាតើអ៊ីចឹងមែនទេលោក?

[១៥:៥០:០០]

**ឆ៖** បាទ អឺ អ៊ឺចឹងបាទ ធ្វើឲ្យខ្ញុំវា--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយសាក្សី។

សូមអញ្ជើញលោកចៅក្រម ហ្វ្រង់ម៉ាក!

[១៥:៥០:១៤]

**ចៅក្រម ហ្វ្រង់ម៉ាក ឡាវែន៍៖**

លោកមេធាវី អ៊ីនូហ្ស៊ី ខ្ញុំគិតថា យើងមានបញ្ហាក្នុងការទំនាក់ទំនងគ្នាហើយ។ គឺថា ខ្ញុំប្រាប់ហើយថា សូមឲ្យសួរសំណួរជាចំហ កុំឲ្យសួរសំណួរដែលមានការនាំមុខ កុំឲ្យមានលក្ខណៈដែលថាមិនស្មោះត្រង់។ ខ្ញុំគិតថា នេះជាចំណុចសាមញ្ញបំផុត។ លោកៗប្រាប់សាក្សីថា របៀបការសួរនោះ គឺថាសួររបៀបមួយមិនទៀងត្រង់។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោក លោកស្រីចៅក្រម សាក្សីគាត់ជាអ្នកឆ្លើយទេ ហើយខ្ញុំក៏សួរទៅតាមចម្លើយដែលសាក្សីបានឆ្លើយ។ នេះគឺអ្វីដែលសាក្សីគាត់បានឆ្លើយ។

**ចៅក្រម ហ្វ្រង់ម៉ាក ឡាវែន៍៖**

លោកមេធាវី ខ្ញុំគិតថា យើងមិនមែននៅទីនេះ ដើម្បីធ្វើបទអត្ថាធិប្បាយទៅលើការឆ្លើយរបស់អង្គជំនុំជម្រះទៅលើការជំទាស់នោះទេ។ លោកនៅទីនេះ គឺត្រូវតែស្តាប់ គោរពតាមការបង្គាប់បញ្ជារបស់អង្គជំនុំជម្រះ។

[១៥:៥១:២៨]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ដូច្នេះ ខ្ញុំបានយល់ច្បាស់ហើយ ចំពោះសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ។ ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យ -- ខ្ញុំត្រូវតែសួរសំណួរបើកចំហ ទោះបីជាចម្លើយពីសាក្សីនេះ គឺបានចង្អុលបង្ហាញយ៉ាងច្បាស់នោះក៏ដោយ។ តើនេះគឺជាអ្វីដែលអង្គជំនុំជម្រះចង់បានមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វ្រង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា យើងមិនត្រូវបកស្រាយទៅលើរបៀបនៃសាក្សីឆ្លើយនោះទេ។ យើងត្រូវតែមានអាកប្បកិរិយានៅក្នុងសវនាការនេះ ធ្វើម៉េចឲ្យមានលក្ខណៈទៀងត្រង់ ស្មោះត្រង់។

[១៥:៥២:២៩]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណច្រើន លោកចៅក្រម ឡាវែន៍។ ខ្ញុំសូមបន្តសំណួរទៅមុខទៀត លើប្រធានបទដដែលនេះ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី ចំណុចមួយដែលលោកបានឆ្លើយនៅក្នុងបន្ទប់សវនាការ នៅពេលដែលលោកចូលមកថ្ងៃពុធសប្តាហ៍មុន លោកបានអះអាងទៅនឹងសំណួររបស់លោកប្រធាន ទៅនឹងខ្លឹមសារនៅក្នុងចម្លើយរបស់លោកជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកចាំថា លោកបានឆ្លើយទៅនឹងសំណួររបស់ចៅក្រមទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំមិនសូវយល់សំណួររបស់លោក។ តើសំណួរអីទៅ ដែលចៅក្រមបានលើកឡើង?

**ស៖** តាមដែលខ្ញុំចាំនោះ បាទ ខ្ញុំសូមនិយាយម្តងៗមួយ នៅថ្ងៃទី១ ដែលលោកបានមកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺខ្ញុំគិតថា នៅថ្ងៃពុធ សប្តាហ៍មុននេះ។ ខ្ញុំសូមសួរឡើងវិញ លោកសាក្សី បើមិនច្បាស់ទេ។

**ឆ៖** បាទ ខ្ញុំមិនច្បាស់មែន មិនដឹងថា ព្រោះសំណួរគឺវាមានច្រើន។ ដល់អ៊ីចឹង មិនដឹងជាលោកចង់និយាយថា កាលពីថ្ងៃពុធ ដំបូងហ្នឹង ចង់សួរថា សំណួរអី? ហើយខ្ញុំបានឆ្លើយមែន គឺប៉ុន្តែមិនដឹងសំណួរអីខ្លះទេ បាទ មិនចងចាំទេ។

[១៥:៥៤:៤៣]

**ស៖** លោកសាក្សីជាការត្រឹមត្រូវហើយ ខ្ញុំសូមទោស ចំពោះដែលខ្ញុំបានសួរមិនច្បាស់។ អ្នកដែលសួរទៅលោកដំបូងផុត គឺប្រធានអង្គជំនុំជម្រះសាលាដំបូងតែម្តង លោកនៅចាំទេ?

**ឆ៖** បាទ ចាំបាន។

**ស៖** សូមអរគុណ។ ហើយតាមដែលខ្ញុំចាំនោះ សំណួរមួយដែលលោកប្រធានសួរទៅលោក គឺ

ថាតើលោកបានពិនិត្យមើលចម្លើយទាំងពីររបស់លោកដែលជូនទៅលើសហចៅក្រមស៊ើបអង្កេត យោងទៅលើនីតិវិធីនៅក្នុងអង្គជំនុំជម្រះនេះ ដែលសួរទៅលោក ថាតើលោកបានពិនិត្យមើលចម្លើយរបស់លោកហើយឬនៅនោះ លោកមានចាំបញ្ហានេះទេ?

**ឆ៖** បាទ លោកប្រធានបានសួរខ្ញុំដូច្នោះមែន។ បានឲ្យខ្ញុំពិនិត្យអ៊ីចឹងមែន។ ហើយខ្ញុំពិនិត្យទៅក៏ឃើញថា វាស៊ីគ្នាបាទ អត់មានអីប្រែប្រួលទេ។

**ស៖** សូមអរគុណច្រើន។ ហើយសំណួរបន្តទៅទៀតនោះ គឺលោកប្រធានបានសុំឲ្យលោកបញ្ជាក់អំពីខ្លឹមសារនៃចម្លើយទាំងពីរហ្នឹង ថាតើលោកនៅតែទទួលស្គាល់នូវអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ គឺត្រឹមត្រូវឬក៏អត់? ហើយលោកឆ្លើយអះអាងថាជាការត្រឹមត្រូវ។ អ៊ីចឹងមែនទេ?

[១៥:៥៦:២៨]

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** សូមអរគុណលោកសាក្សី។ ហើយនៅពេលដែលលោកផ្តល់សក្ខីកម្មនៅក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ ហើយខ្ញុំសូមលើកចំណុចឡើង ចំណុចនេះនៅពេលមួយនោះ លោកបាននិយាយថា ផ្នែកខ្លះនៃចម្លើយរបស់លោកនោះ គឺថាមិនអាចយកជាការបានទេ មិនអាចយកជាភស្តុតាងបានទេ។ លោកបានបញ្ជាក់ច្បាស់ថា ផ្នែកទាំងនោះ គឺពាក់ព័ន្ធទៅនឹងផ្នែកដែលលោកឆ្លើយដោយស្មានៗ។ តើនេះត្រឹមត្រូវអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបានប្រកាស ហើយប្រកាសទៀតថា សូមឲ្យអស់លោកទាំងអស់ពិនិត្យមើលចម្លើយដែលចៅក្រមស៊ើបអង្កេត ចំពោះពាក្យណាដែលខ្ញុំឆ្លើយថា អាច ឬក៏ប្រហែល ឬមួយក៏តាមប៉ាន់ស្មានណ៎ា សូមកុំឲ្យអស់លោកទាំងអស់យកចម្លើយរបស់ខ្ញុំនេះ ថាជាចម្លើយដែលបានការនោះបាទ។ គឺទុកជាអសារបង់ចុះ។ ទុកជាមោឃៈបាទ។

[១៥:៥៧:៤៩]

**ស៖** សូមអរគុណលោកសាក្សី។ សូមជួយកែតម្រូវផង បើខ្ញុំលើកឡើងមិនត្រឹមត្រូវ គឺអង្គជំនុំជម្រះបានពន្យល់ទៅលោកអ្វី មានន័យថាជាការសន្មត ជាការស្មានៗ ដូចជាពាក្យថា "ប្រហែលជាអាចជា" តើលោកមាននៅចាំទេ? ពីព្រោះអង្គជំនុំជម្រះបានពន្យល់ហើយ ពន្យល់ពាក្យថា ចម្លើយស្មានៗ ប្រហែលជានេះយ៉ាងម៉េចនោះហើយ។ លោកនៅចាំទេ?

**ឆ៖** បាទ បាន ខ្ញុំ -- លោកប្រធានបានដាស់តឿនខ្ញុំ ប្រហែលជាថ្ងៃទីពីរ តាមខ្ញុំចាំហ្នឹង គឺមុននឹងចូលប្រជុំភ្លាម លោកប្រធានដាស់តឿនខ្ញុំភ្លាម ហើយក៏ខ្ញុំយកចិត្តទុកដាក់ក្នុងចម្លើយរបស់ខ្ញុំ គឺមិនឲ្យមានពាក្យស្មាន មានពាក្យប្រហែលហ្នឹងទៀតទេបាទ។ ខ្ញុំបានចងចាំ។

**ស៖** សូមអរគុណលោកសាក្សី។ ប្រហែលសំណួរនេះ ជាសំណួរចុងក្រោយហើយ។ នៅពេលដែលលោកផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត តើអ្នកណាម្នាក់ដែលអ្នកស៊ើបអង្កេតហ្នឹងពន្យល់ទៅដល់លោកថា កុំឲ្យលោកឆ្លើយដោយស្មានៗដែរឬទេ?

[១៥:៥៩:១៦]

**ឆ៖** បាទ មិនមានការពន្យល់ជាក់លាក់ ដូចលោកប្រធានបានប្រាប់ខ្ញុំនោះទេ គ្រាន់តែថាអ្វីដែលពិតបានយើងនិយាយ ដែលយើងបានដឹងច្បាស់ ឮច្បាស់ ឬក៏មានបទពិសោធន៍ដែលធ្លាប់ឆ្លងកាត់។ បាទពាក្យនេះ គឺចៅក្រមស៊ើបអង្កេតបាន មុននឹងចាប់ផ្តើមធ្វើសំណួរអីក៏លោកបានផ្តល់អនុសាសន៍ដែរបាទ។

**ស៖** សូមអរគុណច្រើនលោកសាក្សី។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

លោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់ ខ្ញុំមិនទាន់ចប់នៅឡើយទេ ខ្ញុំនឹងបន្តសួរនៅថ្ងៃស្អែក ប៉ុន្តែថាតើគួរឈប់ត្រឹមនេះ ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

គួរតែឈប់ត្រឹមហ្នឹងហើយ ហើយមុននឹងបន្តទៅថ្ងៃស្អែក សូមរំឭកលោកមេធាវីផងដែរថា សូមលោកពិនិត្យបន្ថែមទៀត នូវវិធាន៣៦ អនុវិធាន៧ នៃវិធានផ្ទៃក្នុង -- វិធាន៧៦ អនុវិធាន៧ នៃវិធានផ្ទៃក្នុងដែលបានចែងច្បាស់លាស់ តាមប្រព័ន្ធច្បាប់ស៊ីវិល លើកលែងតែកម្មវត្ថុបណ្តឹងឧទ្ធរណ៍ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុស នៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ។ សូមគ្រាន់តែចាប់អារម្មណ៍ទៅ ហើយពិចារណា ហើយបើសិនជាមានបញ្ហានេះទៀត អាចដោះស្រាយនៅថ្ងៃស្អែកទៀត។

[១៦:០១:១៤]

បាទអរគុណលោកមេធាវី អរគុណសាក្សី។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេល

សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនារការ សម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៦ ខែកញ្ញា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នង សុផង់ ដែលនឹងសួរដេញដោល ដោយក្រុមមេធាវីការពារក្តី លោក នួន ជា និងក្រុមមេធាវីការពារក្តីលោក អៀង សារី។ សូមសាធារណជន និងភាគីជ្រាប។

លោក នង សុផង់ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវបន្តនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយដំណើរការសវនាការទំនងជាអាចចប់នៅថ្ងៃស្អែកហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សូមសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

[១៦:០២:២៧]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយឲ្យនាំពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*